# លោកន័យសាស្ត្រ

ប្រមូល និង រៀបរៀង

**មាស-ព្រេង**

ភ្នាក់ងារក្រុមព្រះនគរបរេ

**ចម្លងដោយ**

លេខ២៣៦អឺ០ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស ២៥៤៣ គ.ស ១៩៩៩

ទទួលបានយកពីលោក ឡៅ ឃុន សំរ៉ឹង ដល់ករុណា
ខ្មែរសម្រាប់ដាក់ទុក ក្នុង eLibrary of Cambodia

# លោកន័យសាស្ត្រ

——×•×——

ប្រមូលនិងរៀបរៀង

មាស-ហ្វេង

ភ្នាក់ងារក្រុមព្រះធរាបាល

ការផ្សាយរបស់

លេខ ៤៤ វិថីកេះដោះវិន ភ្នំពេញ

រក្សាសិទ្ធិ

ព. ស. ២៤៩៩
គ. ស. ១៩៥៧

## អារម្ភកថា

ខ្ញុំជាអ្នកមានសមត្ថភាពដ៏ស្តួចស្តើង, កាលខ្ញុំបានអាន លោកនីតិបករណ៍ និងគតិលោក របស់ទេពកញ្ញាសុគន្ធប្រជាជន ឃើញមានសុភាសិត និងពាក្យឃ្លាជាពាក្យប្រដៅខ្លួនពីរោះក្បោះក្បាយ នាំឲ្យខ្ញុំមើលមិនមានធុញទ្រាន់ ។

ជាតិសំណាន់ខ្ញុំខ្ពង់ខ្ពស់ ទៅទៀតបានប្រទានច្បាប់ស្រី ហិតោបទេសដែលជាច្បាប់វិសេសដែលពួកលោកនិយមប្រើ របស់ព្រះមហាវិរិយបណ្ឌិត ប៉ាង-ខាត់ ទៀតនាំឲ្យខ្ញុំព្យាយាមមើលមិនដាក់ចុះពីដៃ ស្មើក្តួចបាយក្តួចទឹកកើតបីតិបានយ៉ាងជ្រះ ត្រេកចិត្តត្រេកកាយចំពោះអត្ថន័យសុភាសិតពីរនោះ ។ ការពីរោះ, ការជាប់ចិត្ត, និងការស្ងប់នេះ នាំឲ្យខ្ញុំដកស្រង់ភាសិតពាក្យនោះដាក់តាមពួកតាមក្រុម ក្រៀងឲ្យងាយយល់ចូលចិត្ត

បានដើម្បីប្រដៅខ្លួនខ្ញុំ, មិនតែប៉ុណ្ណោះ ខ្ញុំបានស្វែងរកច្បាប់
ផ្សេង ៗ ដទៃទៀតដែលជាស្នាដៃអ្នកប្រាជ្ញខ្មែរបុរាណ ។
នៅខែមេសាឆ្នាំ១៩៥៥នេះ ជាឆ្នាំត្រូវខ្ញុំរៀបចំខ្លួនលាឈប់ពី
ដំណែងរាជការ ដើម្បីនឹងចេញសាងព្រះផ្នួសក្នុងនិព្វាន ធ្វើ
ឲ្យខ្ញុំស្តាយដល់ច្បាប់នេះពន់ពេកដោយច្បាប់នេះវិសេសលើស
ទីងលោកនីតិបុរាណៗទៅទៀត ហើយរបៀបចងក្រងរបស់ខ្ញុំក៏
ដូចជាច្បាប់លោកនីតិនោះដែរ ខ្ញុំក៏បានដាក់ឈ្មោះឲ្យច្បាប់
នោះថា «លោកន័យសាស្ត្រ» គឺច្បាប់ជាទីបង្ហាញន័យ
ពន្យល់ប្រយោជន៍ដល់មនុស្សលោក ហើយបានយកទៅប្រ-
គេនលោកមហាវិមលធម្ម ពិនិត្យកែនិងសុំអនុញ្ញាត ពីលោក
ដើម្បីបោះពុម្ព ទុកឲ្យជនជាន់ក្រោយក្រោយយកសេចក្តីច្បាប់
នេះពិចារណាតទៅទៀត ទីងទុកជាអវសានកិច្ចនៃជីវិតខ្ញុំក្នុងការ
ធ្វើដំណើរទៅកាន់ភេទឧត្តមគឺភេទព្រះសង្ឃ ។
ទីបំផុតនេះខ្ញុំសង្ឃឹមថា ជនជាតិខ្មែរទូទៅមុខជាពេញចិត្ត

នឹងការអាន-ការគិតគូរច្បាប់ប្រដៅប្រយោជន៍ដល់ខ្លួន ដែល
ជាច្បាប់បរទេសក្ដី ច្បាប់របស់ខ្មែរក្ដី ដូចជាខ្ញុំមិនទាន់ ។

ភ្នំពេញថ្ងៃទី ១ ខែមេសាឆ្នាំ១៩៥៥

ភ្នាក់ងារតម្រួតនគរបាល

មាស-ព្រេន-

## វិជ្ជាវគ្គ

១– ជះមា ពុទ្ធាយ សិទ្ធំ សូមឲ្យសេចក្ដីប្រាថ្នា របស់សាធុជនទាំងឡាយ បានសម្រេចផល ដោយកិរិយានមស្ការចំពោះព្រះពុទ្ធជាម្ចាស់ – ជាអគ្គបុគ្គលខ្ពស់ផុតក្នុងលោក ដូចជាៈលខាៈនៃពពុះទឹកក្នុងទន្លេគង្គា ។

២– ពេះកម្មយ សាស្ត្រនេះ នរជនបានក្រងក្រាប ស្ដាប់ហើយនឹងប្រគល់ឲ្យនូវសេចក្ដីជំនាញក្នុងភាសាខ្មែរ នូវសេចក្ដីទៀតផង បក្នុងសំដីថ្មាក់ នឹងក្នុងទីតាំងផ្កា តាំងទូរយ ដំរិចត្រផ្សេង ៗ ក្នុងទីតាំងពួង ។

៣– អ្នកប្រាជ្ញ កាលះបើស្វែងរកវិជ្ជានឹងប្រញាប់ ខប្បី គិតថាដូចជាខ្លួនមិនចាស់មិនស្លាប់, កាលបើស្វែងរកធម៌ គប្បីគិតថាខ្លួនត្រូវមច្ចុរាជចាប់ក្រញួចសក់ពោកសម្លាប់ផ្សង្វាវៈនេះ

ហើយ ។

៤-បណ្ដាទ្រព្យទាំងពួង, វិជ្ជា លោកពោលថាជាទ្រព្យដ៏ឧត្ដម ព្រោះវិជ្ជាចោរលួចយកមិនបានផង កាត់ថ្លៃមិនបានផង មិនចេះរេចរិលអស់ទៅឯង សព្វៗកាល ។

៥-វិជ្ជា យ៉ាងយានជំនិះដែលនាំជាកភាព ឲ្យបានចូលទៅជិតព្រះនរបតី ដែលគេបានទៅជិតបានដោយក្រ ឬអ្នកមានបុណ្យដ៏ក្រៃលែងជាងព្រះនរបតីទៅទៀត ដូចស្ទឹងដែលហូរទៅកន្លែងទាប តែងប្រមូលយកទឹកហូរទៅកាន់សមុទ្រ ។

៦-វិជ្ជា នាំឲ្យមានវិន័យ, វិន័យនាំឲ្យបានសេចក្ដីថ្លៃថ្នូរ, សេចក្ដីថ្លៃថ្នូរ នាំឲ្យបានទ្រព្យសម្បត្តិ ទ្រព្យសម្បត្តិនាំឲ្យបានធម៌, ធម៌ដឹកនាំឲ្យបានសេចក្ដីសុខ ។

៧- សាស្ត្រវិជ្ជានិងសាស្ត្រវិទ្យា ពាក្យពីរនេះ គួរប្រតិបត្តិសិក្សារៀនឲ្យចេះជំនាញទាំងអស់ វិជ្ជាទី ១ ខាងដើម (សាស្ត្រវិជ្ជា) គេគប្បីរៀនឡើងដើម្បីស៊ីបលេងជាថ្នាក់ផ្ទះ;

វិជ្ជាទី ខាងមុខ (សាស្ត្រវិជ្ជា) បុគ្គលនោះគេគោរពគ្រប់កាល ទាំងពួង ។

៨– សាស្ត្រវិជ្ជា គឺកសាងអាវុធ ប្រើអាវុធ គ្រឿងចក្រ យានអាវុធទំនប់ប្រដាប់គុនជាដើម សម្រាប់ប្រហារគ្នា ទៅវិញទៅមក ។

៩– សាស្ត្រវិជ្ជា គឺវិជ្ជាការចេះដឹងរៀនធម៌គម្ពីរដីកា ច្បាប់សម្រាប់ប្រតិបត្តិឲ្យកើតសេចក្តីសុខក្សេមក្សាន្ត ឬសេចក្តីចម្រើនលោក ។

១០– សាស្ត្រវិជ្ជា ជាគ្រឿងកាត់បង់នូវសេចក្តីសង្ស័យជាអនេក ជាគ្រឿងបើកបង្ហាញនូវភពចក្ខុថ្មី ទំងជាភ្នែកសម្រាប់សម្លឹងមើលសព្វសារពើការណ៍ទាំងឡាយ, អ្នកណាមិនមានសាស្ត្រវិជ្ជា អ្នកនោះទុកដូចជាមនុស្សខ្វាក់ ។

១១– ភាពជាយុវជន ១ ភាពជាអ្នកមានទ្រព្យច្រើន ១ ភាពជាអ្នកមានអំណាចយស ១ ទំងភាពជាអ្នក

មិនបែកបាក់គ្នា ១ បើមានតែមួយ ៗ ក៏នាំឲ្យខូចប្រយោជន៍ ធ្វើដូចម្ដេចហ្ន៎ ឲ្យបានគ្រប់ទាំង ៤ ប្រការក្នុងខ្លួនមនុស្ស ?

១៦– អ្នកណាមិនដំកល់ក្នុងការឲ្យទាន, ក្នុងតបៈធម៌គឺសុចរិត, ក្នុងសេចក្ដីអង់អាចក្លាហាន, ក្នុងវិទ្យាសាស្ត្រនិងក្នុងការស្វែងរកទ្រព្យ អ្នកនោះលោកទុកថា ដូចជាខ្ញារៈនៃមាតា ។

១៧– កិរិយាបានទ្រព្យ១ ភាពជាបុគ្គលមិនមានរោគជានិច្ច១ កិរិយាជាទីស្រឡាញ់១ កិរិយាពោលពាក្យពិរោះ១ កូនប្រដៅងាយ១ និងមានវិជ្ជាធ្វើប្រយោជន៍ដល់សាធារណជន១ ធម៌ទាំង ៦ ប្រការនេះជាបរមសុខក្នុងជីវលោកនេះ ។

១៨– មានទ្រព្យមិនស្មើមានវិជ្ជា មានរោគាមិនស្មើពាលនង្គាន ស្រឡាញ់អ្វីមិនស្មើស្រឡាញ់ប្រាណ កំឡាំងអ្វីមិនស្មើនឹងកំឡាំងកម្ម ។

១៥– ចំណេះវិជ្ជា ជាលំអរបស់បុរស សំឡេងពិ
រោះជាលំអរសត្វតាវ៉ៅ ចិត្តស្មោះត្រង់ចំពោះស្វាមីជាលំអរនៃ
ស្ត្រី ខន្តីជាលំអរបស់តាបសបួសមណៈ ។

១៦– សេចក្តីពិត, វិធីនៃការបះដឹង មិនអាចញ៉ាំង
បុគ្គលខ្លាចនឿយហត់ (ខ្លាចសេចក្តីព្យាយាមអត់ធ្មត់) សូម្បី
តែបន្តិចបន្តួច ឲ្យបានជាបុគ្គលមានគុណតម្លៃប្រសើរទេ,
ក្នុងលោកនេះបុគ្គលខ្ជាក់ក្ដក សូម្បីកាន់ប្រទីបនៅដៃ នឹងថា
មើលឃើញទ្រព្យសម្បត្តិដែលនៅជុំវិញខ្លួនឬអ្វី?

១៧– បុរសសូម្បីបានសិក្សារៀនសូត្រ សាស្ត្រវិជ្ជា
ទាំងឡាយហើយ គឺនៅតែល្ងង់ លុះត្រាតែបុរសណាហាត់
ធ្វើផង បុរសនោះទើបឈ្មោះថាជាអ្នកប្រាជ្ញមែន, ដូចគ្រូ
ពេទ្យភ្ជាប់ត្រិះរិះផ្សំថ្នាំបានល្អ ថែមើលមនុស្សឈឺឲ្យជាពេល
មិនមែនគ្រាន់តែប្រាប់ឈ្មោះថ្នាំ ហើយជាពេកនោះទេ ។

១៨– ការបះដឹងជាគ្រូទី១ មេចុងជោយការចិញ

ដូវ១ ការចិញ្ចឹមជីវិតដោយសារបុគ្គលដទៃ១ ទាំង៣ប្រការៈនេះ ជាគ្រឿងរំខាន នាំឲ្យអាម៉ាស់មុខនៃបុរសទាំងឡាយ ។

១៩– បុគ្គលមានការចេះដឹងតិច — កាលៈបើហិនហោចរលំលាយទ្រព្យអស់ហើយ, កិច្ចការទាំងពួងឯទៀត ក៏ឈ្មោះថា អន្តរធានទៅដែរ, ដូចជាស្ទឹងមានទឹកតិច ដល់និទាឃរដូវក៏រីងស្ងួតហួតហែងអស់រលីង ។

២០– ទីឋានណា មិនមានអ្នកប្រាជ្ញជាបណ្ឌិត ទីឋាននោះសូម្បីមានតែអ្នកចេះដឹងបន្តិចបន្តួច ក៏គួរលើកដំកើងសរសើរ ដូចជាប្រទេសណាមួយ ដែលឥតមានព្រឹក្សជាតិបើមានតែដើមល្ហុង ក៏លោកសន្មតថា ជាដើមឈើបានដែរ

២១– អ្នកនេះជាពួកយើង អ្នកនោះជាពួកគេ នេះជាសំដីអ្នកមានចិត្តគំនិតស្រាលះ (ឬអ្នកល្ងង់) ឯអ្នកមានការសិក្សាច្រើន មានចិត្តគំនិតល្អៃតដ៏យាយថា អ្នកនៅលើផែនដីប៉ុណ្ណា សុទ្ធតែជាផៅពង្សនឹងគ្នាទាំងអស់ ។

៦២– លោកអ្នកសប្បុរសទាំងឡាយ តែងសំដែងមេត្តាករុណាចំពោះសត្វទាំងឡាយមិនរើសមុខ សូម្បីបុគ្គលថោកទាបក៏ដោយ, ដូចព្រះចន្ទ្រទីងជាកំណាញ់ពន្លឺមិនឲ្យដល់ទីលំនៅជនចណ្ឌាលក៏ឥតអង្គីមានឡើយ ។

៦៣– អ្នកប្រាជ្ញ តែងប្រើកាលវេលាឲ្យប្រព្រឹត្តទៅដោយការកំសាន្តពាក្យសាស្ត្រ ឬនីតិសាស្ត្រ, មនុស្សល្ងង់ប្រើកាលវេលា ឲ្យប្រព្រឹត្តទៅដោយការប្រព្រឹត្តសេចក្តីវិនាសដោយការដេកនឹងដោយការឈ្លោះទាស់ទែងគ្នា ។

៦៤– អ្នកប្រាជ្ញមានចិត្តល្អ សូម្បីខ្សត់ទ្រព្យ ហើយឥតកម្លាំងក៏អាចជួយកែខៃឲ្យសម្រេចប្រយោជន៍ដោយរួសរាន់បាន ។

៦៥– កិច្ចការណាមួយ ដែលប្រកបដោយគំនិតឥតប្រយោជន៍ករមែងមិនបានផលសមតាមប្រាថ្នាទេ ដូចជាប្រើវេលាព្យាយាមបង្រៀនសត្វកុកឲ្យចេះនិយាយ ដូចសត្វសេក

សុខស្រីក្រៃនាយដង និងបានផលកំភ្លុកផ្គឹមានទៀយ ៗ

២៦- របស់ទ្រព្យដែលនៅលើកំពូលភ្នំខាងទេវយាចិត្យ តែងបានទទួលពន្លឺស្វាងរុងរឿង ព្រោះនៅជិតព្រះអាទិត្យយ៉ាងណា ជនទាបជាតិ វណ្ណៈថោក តែងបានទទួលការចេះដឹងជាពន្លឺព្រោះនៅជិតលោកអ្នកសប្បុរសយ៉ាងនោះដែរ ៗ

២៧- ដង្កូវ ដែលឡើងទៅទំលើក្បាលសាធុជនបាន ព្រោះការនៅលាយឡំជាមួយកម្រងផ្កា, ដុំថ្មដែលអ្នកធំលើកដំកើងហើយ ក៏ក្លាយទៅជាកាតាទេវតាតូកស័ក្តិសិទ្ធិបាន ៗ

២៨- វិជ្ជា បើមិនយកទៅប្រើប្រាស ជាពិសពុល, ភោជន៍ដែលបរិភោគទៅហើយមិនរលួយ ជាពិសពុល, សភា (ទីប្រជុំ) ជាពិសពុល សម្រាប់មនុស្សក្រីក្រនិងមនុស្សល្ងង់, ស្ត្រីក្រមុំ, ជាពិសពុល សម្រាប់មនុស្សចាស់ជរា ៗ

២៩- បរិភោគអាហារ១ ការដេក១ ភ័យ១ និងសេពមេថុន១ ធម៌ទាំង៤ប្រការនេះ មនុស្សនិងសត្វមានស្មើគ្នា

មានតែព្រះធម៌ ( ទឹនវិជ្ជា ) ប៉ុណ្ណោះទេ ទើបអាចធ្វើមនុស្ស និងសត្វឲ្យវិសេសប្លែកពីគ្នា នរណាព្រោះចាកធម៌ (ទឹនវិជ្ជា) អ្នកនោះទុកស្មើសត្វ ។

៣០ មែនពិត, ភាពជាបណ្ឌិតគឺការដឹងកំណត់ប្រមាណខ្លួន កាលណាមានវិបត្តិកើតឡើង នរជនដែលមិនដឹងការកំណត់ប៉ុន្មានខ្លួន តែងតែប្រសព្វវិបត្តិអន្តរាយគ្រប់ជំហានដើរ ។

✳ ៣១ – គប្បីលះបង់បុគ្គលម្នាក់ ដើម្បីស្រង់ត្រកូល, គប្បីលះបង់ត្រកូល, ដើម្បីរក្សាភូមិ, គប្បីលះបង់ភូមិ ដើម្បីរក្សាប្រទេស, គប្បីលះបង់ប្រទេស ដើម្បីស្រោចស្រង់ខ្លួន ។

៣២ – វិជ្ជាមាន១៨ប្រការទៀត ដែលបុគ្គលគប្បីដឹងគឺ៖

១ – សេចក្តីដឹងច្បាស់នូវសំឡេងសត្វថាសំឡេងនេះល្អនឹងមិនល្អ, ២ – ដឹងច្បាស់នូវកំណើតភ្នំ នឹងដើមឈើ, ៣ – ចេះដឹងនូវគណិតសាស្ត្រ, ៤ – ដឹងកិច្ចការរបស់ជាងដែល

ជាធនូប្រគប, ៥-ដឹងសិល្បសាស្ត្ររបស់ស្តេច, ៦- ដឹងច្បាប់ គម្ពីរ ទឹងការចិញ្ចឹមរក្សាប្រជាជនឲ្យមានសេរីសួស្តី ៧- ដឹងកប់ ឧក្កតុក្ស ទីជម្រាក្ខៈយ, ៨-ដឹងក្បួនពេទ្យ, ៩ - ដឹងសិល្ប ទឹងរៀផ្លាបាញ់, ១០ - ដឹងថាស៊ីបរទេសនោះជាមង្គល, ១១- ដឹងខ្សែគម្ពីរពាក្យការណ៍រាស្ត្រ ១២ - ដឹងថាវត្ថុនេះជាកែវមណី- ជាមាសទឹងជាពេជ្រ, ១៣ - ដឹងហេតុដែលបណ្ដាលកើត ទឹងផល ដែលចំរើនឡើងពីហេតុនោះ, ១៤ - ដឹងវិចិត្តពីមគោក្របី ទឹង ជាំពូជពុះកន្សែរស្រូវបានផល, ១៥ - ចេះខ្សែក្បួនជ័យសង្គ្រាម, ១៦ ដឹងខ្សែគម្ពីរលោកវោហារ, ១៧ - ដឹងខ្សែគម្ពីរចំនួនវេយ្យមាត កាទឹងកាព្យឃ្លោងផ្សេងៗ, ១៨- ដឹងថាស្រុកនេះជាដំបន់ចាស់ ទឹងស្រុកចាស់ ៗ

៣៣— បុគ្គលក្នុងលោកសព្វថ្ងៃនេះ គប្បីរៀនយក ច្បាប់៣ប្រការៈទៀត គឺជាច្បាប់សម្រាប់វត្តមានវត្តធម្មញ្ញ

ក្រមព្រហ្មទ័ណ្ឌ ច្បាប់ប្រដៅខ្លួន នឹងច្បាប់ធម៌ សម្រាប់ប្រតិ-បត្តិ ដើម្បីសេចក្ដីសុខក្សេមក្សាន្ត ។

៣៤– រូបគំនូរ ដែលគេគូរទុកឲ្យដឹកនាំជនថ្មី មិនឃ្លាតក្លាយទៅជាបការៈដ៏វែងយ៉ាងណា ទតវិជ្ជាដែលគេបង្ហិកបង្ហាត់ដល់កូនក្មេងទាំងឡាយ ដោយកថាជាគ្រឿងប្រៀបធៀប ក៏ជាប់នៅយ៉ាងនោះដែរ ។

៣៥– មានប្រយោជន៍អ្វី ចំពោះកូនដែលកើតហើយល្ងង់ផង មិនប្រកបដោយធម៌ផង? ដូចផ្លែឈើមានប្រយោជន៍អ្វី? បានត្រឹមតែឈើ ចាក់ដោតនាំឲ្យរខានប៉ុណ្ណោះ ។

៣៦– បណ្ដាកូន៣ពួក គឺកូនមិនទាន់កើត១ពួក កូនកើតហើយស្លាប់ទៅវិញ១ពួក នឹងកូនល្ងង់១ពួក, កូនពីរពួកខាងដើម ជាកូនគាប់ប្រសើរ, ពួកកូនទី៣មិនប្រសើរឡើយ-ព្រោះថាកូនពីរពួកខាងដើម ធ្វើទុក្ខព្រួយតែម្ដងសប់ទៅហើយ ឯពួកក្រោយទៀត ធ្វើទុក្ខម្ដាតបិតាឲ្យលំបាកគ្រប់ជំហាន

ដើង ។

៣៧- ក្នុងពេលប្រាព្ធទឹងរៃសេក ឈ្មោះ នៃពួកអ្នក មានគុណបុះក្នុងបញ្ជីឬផែនថ (ឬដាក់ទាមវិថី-ទីងសាលា រៀនផ្សេង ៗ ជារបស់សាធារណៈផង) ឈ្មោះអ្នកណាឥតមាន គុណ មិនញុំាងចិត្តគេឲ្យរំភើបព្រឺព្រួចទេ គេមិនចារិកឈ្មោះ អ្នកនោះឡើយ បើដូច្នោះ តើគួរទឹងហៅម្ដាយដែលបង្កើត កូននោះ ជាស្ត្រីកា ឬស្ត្រីអ៊ីហ៊ឺ ? ។

៣៨- កូនមានគុណគាប់តែម្នាក់ ជាកូនប្រសើរ កូនល្ងង់កប់រយមិនប្រសើរទេ ដូចព្រះចន្ទ្រតែមួយដួង អាចកំ-ចាត់ងងឹតអន្ធការបាន ។

៣៩- តបៈគឺការបំពេញកុសល ដែលបុគ្គលណាមួយធ្វើក្នុងទីស័ក្ដិសិទ្ធ ពុំនោះបំពេញទុក្ករកម្មដ៏ក្រៃលែងឯណានិមួយ ព្រោះប្រាថ្នាកូន កូននៃអ្នកនោះនឹងជាកូនប្រពៃឆាយ សមបុគ្គិសម្រេចប្រយោជន៍ ប្រកបដោយធម៌ ទីងមាន

ប្រាជ្ញាបរិបូណ៌ ។

៤០- អ្នកណាកើតហើយដឹកនាំត្រកូលឲ្យចំរើនខ្ពង់ខ្ពស់ឡើង អ្នកនោះទើបឈ្មោះថា "កើត" មែនទែន ឬពេញជាកើតត្រឹមត្រូវ ព្រោះសំសារវដ្តដែលប្រព្រឹត្តទៅនេះ អ្នកណាមួយដែលស្លាប់ទៅហើយមិនត្រឡប់កើតទៀត ។

៤១- គួរនឹងពន់អ្នកមានកូនច្រើន ថាគាត់ប្រសើរឬទេ? បើកូនទាំងនោះ ទុកដូចជានាឲ្យទទេក្នុងជ្រូក កូនតែម្នាក់ជាវីរជនដែលគាំទ្រកំរើកត្រកូលល្អជាជាង កេរ្តិ៍ឈ្មោះបិតាក៏ល្បីល្បាញខ្ទរខ្ទាយទៅកាន់ទិសានុទិស ។

៤២- មាតាធ្វើបំណុលទុកឲ្យកូនជាសត្រូវ, មាតាប្រព្រឹត្តចរិតខុសគន្លងប្រវេណីជាសត្រូវ, ភរិយាមានរូបល្អជាសត្រូវ ឯកូនល្ងង់ក៏ជាសត្រូវ ។

៤៣- នរជនសូម្បីកើតចេញពីត្រកូលណាក៏ដោយ តែមានគុណគាប់ប្រសើរហើយ លោកក៏គួរគោរពបូជា, ឬ

សម្បីរបស់បុទ្ធះដាយដៃរៀ តែមិនបានប្រសិទ្ធិ មិនឡើងកើត ?

៤៤ - ឱ កូនតូចកំសត់អើយ ! អ្នកមិនទាន់បានរៀនសូត្រ នោះ ពត្រីភិនវ្យាយៈចះតែប្រព្រឹត្តកន្ទុងទៅ ។ បើដូច្នោះ ខ្លួនអ្នកនឹងកប់បាត់នៅកណ្តាលហ្វូងអ្នកប្រាជ្ញពាំងវ្យាយ ដូច ជាៈគាលធំទ្រនេស ជាប់ក្នុងកណ្តាលបឹងភក់ ។

៤៥– ការធម៌ នៃបុគ្គលមានការធម៌ តែងកើតមាន ផលការនៃបុគ្គលជាទីពេញចិត្ត, ការៈអាក្រក់តែងមានផល ព្រះភ័ស្ទូរ គិឃារដកៈលើតសំដី តែងមានផលព្រះហារ ។

+ ៤៦ – កូនក្មេង ដែលមាតាបិតាណា មិនបានឲ្យរៀន សូត្រ មាតានោះត្រូវជាសត្រូវ បិតាត្រូវជាបុគ្គលមាន ពៀរ ព្រោះកូនមិនបានរៀនក្នុងទីប្រជុំជន ដូចកុកនៅ កណ្តាលហ្វូងហង្ស ។

+ ៤៧– កូនក្មេង ដែលមាតាបិតាបានហ្វឹកហ្វឺនហើយទៅ ជាកូនមានគុណតាប់ប្រសើរបាន មិនដែលមានកូនក្មេងណា

ទៅជាបណ្ឌិត ដោយគ្រាន់តែច្បិតចេញពីគភ៌មាតាទេ ។

៤៨– មនុស្សល្ងង់ប្រដាប់ដោយគ្រឿងអម្ពរ តែង មានកសិរុងរឿង បើមនុស្សល្ងង់នោះ មិនទាន់ហាមាត់ចេញ និយាយដកបណា គឺនៅតែមានកសិរុងរឿងដរាបនោះ ។

៤៩– កញ្ចក់ដែលនៅរួមជាមួយនឹងមាស រាប់ពេល ស្រស់ម៉ោះក្លាយជាកែវមរកតយ៉ាងណា មនុស្សល្ងង់នៅរួមជាមួយនឹងលោកសប្បុរស ក៏អាចត្រឡប់ក្លាយទៅជាបុរសឆ្លៀវឆ្លាតបានយ៉ាងនោះដែរ ។

៥០– កូនគេ មិនតែជាកពាល ព្រោះសមាគមមួយអន្ទើដោយបុគ្គលជាកពាល, សមាគមមួយអន្ទើបុគ្គលស្មើគ្នា មិនតែ តែមិនតែស្មើគ្នា សមាគមមួយអន្ទើដោយបុគ្គលប្រសើរមិនតែ រើសតែប្រសើរទេ ។

៥១– អ្នកមានគុណគាប់ តែងដឹងល្អនឹងអាក្រក់, អ្នកមានគុណគាប់នោះ បើទៅសេពគប់មនុស្សអាក្រក់ ក៏ត្រឡប់

ទៅជាកក្រក់ ដូចស្ទឹងមានទឹកដ៏ហើយដោយរសជាតិល្អ លុះហូរចូលដល់សមុទ្រហើយ ក៏ក្លាយទៅជាមានរសជាតិប្រៃផឹកមិនបាន ។

៤២– មនុស្សល្ងង់ តែងដូចប្រទះប៉ះទង្គិច ហេតុដែលនាំឲ្យកើតសេចក្ដីសោកមួយពាន់ដងក្នុងមួយថ្ងៃៗ តែអ្នកប្រាជ្ញ ដូចប្រទះទង្គិចហេតុដូចនេះឥតអត្ថិមានឡើយ ។

៤៣– កាលក្រោកឡើងពីព្រលឹម នរជនគប្បីដាស់សតិរឭករាល់ៗថ្ងៃថា «មហាភ័យទាំងឡាយជិតមកដល់ហើយ បណ្ដាមហាភ័យទាំងឡាយនោះ ការឈឺចាប់សេចក្ដីស្លាប់និងសេចក្ដីទុក្ខសោក កើតភ័យឬអន្តរាយអ្វីមួយមុខជានឹងធ្លាក់ដល់អាត្មាអញក្នុងថ្ងៃនេះ» ។

៤៤– សិល្បសាស្ត្រវិជ្ជា តែងមិនមានដល់បុគ្គលអ្នកគ្មានសេចក្ដីព្យាយាម, សម្បត្តិទ្រព្យតែងមិនកើតចំរើនដល់បុគ្គលឥតសិល្បវិជ្ជា, មិត្រតែងមិនមានដល់បុគ្គលខ្សត់ទ្រព្យ

សេចក្ដីសុខនៃធម៌មិនមានដល់បុគ្គលអ្នកឥតមិត្រ, អំណាចនៃបុណ្យនៃធម៌មិនកើតមានដល់បុគ្គលឥតសុខ, ព្រះនិព្វាននៃធម៌មិនមានដល់បុគ្គលអ្នកមិនកសាងសន្សំបុណ្យ ។

៤៥– សិល្បសាស្ត្រវិជ្ជា ប្រសើរជាងបុគ្គលមានទ្រព្យ ព្រោះចោរមិនអាចលួចប្លន់បានផង តែងសម្បូណ៌ដោយមិត្រភក្តិផង បានសេចក្ដីសុខក្នុងលោកនេះ នឹងលោកខាងមុខផង ។

៤៦– បុគ្គលមិនគប្បីគិតថា ខ្លួនមានបញ្ញាតិច ហើយលះបង់ការរៀនសូត្រចោល ដោយខ្លាចភ្លេចមិនបានចំណេះទៅទៀត, ការខំស្ដាប់នឹងការខំរៀនបើបុគ្គលបំពេញយូរ ៗ ទៅ អាចពេញក្នុងខាងច័យបាន, ដូចក្អមទឹកទទេ បើបុគ្គលយកទៅដាក់កណ្ដាលទីវាល នឹងមិនពេញដោយដំណក់ទឹកដែលធ្លាក់ចុះរាល់ ១ ថ្ងៃ ៗ ។

៤៧ - ការរៀនសិល្បវិជ្ជា១ ការស្វែងរកទ្រព្យសម្បត្តិ១

ការរៀនទៅកាន់កំពូលភ្នំ១ ការសេពគាម១ បុគ្គលមិនគប្បីខំឲ្យហួសមាត្រាទេ គប្បីព្យាយាមតាមកម្លាំងនិងបញ្ញារបស់ខ្លួន ព្រោះថា ការខំប្រឹងឲ្យហួសមាត្រាជាឧបសគ្គខាងដើមមួយយ៉ាងធំ គប្បីធ្វើតាមដម្រាថា «សន្សំកុំបំពាល» ។

៥៨– សិល្បសាស្ត្រវិជ្ជា បើបុគ្គលរៀនហើយមិនចាំឬប្រាកដក្នុងហឫទ័យ ដោយប្រើការខំហួសមាត្រាពេក ក៏មិនអាចញ៉ាំងផលឲ្យកើតដល់បុគ្គលនោះបានដែរ, ដូចមានទ្រព្យសម្បត្តិហើយនៅក្នុងដៃជនដទៃទុកដាក់ដូច្នោះ ។

៥៩– បុគ្គលអាចកំណត់ដឹងនូវជម្រៅទឹក ដោយការប្រើវត្ថុវាស់វែង ការកំណត់ដឹងប្រមាណនូវបុគ្គលមានត្រកូលដោយការប្រព្រឹត្តតាមវិន័យ, ប្រមាណជនជាបណ្ឌិតដោយការប្រព្រឹត្តយោរយៅ, ប្រមាណបុគ្គលមានប្រាជ្ញាវាងវៃដោយការពោលពាក្យសត្យ, ប្រមាណដឹងនូវព្រះធរណីល្អឬមិនល្អ ដោយស្មៅដែលដុះក្នុងទីនោះ ។

៦០ - បុគ្គលល្ងង់អប្បឥតបញ្ញា តែងរៀនអំនួតអ្នកប្រាជ្ញខ្លួនដែលចេះតិចតួច មានមានះយ៉ាងធំដោយស្មានថា គេចេះមិនដល់ខ្លួន, ដូចជាកង្កែបដែលនៅក្នុងអណ្ដូងតែងសំគាល់ខ្លួនថាធំក្រៃលែង ។

៦១ - ភាពបន្លាដែលស្រួច ១ ភាពក្អែកខ្មៅរបស់សត្វម្រឹគ ១ ភាពខ្យល់មានក្លិនក្រអូប ១ ភាពកុសលបុត្រដែលប្រកបដោយរូបល្អ ១ វត្ថុទាំង៤ប្រការនេះតែងកើតមកតាមសភាពខ្លួនតាំងពីពន្លកចេញមកម្ល៉េះ គ្មាននរណាអាចតែងដាក់បានឡើយ ។

៦២ - កូន បុគ្គលមិនគប្បីថ្នាក់ថ្នមឡើយ [illegible] ព្រោះតែងប្រកបទោសច្រើនប្រការ គប្បីតែវាយរំលងឲ្យរាល់ពេល ទើបអាចក្លាយទៅជាកូនមានគុណគាប់បាន, ហេតុនេះបុគ្គលមិនគប្បីថ្នមកូននិងសិស្សពេកទេ ។

៦៣ - កូន បុគ្គលគប្បីថ្នាក់ថ្នម តែស្រីមានយុ[illegible]

ប៉ុណ្ណោះ តែដល់ឆ្នាំជាគំរប់១០ហើយ គប្បីឲ្យស្ដីតាមច្បាប់ផ្សេង ៗ កូនដែលបុគ្គលធ្វើបែបនេះហើយអ្នកប្រាជ្ញលោកហៅថា «កូនជាមិត្រ» ។

៦៤– ត្រកូលណា ប្រកបដោយកូនមានវិជ្ជានឹងគុណសម្បត្តិ ត្រកូលនោះតែងទទួលនូវលាភសេរីទាំងឡាយសព្វកាល, ដូចឈើដែលមានផ្កាក្រអូប សូម្បីតែមួយដើមក៏អាចធ្វើឲ្យក្លិនទៅសព្វព្រៃបាន ។

៦៥– ត្រកូលណា ប្រកបដោយកូនសុទ្ធតែល្ងង់ មិនមានវិជ្ជានឹងគុណសម្បត្តិ ត្រកូលនោះតែងទទួលនូវសេចក្ដីអន្តរាយនឹងការអាប់យសខ្មាសមុខ ដែលជាទោសកើតពីកូននោះសព្វកាល ដូចព្រៃឈើជាប់ភ្លើង កាលបើឆាបឆេះហើយ រមែងចំផ្លាញព្រៃទាំងអស់បានដែរ ។

៦៦– វិជ្ជាប្រសើរ ព្រោះធ្លាក់ទៅក្នុងដៃជនដោយពិបាក មិនមានទ្រព្យ នឹងបុណ្យស័ក្តិសម្បត្តិតូចតាច ក៏គួរគប្បីទៅសុំ

យកគ្រាន់តែបានដែរ ដូចជុំមាសៈតាះបុក្កាក់ទៅកប់វ៉ៃ ឈ្មោកក្រោក ក៏ត្រូវយើងគាស់ក៏កាយយកដែរ ។

៦៧- ភ្នែក ដែលធម្មជាតិបង្កើតមក សម្រាប់មើលសព្វសារពើការទាំងឡាយ បុគ្គលមិនអប្បន្តូចទេ បើភ្នែកដែលធម្មជាតិបង្កើតមកហើយនោះ មិនចាំរៀនសូត្រអក្សរ ទីនវិជ្ជាផ្សេងៗទេ ភ្នែកនៃបុគ្គលនោះអ្នកប្រាជ្ញលោកពោលជាថា "ភ្នែកខ្វាក់" ។

៦៨- ជាតិអ្នកប្រាជ្ញ តែងស្គាល់បញ្ញប់ទីងគម្ពីរជាទីពឹង ពាហនៈយានមានសម្រាប់ជាទីពឹង, ពាណិជ្ជករស្វែងទ្រព្យតែងមានយានជាទីពឹង, ជនពាលមានការប្រណាំងជាទីពឹង, កូនក្មេងតែងមានការយំទីទស្រែកជាទីពឹង ជនទាំងនេះពួក នេះបើរៀនរក្សជាទីពឹងហើយ ក៏មិនគាបពារ៉ាំងលន្ធៀបប្រយោជន៍បានដែរ ។

៦៩- ជនពាលពាល តែងពោលអួតទ្រព្យសម្បត្តិ, ជន

កាលស្ងាត់តែអ្នកគាំរៀផ្កាដែលមានបច្ចិបច្ចុក្នុងខ្លួន, សូម្បី
មិនមានគេសាកសួរ, ឯងនឹងអ្នកប្រាជ្ញវិញ មិនដែល
ពោលអួតអាងសោះ តែពេលណាមានអ្នកសួរក្នុងការណ៍ធ្ងន់
ទើបគាត់និយាយក្នុងពេលនោះ, ដូចជាស្គរធំបើមានគេវាយ
ទើបឮបន្លឺសំឡេង ។

៧០ - បុគ្គល គប្បីថែរក្សាកេរ្តិ៍ឈ្មោះវង្សត្រកូលខ្លួនឲ្យ
ល្អ, គប្បីថែរក្សាកេរ្តិ៍មត៌ករបស់លោកដែលចែកឲ្យ. គប្បី
ស្ដាប់ពាក្យទូន្មានជាផ្លូវច្បាប់របស់លោក, នឹងគប្បីទទួលយក
កិរិយាដែលលោកបានរៀបចំឲ្យ ។

៧១ - ពាក្យទូន្មានរបស់សមណៈ១ របស់ព្រះរាជា១
របស់មាតាបិតា១ នឹងច្បាប់របស់រដ្ឋ១ បុគ្គលគប្បីប្រុងប្រយ័ត្ន
រក្សាទុកឲ្យបានគង់វង់ ។

៧២ - កិរិយាហាមកូនមិនឲ្យធ្វើអំពើបាប១ ការដំកល់
កូនឲ្យនៅក្នុងកុសលធម៌១ ការបង្ខំឲ្យកូនរៀនសូត្រតាមកាល

សម័យ១ ការរៀបចំគូទឲ្យមានភរិយាសមតាមឋានៈ១ និង ប្រគល់កេរ្តិ៍មត៌កឲ្យតាមសម័យគួរ១ តាំង ៥ នេះហៅថា សង្គហធម៌របស់មាតាបិតា ។

៣៣– ការចិញ្ចឹមមាតាបិតា១ ការជួយធ្វើកិច្ចការរបស់មាតាបិតា១ ប្រព្រឹត្តល្អតាមវង្សត្រកូល ១ ចូលទៅជិតបំរើដោយចិត្តស្ម័គ្រ១ និងធ្វើបុណ្យជូនទៅលោកដែលស្លាប់បាត់បង់ទៅហើយ១ តាំង៥នេះហៅថា សង្គហធម៌របស់កូន ។

៣៤– បុគ្គលគប្បីធ្វើពលិកម្ម៥យ៉ាងទៀតគឺៈ ជួយទំនុកបំរុងញាតិ១ ធ្វើកុសលបានជូនទៅញាតិដែលស្លាប់ទៅ១, ជួយព្រះរាជាដោយការបង់ពន្ធដារ១ បូជាដល់ទេវតាដែលថែរក្សាយើង១ ។

៣៥– បុគ្គលគប្បីធ្វើបដិសណ្ឋារៈទទួលភ្ញៀវ ដែលមកដល់ផ្ទះហើយ ទោះបីភ្ញៀវដែលជាសត្រូវក៏ដោយ, ដូចព្រឹក្សជាតិតែងឲ្យម្លប់ជាទីសំចតមិនរើសមុខ សូម្បីអ្នកកាប់

ផើ ។

៧៦– បើទុកជាខ្សត់ខ្សោយទ្រព្យណាស់ មិនមានការទទួលភ្ញៀវដែលមកដល់ ដោយយោបល់ ក៏គួរពេញ អាទរកក់ក្ដៅចំពោះភ្ញៀវ ដោយសំដីពីរោះជាទីត្រេកអរ ។

៧៧– ស្លោ (ឬចំពើន-ទន្ទះស៊ប្រាប់អុបបំភ្លឺ)១, ភូមិទីលំនៅ១, ទឹកទិនសំដីពីរោះផ្អែមល្ហែម១ ជាម៉ង់ប្រការនេះ ក្នុងកាលណាក៏ដោយ មិនដែលខ្វះខាតលើបរលាប ក្នុងផ្ទះលោកអ្នកសប្បុរសទាំងឡាយទេ ។

៧៨– លោកអ្នកសប្បុរសទាំងឡាយ តែងបំផែន មេត្តាករុណាចំពោះសព្វសត្វទាំងឡាយមិនរើសមុខ, សូម្បីបុគ្គលចោរកបាបក៏ដោយ ដូចជាព្រះចន្ទ្រ ទិនថាកំណាញ់ពន្លឺ មិនឲ្យដល់ទីលំនៅនៃចណ្ឌាលក៏ឥតអន្លំមានឡើយ ។

៧៩– ពោះក្មេងតូច ឬកំលោះក្រមុំ ក៏ពុំនោះជាសព្វព្រឹទ្ធាចារ្យក៏ដោយ ដែលជាភ្ញៀវមកដល់ផ្ទះហើយ បុគ្គលសប្បុ

រៀបចំគ្រឿងសក្ការៈបូជាកប់ភានដល់ជនតាំងនោះ ព្រោះអ្នកតាំងនោះដែលមកដល់ផ្ទះហើយ លោកទុកជាបុគ្គលខ្ពង់ខ្ពស់ជាងគេផង ជាគ្រូផង ។

៨០– សូមសាធុជនទាំងឡាយ បានប្រកបដោយនីតិវិជ្ជា នឹងសុជីវធម៌ផ្សេង ៗ គ្នា, សូមទៅតាមទម្លាប់ទាំងឡាយ បីបាច់តែគេក្នុងប្រជាជន, សូមព្រះករុណាបម្រុងប្រុះនៅក្នុងឲ្យបានភាពកាលទីនេះដៅ. សូមប្រជាជនទាំងឡាយកុំជក-យាតនឹងគ្នា, សូមសុខចិត្តនៅតែមានដល់សាធុសប្បុរសទាំងឡាយគ្រប់ ៗ គ្នាសព្វកាលជានិច្ច ។

# ឥត្ថីវគ្គ

១– ពន្លឺត្រជាក់នៃព្រះចន្ទ មិនជាទីពេញចិត្តនៃមនុស្សរងា, ពន្លឺក្តៅនៃព្រះអាទិត្យ មិនជាទីពេញចិត្តដល់មនុស្សក្តៅក្រហាយ, ប្តីចាស់ជរាគ្រាំគ្រាគគ្រេកគគ្រក មិនជាទីពេញចិត្តនៃភរិយាក្មេង ៗ

២– បើប្តីចាស់មើលទៅឃើញសក់ស្កូវស្រពោនហើយ ឲ្យភរិយាក្មេងប្រាថ្នាកាមភាគដូចម្តេចកើត? ភរិយាណាមានចិត្តប្រគល់ឲ្យទៅប្រុសដទៃទៀតហើយ ភរិយានោះ ទុកប្តីដូចជាថ្នាំកែរោគ ៗ

៣– សេចក្តីប្រាថ្នាចង់បានទ្រព្យសម្បត្តិ, សេចក្តី

ប្រាថ្នាចង់ឲ្យមានអាយុយឺនយូរ ជាធម៌តែងមានទូទៅក្នុងចិត្តនៃ សព្វសត្វទាំងឡាយ, ឯកិរិយាក្នុងរូបកាយរបស់ឥតពោះ គ្រប់ណា ជាធម៌ធ្ងន់គណ្ដកជាប់ចិត្តដ៏ក្រៃលែង នៃបុគ្គលចាស់ជរា ជាងជីវិតទៅទៀត ។

៦– មនុស្សចាស់ជរាលះក្នុងវិស័យនៃកាម ទឹង បរិភោគកាមក៏មិនកើត ឬ ទឹងលះបង់ពេលកាមក៏មិនកើត ទៀត ដូចសត្វសុនខដែលបាក់ចង្កូមហើយ គ្រាន់តែបាន អង្គៀមយកអណ្ដាតលិទ្ធឆ្អឹងតែប៉ុណ្ណោះ ។

៧– កិរិយាប្រព្រឹត្តតាមចំនេញចិត្ត; កិរិយានៅក្នុងផ្ទះ នៃបិតា កិរិយាចូលចិត្តមើលមហោស្រព កិរិយាចូលចិត្ត សេពគប់និយាយច្រើនទឹងញាតិ កិរិយាចូលចិត្តអង្គុយជិត បុរស កិរិយានៅបរទេស សមាគមញយទៈជាដស្រ្តីធាមាស វិនាសទ្រព្យសម្បត្តិព្រោះតាយកាយឥតសណ្ដាប់ធ្នាប់ ស្វាមី ចាស់ជរាប្រច័ណ្ឌឬស្ងប់ ទឹងស្វាមីធ្វើដំណើរទៅប្រទេសក្រៅ

ទាំងអស់នេះ ជាហេតុនាំឲ្យភរិយាក្បត់ចិត្ត ។

៦- កិរិយាផឹកទឹកស្រវឹង១ កិរិយាទៅច្រឡំបល់ដោយមនុស្សអាក្រក់១ កិរិយានៅស្ងាត់ពីស្វាមី១ កិរិយាដើរលេង១ កិរិយាដេកនៅក្នុងផ្ទះអ្នកដទៃ១ កិរិយានៅឆ្ងាយពីស្វាមី១ ទោស៦ប្រការនេះជាគ្រឿងប្រទូស្តនៃស្ត្រីទាំងឡាយ ។

៧- បុរសមិនគួរអង្គុយក្នុងទីស្ងាត់ជាមួយមាតា, បងស្រី ឬកូនក្រមុំខ្លួន, តាមនេះបើនៅរួមគ្នាក្នុងទីស្ងាត់ មានកម្លាំងគ្រឿងក្លាណាស់ សូម្បីអ្នកប្រាជ្ញក៏ធក់ឈ្លប់ងងឹតមុខទប់មិនបាន

៨. ទឹងជាបុរសណា ស្ត្រីមិនស្រឡាញ់ក៏មិនមែន ទឹងជាបុរសណាស្ត្រីស្រឡាញ់ក៏មិនមែនទៀត, ដោយពិត, ស្ត្រីកាលដូចៈគោដើរស្វែងរកស្មៅជាអាហារក្នុងព្រៃ តែងប្រាថ្នានូវស្មៅថ្មី ៗ ជានិច្ចរហូតតទៅ ។

៩- ធម្មជាតិជាស្ត្រី ទឹងជាអៀនខ្មាស់ក៏មិនមែន ទឹងជាមានខ្លួនខ្មាន:ហើយក៏មិនមែន ទឹងជាមានចិត្តស្មោះត្រង់បំ

ពោះប្តីក៏មិនមែន ពុំនោះជាមានសេចក្តីភ័យខ្លាចក៏មិនមែនដែរ, សេចក្តីពិត, គឺមិនមានបុរសចង់ នេះជាហេតុនៃសេចក្តីស្មោះត្រង់ (បរិសុទ្ធ) នៃស្ត្រីទាំងឡាយ ។

១០- នារីបីដូចជាឆ្នាំងខ្លាញ់ បុរសបីដូចជាភ្លើង, ហេតុនោះបានជាអ្នកប្រាជ្ញ លោកមិនដំកល់ទុកឆ្នាំងខ្លាញ់ នឹងភ្លើងក្នុងទីជិតគ្នាទេ ។

១១- តាបសទុសនា (តាបសជាគ្រូពួកអសុរ) នឹងព្រះព្រហស្បតិលោកៈចេះដឹងនូវកលមាយាសាស្ត្រឯណា កលមាយាសាស្ត្រនោះប្រតិស្ឋានស្រេចហើយ ក្នុងប្រាជ្ញានៃស្ត្រីភាព តាមសភាពតាំងតែពីកំណើតមកស្រាប់ ។

១២- ភ្លើងតែងមិនឆ្អែតដោយ អង្កត់ឧសទាំងឡាយ, មហាសមុទ្រ តែងមិនឆ្អែតដោយទឹកស្ទឹងនឹងទន្លេទាំងឡាយ ម្រិត្យុតែងមិនឆ្អែតដោយសព្វសត្វទាំងឡាយ ឯស្ត្រីមានរូបល្អ តែងមិនឆ្អែតដោយប្រុសទាំងឡាយ ។

១៣- ស្ត្រីដែលៈឈ្មោះថាមានចិត្តបរិសុទ្ធនោះ ដោយសារតែមិនមានកន្លែងស្ងាត់ មិនមានឱកាស១ស្របកន់និងមិនមានបុរសមកចង់ប្រាថ្នាខ្លួនប៉ុណ្ណោះ ។

១៤- ដោយការ(ស្លូត)ឲ្យស្រៀមក៏មិនបាន ដោយការយកចិត្តក៏មិនបាន ដោយការប្រើកំហែងក៏មិនបានឬដោយការប្រើប្រាជ្ញាបរិយាយផ្ចាប់ក៏មិនបានទៀត ដោយពិត, ស្ត្រីភាពគឺគេខ្ទប់មិនងាយបានដោយប្រការទាំងពួង ។

១៥- ស្ត្រីភាពចិត្តដាច់ណាស់ អាចលះបង់ប្តីដែលមានគុណដ៏ប្រសើរ មានកិត្តិយស មានរូបល្អជាទីពេញចិត្ត ធ្លាក់ក្នុងកាមវិធី មានទ្រព្យសម្បត្តិច្រើន ឬនៅក្មេងស្រស់ស្រឡាង ពេលក្រមុំមមៈបរពេច ហើយរត់ទៅរើសយកប្រុសគំរក់គាមថុល់ដែលឥតគុណទីងចរិយា ។

១៦- ពិតប្រាកដណាស់ ។ នារីសូម្បីជេរលើខែនសម្ដីនារីបងដែល រិះគន់ប្រណិតគួរជាទីមនោរម្យ ក៏

មិនគាប់ចិត្តស្និតស្នើដោយត្រើតត្រើនរមួររមើយដោយប្រសព្វគេ ជាគូស្នេហាថ្មីថ្មីបុកម្ដងយកដែនដីជាគ្រែ ក្រាលដោយស្មៅក្រៀមក្រស់ជាកន្ទេល ។

១៧- បុគ្គលគប្បីជ្រាបថា ស្ត្រីបរិភោគអាហារទ្វេគុណ, មានប្រាជ្ញាចតុគុណ, មានកលមាយាឆគុណ និងបរិភោគកាមអដ្ឋគុណ ។

១៨- ក្នុងលោកនេះ ដោយច្រើន, នរណាមួយដែលមិនក្រឡេកមើលដោយសាទរចំពោះប្រពន្ធគេ ដែលមានរូបល្អគួរជាទីពេញចិត្តនៃជនដទៃដកប តែលួចពិនិត្យមើលចរិយាសាស្ត្រ, ដូចជាបុរសណាដែលមិនចង់បានទ្រព្យ បុរសនោះមិនមានទៅក្នុងលោកនេះទេ សូម្បីទ្រព្យនោះប្រកបដោយទោសក៏ដោយ ។

១៩- តាមធម្មតា ស្ត្រីភាព ព្រះរាជាឬលតាជាតិ តែងពាក់ព័ន្ធចំពោះតែអ្នកណាឬដើមឈើណាដែលនៅ

ជិត ៗ ទោះជាមនុស្សប្រាកដពាលក្ដី មនុស្សល្ងង់ខ្លៅក្ដី ឬក៏ មិនបានទន្ទានខ្វិនដោយល្អក្ដី ។

២០- ស្ត្រីភាពពិតណាស់ ក្នុងពេលដែលបានក្បត់ ចិត្តប្ដីហើយ ក្នុងសំដីសុទ្ធតែទឹកឃ្មុំ តែក្នុងចិត្តសុទ្ធតែពិស ពុល បើតាំមោតទទឹកដោយពិសពុលហើយ ចិត្តគុះពោរ ដោយសេចក្ដីទុក្ខក្ដៅក្រហាយ ។

២១- ការទុកចិត្តក្នុងស្ត្រីទាំងឡាយ ១ ការប្រ- ណាំងប្រជែងតស៊ូអ្នកមានកម្លាំងជាងខ្លួន ១ ការតាំងខ្លួន វៀនគំនិតខឹងបងប្អូនឯង ១ ការប្រាថ្នាធ្វើការងារដែលមិនគួរធ្វើ ១ ទាំង ៤ ប្រការនេះឈ្មោះថាបើកទ្វារឲ្យផលច្រើនក្ស ទាំងអស់ ។

២១- ដោយច្រើន នារីទាំងឡាយ តែងចូលចិត្តសេពគប់ខ្ជិល, ព្រោះពាក្យតែងគាប់ព្រះទ័យ ទីងអាមាត្យគ្មានគុណសម្បត្តិ, ទ្រព្យសម្បត្តិតែងហូរទៅរកតែជនកំណាញ់ ឯក្មេង

តែងហូរចុះតែលើក្ខុំទឹកធំមហាសមុទ្រ ។

៦២– ភរិយាចិត្តអាក្រក់សាមាន្យ, មិត្រជាសត្រូវ, អ្នកបំរើព្រហើនពោលពាក្យតប ទីធំមិនធ្វើតាមអណ្យានៃព្រះនរេន្ទ្រ ទាំងអស់នេះលោកពោលទុកថា សុទ្ធតែនាំមកនូវប្រមិត្យផត សន្ស្រយទៀយ ។

៦៣– មិនមានសច្ចៈ ចិត្តពោស, មាយា, ឥច្ឆា, លោភ ក្រោធ, មិនមានគុណសម្បត្តិ ទីណាមកទាំងអស់នេះជាទោសនៃស្ត្រីកើតភាសភាពឯង ។

៦៤– ស្ត្រីចូលចិត្តការអន្ទិល ប្រហែលជ្រកស្រកមកដល់ ក្របីចូលចិត្តផុតមន្ទិល ស្ត្រីខូចចិលនឹងកាមា ។

(ចាកកាសិកប្លកៈណ)

៦៥– ការយកស្ត្រីផ្កាមាសជាភរិយាប្រសើរ, ការយកស្ត្រីមានត្រកូល ដែលប្រព្រឹត្តកន្ទបវេណីមិនប្រាសើរទៀយ; ការនៅក្នុងខ្មួតបរសាសៈសួនប្រើបារ, ការៈនៅក្នុងផ្ទះភស្សរៈ

ជនកាចកម្រោលមិនប្រសើរឡើយ, ការនៅក្នុងព្រៃប្រសើរ, ការនៅក្នុងបុរី ដែលមានមន្ត្រីនិងស្តេចអយុត្តិធម៌មិនប្រសើរឡើយ, ការបរិច្ចាគជីវិតប្រសើរការសេពគប់ទុជ្ជនមិនប្រសើរឡើយ, ។

៤៦– ស្ត្រីភាពដែលអត់ឃ្លានហើយ សូម្បីកូនខ្លួនឯងក៏អាចលះបង់ចោលដែរ, ពស់ដែលអត់ឃ្លានហើយ សូម្បីពងឯងក៏ស៊ី, នរណាហ្ន៎ ដែលជួបប្រទះនឹងសេចក្តីអត់ឃ្លានហើយមិនធ្វើបាប ? ។

៤៧– កិរិយាមិនពត់កាយ១ កិរិយាបន្ទន់បន្ទាបកាយ១ កែក្រោយ១ ការសន្ទីងឬសំដីលកាយ១ ផ្ចាក់ក្របកនឹងក្របក១ ទាំង៩ប្រការនេះជាកលមាយាសាស្ត្រនៃស្ត្រីទាំងឡាយ ក្នុងកាលឃើញប្រុសប្ហុកមុរជាទីពេញចិត្តដែលកើតពីសភាពឯង

៤៨– ជាន់ជើងដោយខ្លួនឯង១ គូសវាសដីដោយកំ-ណាត់ឈើ១ ការបញ្ចោបនូវទារក១ ប្រឡែងលេងនឹងទារក១

បន្ថាប់ពាក្យឲ្យលេង១ ទាំង៩ យ៉ាងនេះជាកលមាយាសាស្ត្រ នៃស្ត្រីទាំងឡាយ ។

២៩– ធ្វើបទូរពាក្យ១ ញ៉ាំងពាក្យឲ្យជាប់វិញ១ បរិភោគ១ ញ៉ាំងពាក្យឲ្យបរិភោគ១ បរិភោគ:ឧឯងវិញ១ ទាំង៥នេះជាកលមាយាសាស្ត្រនៃស្ត្រីទាំងឡាយ ។

៣០– សូមពីពាក្យមកវិញ១ ការក្ដោបតាម១ និយាយដដែលៗខ្លាំងៗ១ និយាយតិចៗ១ និយាយច្បាស់ៗ១ ទាំង៥នេះជាកលមាយាសាស្ត្រនៃស្ត្រីទាំងឡាយ ។

៣១– និយាយខ្សឹបៗ១ កាច់ច្រៀនជើងៗ ទីងស្អិតស្អាងកាយ១ ញាក់បង្កេះ១ អង្រួនសំពត់គ្រងគុយក្នា១ លាក់ក្ដៅ១ ទាំង៥នេះជាកលមាយាសាស្ត្រនៃស្ត្រីទាំងឡាយ ។

៣២– បង់ក្ដៅវិញ១ បញ្ចេញដោះ១ បង្ហាញក្លៀក១ បញ្ចេញផ្ចិត១ បប្រិចភ្នែក១ ញាក់ចិញ្ចើម១ ទាំង៦ប្រការ

នេះជាកលមាយាសាស្ត្រ ។

៣៣– បុញ្ញបបូរមាត់១ លៀនអណ្ដាត១ ក្រាយសំពត់១ សៀកសំពត់១ រសាបសក់១ ទាំង៥នេះជាកលនៃមាយាសាស្ត្រ ។

៣៤– បង់សក់១ ផែនផន១ ការធ្វើដំណើរល្វាសល្វន់ខ្ទះខ្ទៀន១ ទាំង៤នេះជាកលមាយានៃស្ត្រីទាំងឡាយដែលស្ថិតនៅតាំងតែពីដើមក្ដីមក ។

៣៥– នារីដែលមានប្ដីពីរបីដង១ កិត្តិសព្ទនៅតែច្រើន១ បក្សីត្រាប់ជាប់ជន់ញយ១ ជនទាំង៣ពួកនេះប្រកបដោយមាយាច្រើន ។

៣៦– ស្ត្រីណាធ្មៀរទាសប្រុសព្រៀនវៃ កូនការផ្ទះ ស្ត្រីនោះជាភរិយាមែនទែន, ស្ត្រីណាសាយកូន ស្ត្រីនោះជាភរិយាមែនទែន ស្ត្រីណាប្រគល់ចិត្តខ្លួនឲ្យស្វាមី ស្ត្រីនោះជាភរិយាមែនទែន ស្ត្រីណាស្មោះត្រង់ចំពោះស្វាមី ស្ត្រីនោះជាភរិ

យាមែនទែន ។

៣៧– នារីណា មិនធ្វើឲ្យភស្តាខ្លួនកើតការសប្បាយ នារីនោះបុគ្គលមិនគប្បីហៅថាភរិយាទេ, បើភស្តាពេញចិត្តនឹងនារីណាជាភរិយាហើយ សូម្បីពពួកទេវតាក៏ជួយរក្សាដែរ ។

៣៨– នារីណា ប្តីជេរប្រទេចក្តី ឬ សំឡុតសំឡឹង ដោយក្តីក្រោធក្តី នៅតែធ្វើទឹកមុខស្រស់ស្រាយញញឹម នារីនោះទើបឈ្មោះថាជាស្ត្រីគ្រប់លក្ខណ៍ ។

៣៩– ស្ត្រីណាស្រឡាញ់ប្តីទោះបីនៅក្នុងក្រុងឬស្រែចំការ ក្តី ទោះជាប្តីមានបុណ្យស័ក្តិ ឬគ្មានបុណ្យស័ក្តិ ស្ត្រីនោះទើបលោកតាំងទុកឲ្យសេចក្តីសុខ ។

៤០ – លោមជាតិដែលឋិតនៅលើរូបនារីមានចំនួន៣៥ កោដិ នារីដែលប្តូរជីវិតស្លាប់នឹងប្តី ហ៊ានទៅកើតក្នុងស្ថានសួគ៌ក៏ មានចំនួនច្រើនដូចលោមជាតិដែរ ។

៤១– កាលម្តាយ ចាប់ពស់ពាញចេញពីរូងបានយ៉ាង

ណា កិរិយាដែលស្លាប់ទៅតាមភស្តាខ្លួន អាចនាំភស្តាខ្លួន (ពីនរក) ទៅកាន់ស្ថានសួគ៌បានក៏យ៉ាងនោះដែរ ។

៤២– នារីណា ស្រឡាញ់ប្តី កៀកទបប្តីស្លាប់ជាប់ ទីងខ្លួនលះបង់ខ្លួនចូលក្នុងគំនរភ្លើងដើងថ្ករជាមួយប្តី នាងនារីនោះសូម្បីធ្វើបាបកប់ភាំងសែនឆ្នាំ ក៏អាចនាំភស្តាខ្លួនទៅកាន់សុរលោកបាន ។

៤៣– បិតា ឬ បងប្រុស ដែលបានទទួលបង្គាប់ពីបិតា ហើយបានឲ្យនាងនារីទៅជាភរិយានរជនណាហើយ នាងនារីត្រូវស្តាប់បង្គាប់ប្តីនោះមិនត្រូវក្បត់ចិត្ត ទោះនៅទីកបាំងមុខក៏ដោយ ។

៤៤– សេចក្តីពិត, ភស្តាជាគ្រឿងអលង្ការនៃនារីទាំងឡាយ នារីឥតភស្តា បើទុកជាមានរូបល្អ ក៏មិនឈ្មោះថាមានរូបល្អដែរ ។

៤៥ – ស្ត្រីចេះធ្វើត្រូវប្រតិបត្តិប្តីមិនឲ្យអាក់អន់ចិត្ត មិន

ប្រមាថមើលងាយប្តី ដែលខុសស្មើដោយសតិសា ទោះប្តីនោះ មានរូបពិការ ឬ មានវង្សនិងទ្រព្យតិចជាង មានសំដីពីរោះគួរឲ្យញាក់ចូលចិត្ត ស្ត្រីនោះជាភរិយាមែនទែន, ហើយនឹងគេចទៀងទៅកាន់ស្ថានសួគ៌ឋានយ៉ាងងាយ ។

៤៦- នារីណា ឃើញប្រុសដទៃសើចសំឡក់សំឡៀង សំដែងមាយា និយាយបញ្ចុកបញ្ចៀងដោយពាក្យលែបខាយ ចូលចិត្តអង្គុយលាយឡំនឹងប្រុសដទៃ នឹងវិលប្រសូក្ន កិច្ចការផ្ទះ ស្ត្រីនោះ លោកតាំងមូលមិនហៅថាភរិយាទេ ។

៤៧- នារីណា ដើរត្រសូវដោយសំពត់កប ៗ, ជាន់លើផ្ទះឮខ្ទាំង ៗ , ចេញចូលបន្ទប់ដេកមិនបានបិទឲ្យជិត , និយាយឬសើចក្ទុះពីរប៉ើ, ពេលដេកបែរខ្នងឲ្យប្តី, កាន់ក្បាលប្តីកកៃមិនបានសុំទោសនឹងដើរកន្ទង់ជើងប្តី, នារីនោះប៉ះតាមច្បាប់ស្ត្រីបុរាណលោកថា ជាស្ត្រីចបច្រពចប្រែ បុគ្គលមិនគប្បីទៅបៀតបៀនទេ ។

៤៨– ស្ត្រីណាចូលចិត្តបង្កវិវាទជាទោស, ជាអ្នកប្រកាន់ពូជពង្សជាស្ត្រីមានអំនួត, ជាស្ទុះឆ្វាយ, មិនស្ដាប់បង្គាប់, ជាស្ត្រីសំដែងមាយាកលពេលឃើញប្រុសពេញចិត្ត, បះពោតបាយមុនប្ដី, ចូលចិត្តដើរផ្ទះគេ សូម្បីគេមិនហៅក, ស្ត្រីនោះលោកហៅជាស្ត្រីហីនលក្សណ៍,

៤៩– បុគ្គលគប្បីជ្រាបថា ភរិយាមាន ៧ ពួកៈនៅក្នុងលោកនេះ គឺវធកាភរិយា ១ ចោរីសមាភរិយា ១ អយ្យាស.មាភរិយា ១ មាតាសមាភរិយា ១ ភគិនីសមាភរិយា ១ សហាយាសមាភរិយា ១ ទាសីសមាភរិយា ១ ។

៥០– ភរិយា ៣ ពួកខាងដើមគឺ វធកាភរិយា ១ ចោរីសមាភរិយា ១ អយ្យាសមាភរិយា ១ ទេវតាព្រមទាំងមនុស្សទាំងឡាយតែងនិន្ទានឹងមិនពេញចិត្ត ។ ឯភរិយា ៤ ពួកខាងចុងគឺ មាតាសមាភរិយា ១ ភគិនីសមាភរិយា ១ សហាយាសមាភរិយា ១ ទាសីសមាភរិយា ១ តែងជាទី

ពេញចិត្តលើមនុស្សដទៃទៀតទាំងឡាយ ទើបបានទៅកើត
ក្នុងស្ថានសួគ៌សោយសុខសម្បត្តិយ៉ាងសប្បាយ ។

៥១ – ភរិយាណា ដែលប្រគល់ចិត្តឲ្យទៅប្រុសដទៃ
មិនមែនស្វាមី មិនមានចិត្តសន្តោស តែងធ្វើនូវអំពើឥតប្រ
យោជន៍ដល់ស្វាមី រកឧបាយដើម្បីក្បត់ ទើបធ្វើឃាតដល់ស្វា-
មីភរិយានោះ លោកហៅថា វធកាសមាភរិយា ។

៥២ – ភរិយាណា មានលោភចិត្តប្រព្រឹត្តឥទ្ធាចារៈ
លបលួចទ្រព្យសម្បត្តិ របស់ស្វាមីចាយវាយមិនមានសណ្ដាប់
ធ្នាប់ ប្រព្រឹត្តល្បែងភ្នាល់ ចាយវាយខ្ជះខ្ជាយតាមអំពើចិត្តខ្លួន
ភរិយានោះលោកហៅថា ចោរីសមាភរិយា ។

៥៣ – ភរិយាណា ខ្ជិលច្រអូស មិនប្រកបកិច្ចការក្នុងផ្ទះ
ចិត្តសាហាវឃោរជាតិ ពោលពាក្យអាក្រក់ ជេរស្វាមីខ្លួន មិនរ
វល់ស្ដាប់បង្គាប់ស្វាមី ភរិយានោះហៅថា អយ្យសមាភរិយា

៥៤ – ភរិយាណា មានហិតានុគ្គហៈករុណាសន្តាន មាន-

ការគោរពប្រតិបត្តិកោតក្រែង ចំពោះស្វាមីខ្លួន, ដូចប្អូនស្ត្រី ដែលកោតខ្លាចគោរពបងប្រុស ភរិយានោះ ហៅថាភគនីសមាភរិយា ។

៤៥– ភរិយាណា មានកុសលចិត្ត ប្រកបដោយសីល និងអាចារៈស្លូតត្រង់ មានវត្តប្រតិបត្តិ មានចិត្តស្មោះត្រង់ចំពោះស្វាមី ពោលពាក្យពីរោះជាទីគាប់ចិត្ត ភរិយានោះហៅថា សហាយាសមាភរិយា ។

៤៦– ភរិយាណា ទោះបើស្វាមីជេរស្តី ឬគំរាមគំហកវាយ ក៏មិនប្រទុស្តតប មានចិត្តអំណត់ មិនគុំគួន និងទទួលស្តាប់បង្គាប់ស្វាមី ភរិយានោះ លោកឲ្យឈ្មោះថាទាសីសមាភរិយា ព្រោះមានសភាពដូចជាទាសីខ្ញុំម្ចាស់ ។

៤៧– ភរិយាណា មានចិត្តអាណិតករុណា គ្រប់គ្រ ថែរក្សានិងស្វែងរកប្រយោជន៍ឲ្យស្វាមី ជាអ្នកមិនមានពុតត្បុត ដូចជាមាតាថែរក្សាបុត្រ ភរិយានោះលោកហៅថា

មាតាសមាគរិយា ។

៥៨- នារីទាំងឡាយគប្បីកាន់យកខ្សែទុកចំណាំទាំងឡាយ ១០ប្រការតទៅទៀតគឺ ភ្លើងក្នុងមិនត្រូវនាំទៅខាងក្រៅ១ ភ្លើងខាងក្រៅមិនត្រូវនាំចូលមកខាងក្នុង១ គប្បីឲ្យទ្រព្យសម្បត្តិដល់បុគ្គលដែលគួរឲ្យ១ មិនគប្បីឲ្យដល់បុគ្គលដែលមិនគួរឲ្យ១ ព្រោះបើជននោះមានសភាពយ៉ាងណាក៏ដោយ គប្បីតែឲ្យ១ គប្បីអង្គុយជាសុខ១ គប្បីបរិភោគជាសុខ១ គប្បីដេកជាសុខ១ គប្បីបង្អាក់ភ្លើងទុក១ ទេវតាខាងក្នុងគប្បីនមស្ការ១ ។

៥៩- ពាក្យណា ដែលកើតចេញពីសង្គមយើង ហើយនាំយកទៅប្រាប់ជនក្រៅសង្គមដែលមិនមែនជាញាតិ ជាពាក្យប្រកបដោយទោស ពាក្យនោះហៅថា ភ្លើងក្នុង ។

៦០- ពាក្យណាមួយ កើតចេញនៅក្រៅសង្គមបិតាមាតា ដែលជាពាក្យ: ប្រកបដោយទោស ជាហេតុនាំឲ្យបង្ករពាក្យ ក៏

មិនគប្បីនាំចូលមកប្រាប់ដល់សង្គមរបស់យើង ពំខនោះ ហៅថា ភ្លើងក្រៅ ។

៦១ – ជនណា ដែលតាំងគេហដ្ឋាននៅជិតផ្ទះ ដែលគួររាប់ជាញាតិដែរ បានចូលមកខ្ចីវត្ថុណាមួយពីសង្គមយើង មិនបានយកមកប្រគល់សងវិញ ជននោះជាបុគ្គលមិនគួរឲ្យគត់ទៅទៀយ ។

៦២ – តែបើជនដទៃណាមួយ, ប្រកបដោយចិត្តល្អ បានខ្ចីយកវត្ថុណាមួយ តែនោះបានយកមកប្រគល់ឲ្យវិញ, ជនដទៃនោះគប្បីឲ្យខ្ចីក្នុងថ្ងៃខាងក្រោយ ។

៦៣ – ញាតិខ្សត់ទ្រព្យ ដែលប្រកបដោយចិត្តល្អ ប្រកបដោយគុណធម៌ផ្សេងៗ វត្ថុណាដែលយើងបានឲ្យខ្ចីហើយទោះបីជាសងក៏មិនសងវិញក្តី តែនោះគប្បីត្រូវតែឲ្យទៀត ។

៦៤ – ទីសេនាសនខ្ពស់ ប្រសើរជាងម្តាយឪពុកក្មេក និងស្វាមី នាងមិនគប្បីអង្គុយនៅ, គប្បីក្រោកទទួលដោះជើ

ជាទៅវិសេទាសនៈខ្ពង់ខ្ពស់ក្តី មិនប្រសើរក្តី ដែលជនមានគុណសម្បត្តិគឺមាតាបិតាទីងស្វាមី មកដល់ ទាំងនេះហៅជា អង្គុយជាសុខ ។

៦៥ – គ្រឿងបរិភោគ ដែលបានចាត់ចែងរួចហើយប្រណីតនឹងមិនប្រណីត ទោះបីនាងឃ្លានយ៉ាងណាក៏ដោយក៏មិនគប្បីបរិភោគមុន ដរាបណា មាតាបិតាក្មេកនឹងស្វាមីនាងបានរៀបទទួលគាត់ស្រេចហើយ ដរាបនោះទើបនាងគប្បីបានបរិភោគជាខាងក្រោយ ទាំងនេះហៅថា បរិភោគជាសុខ ។

៦៦ – នាងគប្បីដេកជាសុខ, ក្នុងពេលដែលត្រូវដេកប្តីមុនពេលរៀបដេក នាងគប្បីបោសសំអាតទីសេនាសនៈ គប្បីរៀបចំទុកដាក់វត្ថុដែលគួរទុកដាក់ គប្បីធ្វើកិច្ចវត្តមានការគក់ប្រយ័ត្នក្នុងពេលជនទាំងនោះមានអាពាធបៀតបៀន ។

៦៧ – ភ្ញៀវដែលនេះសន្ទោសនៅ១ ស្តេចពស់មានពិសកំណាច១ ជនទាំងពួងមានសេចក្តីតក់ស្លុតខ្លាចយ៉ាងណា

នាងក៏មានការគោរពប្រតិបត្តិ មាតា-បិតាក្មេកទាំងស្វាមីជានិច្ច ប្រៀបប្រៀបយ៉ាងនោះដែរ, គំនិតមារយាទថោកទាបមានការប្រកាន់ក្ដដក្ដី ទាំងទ្រព្យសម្បត្តិ គប្បីលះបង់ចេញនេះលោកដោយក្ដី នាងគប្បីបង្អាក់ទុក ។

៦៨– មាតាបិតាក្មេកនិងស្វាមី តែងប្រកបដោយគុណមានចិត្តល្អ ចិត្តបន្ទោស មានមេត្តា ឧបេក្ខា ករុណាទាំងបរិតាជានិច្ច ដែលត្រូវផ្ដល់ឲ្យដល់នាង នាងគប្បីចូលទៅបំរើអ្នកទាំងនោះ ដូចជាអ្នកចូលទៅបំរើព្រះឥន្ទ ទាំងនេះទៅថាទេវតាក្នុងផ្ទះ គឺមាតាបិតាក្មេកនិងស្វាមី ។

៦៩– នារី, នរជន, សស្ត្រាវុធ, ពិណ, សាស្ត្រាង្គ, សុន្ទរកថា, វិសេសឬមិនវិសេស ប្រើបានល្អ ឬមិនបានល្អស្រេចហើយតែវិធីនៃម្ចាស់អ្នកប្រើអ្នកបង្គាប់បញ្ជាទេ ។

៧០– កិរិយាដែលគេស្ដីតិះកិរិយា កិរិយាមិនអើពើបំ-រើព្រាហ្មណ៍ និងសមណៈទាំងកិរិយាមិនធ្វើតាមពាក្យព្រះ

នរេន្ទ្រ ទាំងអស់នេះឈ្មោះថាស្លាប់មិនបាច់ប្រហារដោយសាស្ត្រាវុធឡើយ ។

៧១– នៅលើផែនដីនេះ នរណាមានចិត្តនឹងមិនព្រួយខ្លួនដួលព្រោះស្ត្រី? នរណាបានទ្រព្យសម្បត្តិហើយមិនឡើងតាំង? នរណាលុះក្នុងអំណាចវិស័យខ្លួន ហើយរលត់ក្តីទុក្ខអន្តរាយបាន? មួយទៀត, នរណាជាទីស្រឡាញ់នៃព្រះរាជា? ក្នុងលោកនេះនរណាមានអំណាចខ្លាំង មិនចូលទៅក្នុងកណ្តាប់ដៃនៃព្រះកាល? នរណាជាអ្នកសូមទាន ហើយបានដល់សេចក្តីគោរពយ៉ាងខ្ពង់ខ្ពស់? មួយវិញទៀត, នរណាដែលធ្លាក់ខ្លួនទៅក្នុងអន្ទាក់នៃទុរជន ហើយបានត្រឡប់ជាបុរសបរិបូណ៌ដោយក្តីក្សេមក្សាន្ត? ។

៧២– គេអាចដឹងចិត្តភរិយាគ្រប់ក្នុងកាលវិបត្តទ្រព្យ, ដឹងចិត្តមិត្តក្នុងគ្រាក្រ, ដឹងចិត្តទាហានក្លៀវក្លាក្នុងសង្គ្រាម, ដឹងចិត្តស្មោះត្រង់ក្នុងការសងបំណុលគេ, និងដឹងចិត្តដៅ

ពង្សត្រកូលគ្រោះទោសអន្តរាយ ។

៧៣– បុគ្គលគប្បីរក្សាកិរិយាដោយទ្រព្យ, គប្បីថែរក្សាទ្រព្យទុកក្នុងគ្រាក្រ តែគប្បីរក្សាខ្លួនរឿយ ៗ ដោយទ្រព្យផង ដោយកិរិយាផង ។

៧៤– បុគ្គលមិនគប្បីធ្វើសេចក្ដីស្និទ្ធស្នាលទុកចិត្តស្ត្រីក្នុងកដត្រកូល, បុគ្គលមានសស្ត្រាវុធក្នុងដៃ, សត្វមានក្រចកមុត, សត្វមានស្នែងនឹងពឹកខ្លួនទាំងឡាយ ។

៧៥– នរជនណា ឃើញកិរិយាអ្នកដទៃ ទុកស្មើដោយមាតារបស់ខ្លួន ឃើញទ្រព្យអ្នកដទៃទុកស្មើដោយដុំថ្ម ឃើញសព្វសត្វទាំងឡាយ ទុកស្មើដោយរូបខ្លួន នរជននោះលោកហៅថា «បណ្ឌិត» ។

៧៦– ភរិយាខ្លួនជាទីស្រឡាញ់ពេញចិត្តយ៉ាងណា ភរិយាជនដទៃក៏យ៉ាងនោះដែរ, លោកអ្នកសប្បុរសទាំងឡាយ តែងធ្វើសេចក្ដីមេត្តាករុណា ព្រោះលោកយកខ្លួន

របស់លោកជាគ្រឿងឧបមា ។

៧៧– បុគ្គល គួរលះបង់កាមឲ្យស្រឡះទៅ ចាំបើអត់ទ្រាំទប់ទល់ កាមមិនបានទេ គួរសេពគប់ចំពោះតែភរិយាខ្លួនប៉ុណ្ណោះហើយ ព្រោះថាភរិយាជាគេសដ្ឋៈតែពេកគឺកាមកត បាន ។

៧៨– កាម១ ក្រោធ១ លោភៈ១ មោហៈ១ ឫស្សា១ មានៈ១ ស្រវឹង១ ធម៌ទាំង៦ប្រការនេះ បើលះបង់បាន ទើបបានសេចក្តីសុខ ។

៧៩– ករិយាពោលពាក្យ បយ៉ាថា ទៅកាន់ភរិយា១ មិនជឿរឿយករិយាដូចជាទាសី១ ប្រគល់នូវតែទាំងពួងមាន កិច្ចថែរក្សាផ្ទះនិងចំអិនអាហារជាដើម១ ផ្គត់ផ្គង់គ្រឿងអលង្ការឲ្យភរិយាតាមបវេណី១ ទាំង៥ប្រការនេះជាសង្គហស្វាមី ដែលគប្បីធ្វើដល់ករិយា ។

៨០– ករិយាចាត់ចែងការងារទាំងភាគតែងម្ហូបអាហារ

បំរុងស្ត្រីមិនឲ្យហួសពេលវេលា១ សង្គ្រោះដល់កូនផងនឹងញាតិរបស់ប្ដីឲ្យដូចជាញាតិខ្លួន១ ប្រគល់ចិត្តឲ្យស្វាមីមិនមានប្រុសដទៃជាសាហាយស្មន់១ រក្សាទ្រព្យសម្បត្តិរបស់ប្ដីដែលរកបានមករក្សាទុកឲ្យគង់១ នឹងឈ្លាសស្ទាត់ក្នុងកិច្ចការផ្ទះមិនខ្ជិលច្រអូស១ ទាំង៥នេះជាសង្គហរបស់ភរិយា ដែលត្រូវធ្វើដល់ស្វាមី ។

៨១– បុគ្គលគប្បីជ្រាបថា ព្រះពជាម្ចាស់ផែនដី១ អ្នកបួស១ យាតីស្ត្រីភាព១ ដំរីមង្គល១ ទាំង៤នេះ គប្បីមានវិន័យនឹងកិរិយាប្រព្រឹត្តដូច ៗ គ្នា ។

៨២– ម្ចាស់ផែនដីដែលបានពជាភិសេកហើយ ដែលប្រដាប់ដោយគ្រឿងឥស្សរិយយស គប្បីយានតាមសភាពជាប្រក្រតី បើស្ទុះឬរត់ដូចជាមន្ត្រីតូចតាចតែងបានគេហានិន្ទាពីជនដទៃដោយពិត, ឯស្ត្រីភាព ជាអ្នកមានវង្សត្រកូលបើស្ទុះឬរត់ក៏បានគេហានិន្ទាយ៉ាងនោះដែរ ។

៨៣ - ដំរីជាព្រះទីនាំង ដែលគេសន្មត់ថាជាដំរីប្រសើរ មានដំណើរយោងយោះសណ្ដងណ្ដាយទៅតាមភាពខ្លួន ទើបសមសក្ដិជាព្រះកដទីនាំង ជាដំរីមង្គលពិតគួរគេលើកដំកើង ៗ

៨៤- អ្នកបួសក្នុងព្រះពុទ្ធសាសនា ត្រូវនិមន្តតាមផ្លូវជាលំដាប់តាមពាស្ស ក្នុងវស្សា ហើយមិនគប្បីដាក់ចុះទៀងសុះស៊ុតដូចជាគ្រហស្ថ ព្រោះជាហេតុទាស់ខុសផលវិន័យ សិក្ខានៃភិក្ខុបញ្ញត្តិ ៗ

៨៥- ស្ត្រីភាព ប្រកបដោយទោសច្រើន ប្រកបដោយជាតិជាអ្នកអៀនខ្មាសច្រើន ក៏ត្រូវការវិន័យ និងច្បាប់ដូចជាអ្នកបួស; ស្ត្រីណាជាអ្នកមិនមានវិន័យនិងច្បាប់ប្រព្រឹត្តខុសគន្លងប្រវេណី ស្ត្រីនោះលោកហៅថា «ស្ត្រីវេស្យា» ៗ

៨៦- សមាគមមួយអន្ទើរដោយស្ត្រីជាមាស ចូលចិត្តនៅលាយនឹងបុរស កិរិយាធៀស្ដាប់សំដីមេអណ្ដើក កិរិយាដើកទូវើកប្រឹង និងជឿពាក្យលួងលោមនៃបុរស តាំងពីនេះ

ជាហេតុប្រទុស្តនៃនារីក្រមុំទាំងឡាយ ។

៨៧– ស្តេច ស្រីក្រមុំមានត្រកូល, សមណព្រាហ្មណ៍ បព្វជិត, ចោរ, ធ្មេញ, សក់, ក្រចកទឹងនៃផែន ទាំងអស់នេះ ដែលគេដកចេញពីដំណែងហើយ (ឬកន្លែង) មិនល្អទេ ។

៨៨ – នារីក្រមុំឯណា ប្រកបដោយរូបល្អសម្បុរលឿង រឺដូចជាសុវណ្ណ មាននេត្រខ្មៅដូចជាម្រឹគ, ចង្កេះរៅសមគាងស្មា, ដំណើរប្រៀបព្រាយដូចគជហង្ស, ចុកទំនួលសម មានកេសាខ្មៅរលើបចុងឡើង, ធ្មេញស្រឹមល្អ, នាភីខ្វង់ ទឹងកបោះដោយទ័យគល់មារយាទ នារីដែលមានលក្ខណៈបែបនេះ នារីនោះ សូម្បីកើតក្នុងត្រកូលហីនជាតិបុគ្គល គប្បីសង្គ្រោះយកជាភរិយាត្រាតែបាន ។

៨៩– បុគ្គលគប្បីជ្រាបថា ៖ ម្លប់ពពក, មេត្រីដោយមនុស្សសាហាវ, សំពត់ថ្មី, ស្រីក្រមុំ និងទ្រព្យសម្បត្តិទាំងអស់នេះ ធ្វើឲ្យមានសេចក្តីកក់យតែមួយខណៈទេ ។

៩០ – សូមឲ្យបុរសចាស់ៗ ទាំងឡាយកុំពេញចិត្តនឹងនារីក្មេងសាវ៉ាឡើយ, សូមឲ្យភរិយា នឹងនារីទាំងឡាយប្រតិបត្តិតាមច្បាប់របស់ខ្លួន ត្រូវបំពេញករណីយរបស់ខ្លួនឲ្យម៉ឺនមាំ, សូមឲ្យស្ត្រីភាពទាំងឡាយប្រកបដោយសេរីសួស្តីជ័យមង្គល ឲ្យប្រកបដោយសុខសន្តិភាពគ្រប់កាលទាំងពួង ។

ចប់

# ការស្វែងទ្រព្យ

១– ការ្យទាំងឡាយ តែងសម្រេចដោយការប្រឹងប្រែង ដោយពិត មិនមែនដោយមនោរថទេ, ដូចម្រឹគទាំងឡាយ មិនពោលចូលមាត់សីហៈដែលដេកលក់ឡើយ ។

២– បុគ្គល សូម្បីកាលឃើញកំណប់ទ្រព្យក្នុងទីចំពោះមុខដូចរៀនក្អែកដែលមិនទឹកនាថា មិនកើតមានបាន ហើយ ចាំព្រេងវាសនាគាស់កកាយមកឲ្យឯង ៗ មិនរវល់ធ្វើសេចក្ដីព្យាយាមពេញជាកូនប្រុស មិនបានកំណប់នោះទេ ។

៣ - បុគ្គល សូម្បីគិតឃើញព្រេងវាសនា ក៏មិនគួរលះបង់សេចក្ដីព្យាយាមចោលឡើយ បើបុគ្គលមិនព្យាយាមចម្រាញ់

ល្ង មិនបានប្រេងល្ងទេ ។

៤– ដោតលោក តែងតែហៅតែបុរសសីហៈ ដែលជាអ្នកមានសេចក្តីព្យាយាមក្លៀវក្លា, មានតែបុរសតែគេទេ ដែលពោលថា «ស្រេចតែព្រេងវាសនា» បុគ្គលចូរផ្ចាញ់នូវវាសនា ហើយធ្វើនូវសេចក្តីព្យាយាមឲ្យពេញជាកូនប្រុស តាមកម្លាំងខ្លួនដែលអាចធ្វើបាន, ជាបើតាំងសេចក្តីព្យាយាមប្រឹងប្រែងហើយ នៅតែមិនសម្រេចទៀត តើវាទៅជាកើតទោសអ្វី ?។

៥– រថ តែងមិនគប្បីទៅបានដោយកង់តែម្ខាង យ៉ាងណា ? ព្រេងវាសនា បើប្រាសចាកសេចក្តីព្យាយាមនៃបុរសហើយ ក៏មិនសម្រេចយ៉ាងនោះដែរ ។

៦– កម្មដែលបុគ្គលធ្វើពីបុព្វជាតិហៅថា «ព្រេងវាសនា» ហេតុនោះ បុគ្គលដែលមិនត្រូវខ្ជិលច្រអូស គប្បីធ្វើសេចក្តីប្រឹងប្រែងដោយសេចក្តីព្យាយាមពេញជាបុរស ។

៧– កំជិលជាមេបាបធម៌ទាំងឡាយគ្រប់យ៉ាង, ការ

វិនាសលោក, ការអប្បប្រាជ្ញា, ការបានសេចក្តីទុក្ខសោក ការធ្លាក់នរក, ការមិនមានវិជ្ជាទ្រព្យ, ការអន្តរធានសាសនា, និងការលិចលង់ជាតិ ក៏មកពីមេកំជិលជាដើមអាទិ ព្រោះហេតុនោះ បុគ្គលចូលផ្ចាញ់សេចក្តីខ្ជិលនេះចេញពីខ្លួនឲ្យស្រឡះ ។

៨– ជនដែលធ្លាក់ខ្លួនទៅជាមនុស្សក្រីក្រ លោកទម្លាក់ខ្លួនក្នុងគំនរភ្លើង ឲ្យស្លាប់បាត់បង់ជីវិតទៅប្រសើរជាងការដើរអើតដើតសូមទានគេ ; ដែលឥតគួរសមកំណាញ់មិនចង់ឲ្យទានមិនប្រសើរឡើយ ។

៩– សេចក្តីក្រីក្រនាំឲ្យកើតសេចក្តីអៀនខ្មាស, ក្តីអៀនខ្មាសនាំឲ្យបាត់ក្លាហាន, ការបាត់ក្លាហាននាំឲ្យគេមើលងាយ, ការមើលងាយនាំឲ្យកើតការស្អប់ខ្ពើម, ការស្អប់ខ្ពើមនាំឲ្យបានសេចក្តីទុក្ខសោក, សេចក្តីទុក្ខសោកនាំឲ្យអប្បប្រាជ្ញា ការអប្បប្រាជ្ញា នាំឲ្យក្ស័យអន្តរធានជាងអ្វីទាំង

អស់, ទ ॥ សេចក្ដីក្រីក្រអើយ អ្នកជាប្រធាននៃសេចក្ដីវិនាស គ្រប់ប្រការទាំងអស់ ។

១០– បុគ្គលមិនប្រឹងប្រែងរកទ្រព្យសម្បត្តិ ឈ្មោះជាប្រគល់ការសម្បូណ៌ទ្រព្យសម្បត្តិ ទៅលើដៃជនដែលមានសេចក្ដីព្យាយាម, ដូចសត្វកង្កែបកែងលោតចូលទៅក្នុងអណ្ដូង ឬ ដូចជាត្រីកែងចូលទៅនៅក្នុងស្រះ ដែលពេញប្រៀបដោយទឹកយ៉ាងនោះ ។

១១ – ជោគក៏សនា តែងតែទៅរក តែនជនដែលសម្បូណ៌ទៅដោយសេចក្ដីព្យាយាមប្រឹងប្រែង មិនដេកទ្រមក់ហួសកាលវេលា, ស្គាល់វិធីដំណើរការណ៍, មិនជាប់ជំពាក់ចិត្តក្នុងរឿង គឺអន្ទពយ, ក្រៀវក្លាហាន, ដឹងឧបការៈគុណគេ នឹងមានចិត្តល្អអាំមួនក្នុងសន្ដានដោយចំរើនខ្លួនឯង, មិនមែនមកពីទីលំនៅជាហេតុទេ ។

១២ – បុរសខ្សត់ បើទុកជាប្រព្រឹត្តតាមគន្លងធម៌នៃព្រ

កូល ក៏មិនជាទីសេពគប់ផងដែរទេ សូម្បីតែប្រពន្ធខ្លួនក៏លះបង់ចោលដែរ ចាំបាច់និយាយថ្វីដល់ផងដៃ ។

១៣ – នរជនដែលក្រីក្រសម្បត្តិ ដោយហោចទៅសូម្បីប្រដាប់ខ្សែកជាវិការនៃអាសសុទ្ធ ក៏លោកប្រាប់ថាពោលថាខ្សែកស្ពាន់ដែរ, ឯនរជនមានទ្រព្យសម្បត្តិ ដែលប្រដាប់ដោយខ្សែកជាវិការសំណលោបក្រឡែមាស នរណាហ៊ានហ៊ានពោលថាខ្សែកក្រឡែបាន ? ។

១៤ – ទ្រព្យសម្បត្តិ មិនតែងទៅរកជនណាដែលគ្មានសេចក្ដីប្រឹងប្រែងខ្វល់ច្រអូស វាធ្វើនឹងបន្ទោសព្រេងវាសនានឹងមិនមានពូកយាមទេ, ដូចប្រពន្ធគេនឹងមិនអើពើនឹងប្ដីចាស់ជរាដូច្នោះ ។

១៥ – ទឹកស្រះមួយដំណក់ៗអាចពេញក្អមបានយ៉ាងណា, ការសន្សំទ្រព្យ. រៀនសូត្រវិជ្ជានឹងការប្រតិបត្តិធម៌ ក៏យ៉ាងនោះដែរ ។

១៦ – បុគ្គល គប្បីស្វែងរកទ្រព្យសម្បត្តិដែលមិនទាន់បាន គប្បីរក្សាទ្រព្យដែលរកបានហើយ កុំឲ្យខាតទាំងអស់ទៅវិញ, គប្បីកពូនទ្រព្យសម្បត្តិនោះឲ្យចំរើនឡើងដោយប្រពៃ ហើយគប្បីគប់ទ្រព្យសម្បត្តិនោះក្នុងបុញ្ញក្ខេត្ត ។

១៧– បុគ្គលកាលប្រាថ្នា, ហើយប្រាថ្នារកសម្បត្តិទ្រព្យដែលមិនទាន់បាន តែងបានសម្បត្តិទ្រព្យនោះមក, ឯទ្រព្យដែលគេរកបានហើយ បើមិនរក្សាទុកដាក់ឲ្យបានមាំមត់ទេ សូម្បីនឹងព្យាយាមដ៏ធំយ៉ាងណាក៏ដោយ ក៏នឹងវិនាសទៅឯង ។, ដូចជាគេដងទឹកដាក់ជាលក្អមប្រហូលហូចយ៉ាងនោះ ។

១៨– ទ្រព្យសម្បត្តិ បើបុគ្គលមិនធ្វើឲ្យចំរើនឡើងទេ ក៏តែងតែអស់ទៅបន្តិចម្តង ៗ គ្រប់កាល ដូចជាថ្នាំបន្តក់ភ្នែក ។ ទ្រព្យសម្បត្តិនេះឯង បើបុគ្គលមិនចែកចាយជាសាធារណៈ គានឲ្យជាសុខដល់ជនដទៃទេ ក៏ជាការសាបស

សោះសូន្យទេ ។

១៩– បុគ្គល គប្បីរក្សាទ្រព្យទុកដើម្បីគ្រាក្រ គប្បីរក្សាកិរិយាដោយទ្រព្យ តែគប្បីរក្សាខ្លួនរឿយ ៗ ដោយកិរិយាផង ដោយទ្រព្យផង ។

២០– បុគ្គល គប្បីស្វែងរកស្ត្រីដែលមានវង្សត្រកូលជំពាក់បរិសុទ្ធ មានពូជជាអ្នកចេះកតួនទ្រព្យ ទឹងមាន៖ស្រាប់កៀវក្លាក្នុងការស្វែងទ្រព្យធ្វើជាកិរិយា ព្រោះស្ត្រីភាពគេទុកដូចជាភាជន៍សំរាប់ទ្រទ្រង់នៅទ្រព្យដែលស្វាមីខំរកបានមក បើភាជន៍មានបាតធ្លាយហើយ ការខំកតួនសន្សំទុកក៏ជាការឥតផលដែរ ។

២១– ទ្រព្យសម្បត្តិ តែងរត់ទៅរកស្ត្រីណាដែលចេះសំចៃទុកដាក់ដោយប្រពៃ មិនមែនរត់ទៅជ្រកនឹងអ្នកដែលចាយវាយខ្ជះខ្ជាយគ្មានសណ្ដាប់ធ្នាប់ឡើយ, ដូចធម៌សតែងរក្សាជនដែលមានធម៌ស ដែលបានប្រតិបត្តិជាប់ក្នុងសន្តាន

ដូច្នោះ ។

៦២– សព្វកិច្ចការគ្រប់ពីហ៊ុន គ្រប់ការលើលោកនិងលោកនេះ, បុគ្គលមានទ្រព្យឈ្មោះថាមានកម្លាំង, សេចក្ដីពិតព្រះពុជាមានភាពជាមហាអំណាច ព្រោះមានទ្រព្យជាមូលហេតុ ។

៦៣– ក្នុងលោកនេះ បុគ្គលមានទ្រព្យឈ្មោះថាមានកម្លាំងផង ឈ្មោះថាជាបណ្ឌិតទៀតផង ។

៦៤– បណ្ដាសេចក្ដីក្រីក្រនិងសេចក្ដីស្លាប់ទាំងពីរប្រការនេះ គេចូលចិត្តសេចក្ដីក្រជាងសេចក្ដីស្លាប់, តែដោយពិតវិញ សេចក្ដីស្លាប់នាំឲ្យកើតទុក្ខស្រាលៈ១ គឺមួយពេលមួយកាលគឺអស់ទៅហើយ, ឯសេចក្ដីក្រីក្រវិញ ធ្វើឲ្យកើតសេចក្ដីទុក្ខព្រួយយ៉ាងខ្លាំង ស្ទើរតែរាល់គ្រាពុំបានគ្រប់កាលទាំងក្នុង ។

៦៥– បើឥន្ទ្រិយ៍ទាំងឡាយកែលហើយ ក៏

ឈ្មោះក៏នៅដដែល បើប្រាជ្ញាវិបត្តិហើយ ក៏វាគិតនឹងទៅ មិនរំពឹក. បើបុរសប្រាសចាកកម្លាំងទ្រព្យរបស់ផងហើយ អ្វីដទៃទៀត ដែលមិនឈ្មោះជារលំរលាយទៅក្នុងមួយខណៈនោះដែរ ? ។ ធម្មជាតិអស់នេះ គួរឲ្យស្ញើចអស្ចារ្យណាស់ហ្ន៎ !

២៦– អ្នកមានប្រាជ្ញាមិនគប្បីប្រកាស ការវិនាសទ្រព្យសម្បត្តិ, ការក្តៅក្រហាយចិត្ត, ការទុច្ចរិតក្នុងផ្ទះ, ការត្រូវគេប្រវ័ញ្ច និងការគេមើលងាយឲ្យគេដឹងឮឡើយ ។

២៧– អាយុជីវិត, ទ្រព្យសម្បត្តិ, ទោសជាប់ចនោះក្នុងផ្ទះ, មន្ត ( ការសម្ងាត់ ) មេថុន, ឱសថៈ ( ថ្នាំរោគ ) តបជមិ, ការឲ្យទាន និងការត្រូវគេមើលងាយ គប្បីលាក់ទុកកុំឲ្យគេដឹងឮឡើយ ។

២៨– ជីវិតអ្នកទ័លក្រ ដែលហិនហោចចាកទ្រព្យសម្បត្តិ

អាស្រ័យនៅក្នុងព្រៃតែម្នាក់ស្ងាត់ ប្រកបដោយប្រឹតពាក្យ សាហាវយង់ឃ្នងមានតែខ្លានឹងដំរី, យកឈើព្រៃជាទីលំនៅ យកផ្លែឈើមើមស៊ីជាចំណីអាហារ យកស្លឹកឈើក្រាលដេក ទីដែលយកសំបកឈើជាគ្រឿងស្លៀកពាក់ ប្រសើរជាងការរស់នៅក្នុងកណ្ដាលពួកញាតិដែលក្រ ។

២៩– បុគ្គល គប្បីរក្សាទ្រព្យសម្បត្តិរបស់ការបជាទិច្ច ដូចជាការរក្សានៃសត្វកណ្ដៀរនិងសត្វឃ្មុំ, តែកុំលោភលន់ហួសប្រមាណពេក រហូតដល់លបលាក់ប្រវញ្ចន៍ទ្រព្យជនដទៃ គប្បីតែមានការព្យាយាមជាមូលពល ។

៣០– នរជនមានទ្រព្យច្រើន នរជននោះសូម្បីប្រព្រឹត្តអនាចារមិនគប្បី ក៏នៅតែមានគេកោតខ្លាច គោរពរាប់អានដែរ, ឯនរជនដែលក្រីក្រវិញ បើទុកណាជាមានវង្សជាប់នឹងព្រះចន្ទ ឬព្រះអាទិត្យ ក៏នៅតែគេមើលងាយដែរ ។

៣១– ភាវនៃបុគ្គលខ្ជិល១ ការសេពគប់ស្ត្រីខ្ញាមាស១

ភាវៈនៃបុគ្គលមានកេតច្រើន១ ចិត្តជាប់នឹងស្រុកកំណើត១ ចិត្តសន្តោស១ ភាវៈជាបុគ្គលខ្លាចច្រើន១ ទោសទាំង៦ប្រការ នេះជាគ្រឿងទម្លាយបង់នូវភាវៈនៃខ្លួនជាធំ ។

៣២– អ្នកណា មានទ្រព្យសម្បត្តិតិចតួច ហើយមិនខំប្រឹងប្រែងរកទៀត ព្រោះវាសនាដែលកប់ទុកពីបុព្វជាតិ ជាអ្នកធ្វើនូវទ្រព្យសម្បត្តិ មិនព្រមចំរើននូវលាភទ្រព្យឲ្យដល់ជននោះទៀតទេ ។

៣៣ - បុគ្គលប្រព្រឹត្តដេកសំយ៉ាបផ្ទះអ្នកដទៃ, បុគ្គលមានគេបៀតបៀន, បុគ្គលព្រាត់ប្រាសអស់កាលយូរ និង បុគ្គលអាស្រ័យបាយទឹកគេចិញ្ចឹម ជីវិតនៃបុគ្គលនោះ ឈ្មោះថាជាជីវិតស្លាប់សូន្យឈឹង, សេចក្ដីស្លាប់នៃបុគ្គលនោះ ។ ឈ្មោះថាជាទីសម្រាកដ៏ស្ងប់ស្ងៀម ។

៣៤ – ភាពជាអ្នកមានទ្រព្យច្រើន១ ភាពជាយុវជន១ ភាពជាអ្នកមានអធិបតេយ្យ១ ភាពជាអ្នកមិនបែកបាក់គ្នា១

ធ្វើដូចម្ដេចឲ្យបានគ្រប់ទាំង៤ប្រការនេះ នៅក្នុងខ្លួនមនុស្ស ។

៣៥– ការចិញ្ចឹមជីវិតដោយសារជនដទៃ១ មេថុនដោយការទិញដូរ១ និងការលេងល្បែងភ្នាល់១ ទាំង៣ប្រការនេះជាគ្រឿងនាំឲ្យអាម៉ាស់មុខនៃបុរសទាំងឡាយ ។

៣៦– មនុស្ស មិនមែនជាទាសនៃមនុស្សទេ មនុស្សជាទាសនៃទ្រព្យសម្បត្តិ, ការបានជាបុគ្គលខ្ពង់ខ្ពស់ ឬការធ្លាក់ទៅជាបុគ្គលថោកទាប ស្រេចហើយតែមានទ្រព្យ និងក្រីក្រទ្រព្យតែប៉ុណ្ណោះ ។

៣៧– សត្វសីហៈ សប្បុរសនឹងដំរី តែងលះបង់ទីឋានមិនល្អ ទៅរកទីឋានល្អវិញ, តែសត្វក្អែកបុរសកំរក និងម្រឹគតែងស្លាប់នៅក្នុងទីកន្លែងខ្លួន ។

៣៨– វីរៈបុរស ជាអ្នកមានប្រាជ្ញា មិនរវល់យកចិត្តទុកដាក់ថា „ដូចម្ដេចដែលហៅថាប្រទេសខ្លួន„ ឬ „ដូចម្ដេចដែលហៅថាបរទេសឡើយ„ ចូលទៅក្នុងប្រទេសណាក៏ច្រើន

ប្រែងរកទ្រព្យក្នុងប្រទេសនោះ ដោយកំឡាំងនៃខ្លួន, ដូច
សត្វសីហៈរូបតៅនៅក្នុងព្រៃណា មិនមានអ្វីជាកុជមាន
តែចង្កូមនិងក្រញុំ ជាគ្រឿងប្រហារ អាចចាប់សម្លាប់ស្តេចដំរី
សារពើភក្សាហារស៊ីហុតឈាម ដើម្បីបំបាត់សេចក្ដីស្រេក
ឃ្លានទៅក្នុងព្រៃនោះ ។

៣៩ – ចូលមើល / ជាតិចិន តែងរត់ចេញពីប្រទេស
មិនល្អ គឺប្រទេសកំណើតរបស់ខ្លួន មានតែអម្រែកនិងឆ្នាំងជា
មូលធន ចេញស្វែងរកសម្បត្តិទ្រព្យ បានជាអ្នកមានធំគ្រប់ប្រ
ទេសនានា, វិស័យដូចជាសត្វសីហៈ, ប៉ុន្តែក្នុងសម័យនេះ
មានជនជាតិខ្លះ ទៅជាក្រស់ក្រោធក្នុងការខ្លួនដេកច្រមក់មិន
លក់ដើម្បីផ្ចាប់កំដិល ទីងផ្ទះជាតិដែលប្រឹងប្រែងធ្វើការទាំង
យប់ ។

៤០ – អ្នកមានប្រាជ្ញា សាលដែលលើកជើងក្រោយ
ល្បះគ្រាតែជើងមុខជាន់ស៊ប់ហើយ គេចំហាងឯទៀតបានហើយ

ទើបលះបង់ទីឋានចាស់ពោលបាន ។

៤១ ប្រទេសឯណា មិនមានគោចរគេ មិនមានផ្លូវរកស៊ីចិញ្ចឹមជីវិត មិនមានញាតិសន្តានផៅពង្ស ឬក៏មិនមានវិញ្ញូជនចំរើនចំណេះវិជ្ជា បុគ្គលគប្បីលះបង់ប្រទេសនោះចោលចេញ ។

៤២ – លោកយាត្រា (ការរស់គង់) ១ សេចក្តីភ័យ ១ ការខ្មាសមុខ ១ មេត្តាករុណា ១ ការបរិច្ចាគទាន ១ ទីណាមិនមានធម៌៥ប្រការនេះ បុគ្គលមិនគប្បីតាំងទីឋានអាស្រ័យនៅក្នុងទីនោះឡើយ ។

៤៣ – មនុស្សសេដ្ឋីបំណុលគេ ១ គ្រូពេទ្យ ១ សមណៈព្រាហ្មណ៍ ១ ចេះដឹងធម្មសាស្ត្រទាំងវេទ ១ ទន្លេមានទឹកថ្លាបរិសុទ្ធ ១ ទីឋានណាមិនមានវត្ថុទាំង៥ប្រការនេះទេ បុគ្គលមិនគប្បីតាំងលំនៅក្នុងទីឋាននោះឡើយ ។

៤៤ – វិស័យពាណិជជន សម្បូរគ្រប់ទ្រព្យសម្បត្តិ ក៏

អាចចូលទៅកាន់សភាពខ្ពង់ខ្ពស់ ដោយកិត្តិយសដ៏ក្រៃលែង ឯបុគ្គលកំណាញ់ សូម្បីប្រកបដោយទ្រព្យសម្បត្តិសម្បូណ៌ ប៉ុន្មានក៏ដោយ គង់ធ្លាក់ខ្លួនចុះទៅកាន់សភាពថោកទាបដ៏អាក្រក់ក្រៃលែង ដូចសុនខជាតិដែលគេចងកដោយខ្សែកជាវិការៈនៃមាស មួចឡើយនឹងបានល្អ ដូចសីហៈដ៏រុងរឿង ប្រកបដោយវិស័យលេចល្អឡើងពីកំណើតស្រាប់ ព្រមទាំងគុណលក្ខណៈគ្រប់ប្រការ ។

៤៥– សភាពមនុស្សលោកនេះ, បើមានទ្រព្យច្រើន សប្បាយចិត្ត បើធ្លាក់ខ្លួនជាអ្នកខ្សត់ទ្រព្យសម្បត្តិ សោកសៅក្តៅក្រហាយចិត្ត ធ្វើដូច្នេះឬអ្វី? ដោយពិតការធ្លាក់ទៅតាបទីង ការឡើងទៅខ្ពស់ជារបស់មនុស្សតាំងឡាយ ដូចជាបាល់ដែលគេបោះដោយដៃដូច្នោះទេ ។

៤៦– បុគ្គលកាលបើឃើញ នូវការរស់នៅនៃខ្ចាំ បន្ទក់ភ្ជក់នឹងការភ្ញាន់នៃកណ្តោរហើយ គប្បីប្រឹងប្រែងឲ្យ

កើតជាប្រយោជន៍រាល់ៗថ្ងៃ ដោយការទៀងទាត់ ដោយការសិក្សាក្បួនខ្នាត និងដោយការខំប្រឹងប្រែងធ្វើការងារ ។

៤៧- ការដូចម្ដេច ដែលហៅថាធ្ងន់ណាស់ សម្រាប់អ្នកមានសមត្ថភាព? ទីណាដែលឆ្ងាយណាស់ សម្រាប់អ្នកមានព្យាយាមច្រើន? ប្រទេសណា ដែលហៅថាបរទេស សម្រាប់អ្នកមានចំណេះវិជ្ជា នរជនណាដែលហៅថាអ្នកកន្ទៀតសម្រាប់អ្នកមានប្រិយវាចា? មួយទៀត សេចក្ដីអត់ធន់ណា ដែលធ្វើឲ្យការអត់ធន់ប្រពន្ធប្រើ?

៤៨- ទ្រព្យសម្បត្តិ មាននៅក្នុងសេចក្ដីផ្ទះថាវៃនៃអ្នកណា, ជ័យជំនះមាននៅក្នុងសេចក្ដីប្រឹងប្រែង នៃអ្នកណា, ម្រឹត្យបិតនៅក្នុងសេចក្ដីក្រោធនៃអ្នកណា, សេចក្ដីពិត អ្នកនោះ ៗ ឈ្មោះថាប្រកបហើយដោយតេជានុភាពទាំងពួង ។

៤៩- អ្នកស្វែងរកទ្រព្យសម្បត្តិ គួរគប្បីឲ្យរាតបង់មួយរយ តែមិនគួរឲ្យកើតរាំងមួយទេ នេះជាមតិរបស់អ្នក

ប្រាជ្ញសម្បើមមិនមានទម្ងន់ហេតុអ្វីជាមួយនាំ ហើយបង្កើតឱ្យកាន់វិញមួយដែរនោះ នេះជាលក្ខណៈមនុស្សល្ងង់ទេ ។

៨០ – មនុស្សមានវិបត្តិគ្រោះថ្នាក់ (ឈ្មោះតាសវែងគ្នា) ឲ្យសេចក្តីចំរើនដល់មន្ត្រី, មនុស្សឈឺឲ្យសេចក្តីចំរើនដល់ពេទ្យ, មនុស្សល្ងង់ជាការរស់នៅនៃអ្នកប្រាជ្ញ,. វណ្ណល្អទាំងឡាយ ជាការរស់នៅនៃសប្បុរសទាំងឡាយ ។

៨១ – នរជនណា បណ្តោយឱ្យសេចក្តីក្រោធគ្របសង្កត់ហើយធ្វើឲ្យកើតពិទនជននោះ រមែងដល់នូវសេចក្តីសាបសូន្យបាកទ្រព្យដែលខ្លួនកតូនហើយ ។

៨២ – នរជនអ្នកស្វែងទ្រព្យ, គប្បីថ្នាក់ថ្នមរក្សាចិត្តរបស់ខ្លួនដោយសតិយ៉ាងប្រពៃពុក ដូចជាបុគ្គលថ្នាក់ថ្នមភាជនៈដែលពេញដោយប្រេងដូច្នោះ ។

៨៣ – អ្នកមានប្រាជ្ញា បើទុកជាត្រូវស្លាប់ក៏មិនប្រកែក តែមិនព្រមឲ្យធ្លាក់ខ្លួនទៅជាមនុស្សក្រីក្រទេ, ដូចជាភ្លើងបើ

រលត់ហើយមិនឆាយត្រជាក់ភ្លាមទេ ។

៤៤– អ្នកមានប្រាជ្ញានឹងកូនផ្កាប៉ិកនៅក្នុងគតិពីរយ៉ាង គឺ៖ មួយនៅចំលើក្បាលនៃនរជនទាំងពួង ទីពីរស្ងាប់ស្រពោនក្រៀមស្អិតក្រញាន់នៅក្នុងព្រៃ ។

៤៥– អ្នកមានទ្រព្យឈ្មោះថា មានមិត្រ, អ្នកមានទ្រព្យឈ្មោះថា មានផៅពង្ស, អ្នកមានទ្រព្យឈ្មោះថា ជាបុរស, អ្នកមានទ្រព្យឈ្មោះថា ជាបណ្ឌិត ។

៤៦– បុគ្គលមានការចេះដឹងតិច កាលបើបានហោចទ្រព្យសម្បត្តិអស់ហើយ កិច្ចការឯទៀត ៗ ក៏ឈ្មោះថា វិនាសអន្តរធានទៅដែរ, ដូចស្ទឹងមានទឹកតិច កាលបើដល់គិម្ហរដូវក៏រីងស្ងួតហួតហែងអស់រលីង ។

៤៧– នៅក្នុងលោកនេះ, នរជនណាមួយ មានកាយធំទឹងមានកំពស់ប៉ុនកល្បព្រឹក្ស ៧ ក្តី មានពូជវង្សជាមួយព្រះបរ្ទូននិងព្រះមហាក្សត្រ តែព្រងើយសាសនាមិនជួយ មិនរៀន

ទ្រព្យសម្បត្តិហើយ គឺមិនមានគេគោរពបូជាដែរ, ព្រោះទ្រព្យជាទីពឹងរបស់មនុស្សទាំងពួងជាទីត្រូវទាំងអស់ ។

៥៨– ទោះបើនរជនណាមួយ ទោះបីជាក្រយ៉ាងណាក៏ដោយ តែមានទ្រព្យសម្បត្តិច្រើន នរជននោះតែងមានញាតិនៅ ទីងដោយមនុស្សមានជនផងដែរ ។ គេតែកោតខ្លាចកប់ក្រានគ្រប់កាលវេលា ។

៥៩– ជីវិតនៃនរជនណា សូម្បីមានការរស់នៅអស់រយឆ្នាំ ខ្ជិលច្រអូសមិនមានព្យាយាម រៀនសិល្បវិជ្ជា ស្វែងទ្រព្យនឹងធម៌បំរុងប្រាណ ជីវិតនៃជននោះឈ្មោះថា ឥតអំពើ, ដូចស្នប់ដែលគ្រាន់តែមានខ្យល់ចេញចូលតែប៉ុណ្ណោះ ។

៦០– ឯជីវិតនៃជនណា មានសេចក្ដីព្យាយាមដ៏មួនមាំ ចេះចាំវិជ្ជា មានទ្រព្យសម្បត្តិ នឹងមានធម៌ល្អ បានប្រតិបត្តិហើយជីវិតនៃជននេះសូម្បីមានការរស់នៅតែ១ថ្ងៃ ក៏

ឈ្មោះថាប្រសើរក្រៃលែង ។

៦១ – ជីវិតនៃជនណាមួយ មិនអើតអើតស្ងួមតាមភាពផ្ទះនៃជនដទៃ ដែលមិនធ្លាប់គប់ប្រសព្វសេចក្តីព្រាត់ប្រាសទុក្ខព្រួយ និងមិនដែលពោលពាក្យឥតខ្លឹមសារ, ជីវិតនៃជននោះឈ្មោះថាមានបុណ្យធំណាស់ហ្ន៎ ។

៦២ – នរជនដូចម្តេច កាលក្រឡេកមើលទៅខាងក្រោមឃើញជនជាន់ទាបជាងខ្លួន មិនឡើងជោរស្គមថាខ្លួនធំមហិមា តែកាលក្រឡេកមើលទៅលើឃើញជនជាន់ខ្ពស់ជាងខ្លួនទៀតដឹងថាខ្លួនជាអ្នកកំសត់ក្រៃលែង ។

៦៣ – បើបុគ្គលប្រាថ្នារបស់អ្វីក្នុងកាលណា សេចក្តីប្រាថ្នារបស់អ្នកនោះ តែងប្រព្រឹត្តទៅរឿយៗក្នុងកាលណោះ បើសេចក្តីប្រាថ្នាណា ដែលធ្វើឲ្យបុគ្គលស្ងប់ស្ងៀម ទ្រព្យរបស់បុគ្គលដែលគេបានមកនោះឈ្មោះថាជាទ្រព្យពិតប្រាកដ ។

៦៤ – បុរសមានទ្រព្យ, គប្បីលះបង់ប្រយោជន៍បុគ្គល

ម្នាក់ចោល ហើយធ្វើប្រយោជន៍ដល់ត្រកូល, គប្បីលះបង់ប្រយោជន៍ត្រកូលដើម្បីរក្សាភូមិ, គប្បីលះបង់ប្រយោជន៍ភូមិដើម្បីរក្សាប្រទេស, គប្បីលះបង់ប្រយោជន៍ប្រទេស ដើម្បីស្រោចស្រង់ខ្លួនមានការប្រតិបត្តិធម៌ជាដើម ។

៦៥– ទ្រព្យសម្បត្តិ ទុកដូចជាធូលីបាតជើង, យោវ្វនវ័យប្រៀបដូចជាខ្សែទឹកជ្រោះហូរខ្ចាញ់ចុះពីកំពូលភ្នំ ការមានអាយុរស់នៅយឺនយូរ ប្រៀបដូចជាការឃើញឃ្លោងនៃដំណក់ទឹកកម្រើក, ជីវិតសត្វប្រៀបដូចជាក្រពែងទឹក, អ្នកណាមានចិត្តគគាយ មិនប្រព្រឹត្តធម៌ដែលទុកដូចជាកូនសោចាក់បើកទ្វារទៅកាន់ស្ថានសួគ៌ទេ អ្នកនោះលុះត្រូវជរាបរឹតស៊ីឲ្យទ្រុឌទ្រោមហើយ រមែងឆេះដោយភ្លើងគឺសេចក្តីសោកសង្រេងសង្រែង និងសេចក្តីក្តៅក្រហាយ ស្តាយក្រោយមិនមានទីបំផុត ។

៦៦– អ្នកមានប្រាជ្ញា តែរក្សាទ្រព្យច្រើនរាសនាមិន

ជួយព្យាយាមបុរសក៏ឥតប្រយោជន៍ តើទីនស្មូនទៅរកសេចក្ដី
សុខឯណា ក្រៅពីការចូលទៅនៅព្រៃបួសយកភេទជា
សមណៈ ? ។

៦៧– បក្សីស្មូនគេរកចោះប៉ះភាគក្នុងអាកាស ត្រី
ស្មូនកេរកពោះលើផែនដី ក្រពើស្មូនគេចំណីក្នុងទឹក យ៉ាង
ណា ជនដែលប្រាថ្នាស្មូនគេព្រាញប៉ះកោតបានគ្រប់ទីកន្លែង
យ៉ាងនោះដែរ ។

៦៨– បុគ្គល មិនគប្បីប្រើងខ្វល់ខ្វាយទៀតហួសប្រមាណ
ពេក ព្រោះថា វាសនា កុសលនិងអកុសលបាននិម្មិតទុក
ហើយ (តែមិនត្រូវលះបង់ព្យាយាមពោល), ដូចជាដោះទាំង
គូនៃមាតា តែងបង្ហូរទឹកគ្បែរ ឲ្យទារកតាំងពីកាលប្រសូត្រ
ចេញពាកគតិម៉េះ? ។

៦៩– លោកណា ដែលសាងហង្សឲ្យមានពណ៌ស,
សាងសេកឲ្យមានពណ៌ខៀវ, សាងក្ងោកឲ្យមានពណ៌វិចិត្រ

ផ្សេង ៗ លោកនោះ ៗ ទើងតាក់តែងគ្រឿងចិញ្ចឹមជីវិតទុក សម្រាប់ជនភរិយាក៏យ៉ាងនោះដែរ ។

៧០ – ការស្វែងទ្រព្យបានក៏ទុក្ខលំបាកម្តង, កាលវិបត្តិទ្រព្យទៅបានសេចក្តីទុក្ខក្តៅក្រហាយម្តង, កាលបានសម្បូណ៌ទ្រព្យសម្បត្តិកើតមានស្រើនម្តងទៀត ដូច្នេះតើទ្រព្យសម្បត្តិទាំងឡាយនោះនាំឲ្យយើងបានសេចក្តីសុខដូចម្តេចហ្ន៎ ? ។

៧១ – អ្នកមានទ្រព្យតែងមានភ័យជានិច្ច កើតពីរាជភ័យ ពីចោរភ័យ ពីអគ្គិភ័យ ទឹងពីឧទកភ័យ, ដូចសត្វទាំងឡាយខ្លាចពីមរណៈភ័យដូច្នោះដែរ ។

៧២ – ដោយពិត, ទ្រព្យនេះគេរកបានមកដោយកម្រណាស់ រកបានហើយកម្រទុកដាក់ទៀត រកបានហើយវិនាសទៅវិញទៀត ដូចគេរកព្រម្រិត្យ (សេចក្តីស្លាប់) ព្រោះហេតុនោះបុគ្គលមិនត្រូវគិតពីទ្រព្យនេះពេកទេ គប្បីធ្វើជាទានដល់សមណៈព្រាហ្មណ៍ដែលមានសីលបរិសុទ្ធ ដើម្បីកសាងកសនា

ទៅអនាគតកាល ។

៧៣ – ក្នុងជីវិតដែល បរិបូណ៌ដោយសេចក្ដីលំបាកគ្រប់ប្រការនេះ ទឹងមានអ្វីឲ្យជាទុក្ខដ៏ក្រៃលែងជាងនេះទៅទៀតហ្ន៎ ? ។

៧៤ – ការយកភេទជាសមណៈ សូមតានគេប្រសើរ, សេចក្ដីសុខដែលកើតពីការចិញ្ចឹមជីវិត ដោយសារទ្រព្យជនដទៃមិនប្រសើរឡើយ, ការតាំងខ្លួនជាបុរសខ្ភយអំណាចប្រសើរ, ការលួចគរិយាអ្នកដទៃមិនប្រសើរឡើយ, ការនៅស្ងៀមប្រសើរ, ការពោលពាក្យកុហកមិនប្រសើរឡើយ, ការលះបង់ជីវិតប្រសើរ, ការពេញចិត្តស្ដាប់ពាក្យញុះញង់មិនប្រសើរឡើយ, ។

៧៥ – បុគ្គលមានចិត្តជាប់ដោយទ្រព្យ មិនមានចិត្តកើតពយ មានចិត្តមិនលះក្នុងអំណាចខ្លួន ទឹងមានខ្លួនមិនបានទុកនាន, សេចក្ដីអន្តរាយតាំងអស់តែងគ្រប់សង្កត់ចិត្ត នៃជនណាមួយ

ដែលមិនសន្តោស ។

៧៦– នរជនណាមួយមានចិត្តសន្តោសរីករាយ (បានលះបង់ទ្រព្យធ្វើជាទាន) នរជននោះឈ្មោះថាជាម្ចាស់នៃសម្បត្តិទាំងអស់, ដូចបុគ្គលពាក់ទ្រនាប់ជើងស្បែកដើរលើផែនដី ក៏ហាក់ដូចជាដីទាំងផែនដីមូលក្រាលពាសពេញដោយស្បែក មិនមែនដូច្នោះឬ ? ។

៧៧– សម្រាប់ជនខាងក្រោមនេះ អ្វីហ្ន៎ជាស្នេហា ? ភាពនៃបុគ្គលមានចិត្តសប្បុរស (ក្នុងការឲ្យទាន), អ្វីហ្ន៎ជាធម៌ ? សេចក្តីករុណាតែស្លូតសត្វលោក, អ្វីហ្ន៎ជាសុខ ? កិរិយាប្រាសចាកកេតកាព, អ្វីហ្ន៎ជាភាពនៃបណ្ឌិត ? ការដឹងកំណត់ប្រមាណខ្លួន ។

៧៨– ការបរិច្ចាគទ្រព្យសម្បត្តិ ដែលបុគ្គលសន្សំគតួននេះឯងឲ្យទៅជាទានឈ្មោះថា «កេរ្តិ៍ទ្រព្យសម្បត្តិ» ដូចជាទឹកជំនន់បរិច្ចាគទឹកដែលនៅក្នុងត្រពាំង ហើយពេញ

ដដែល វិញដូច្នោះ ។

៧៩– ទ្រព្យសម្បត្តិ, មប់ពពក, មេត្រីដោយមនុស្សសាហាវ, សំនួនជុំនឹងស្ត្រីក្រមុំ ...... ទាំងអស់នេះធ្វើឲ្យកើតសេចក្តីភ័យតែមួយខណៈ ។ ល ។

៨០– ក្នុងលោកនេះ, បើបុគ្គលរស់បង្គណាពេញបាន អ្នកណាធ្វើជាអ្នកក្រីក្រ ? បានអ្នកណាធ្វើជាអ្នកធំមានទ្រព្យ? តែបើបុគ្គលធ្វើខ្លួនឲ្យទៅជាខ្ញុំគេណាវិញ នោះឈ្មោះជាបណ្តោយឲ្យតាសភាពមកទុំលើតម្លៃរបស់ក្បាលប្រាកដតែម្តង ។

៨១ – ទ្រព្យដែលគេមិនបានឲ្យទាន ឬមិនហ៊ានបរិភោគខ្លួនឯង បានប្រយោជន៍អ្វី? ពេលវេលាដែលគេមិនបានយកទៅចម្រើនកុសល ស៊ូទឹងសត្រូវ បានប្រយោជន៍អ្វី? ការរៀនទឹងគម្ពីរធម៌អាថិទឹងក្បួនច្បាប់ បើគេមិនប្រព្រឹត្តតាមតើមានប្រយោជន៍អ្វី? ខ្លួនយើង បើមិនបានទំនាន់ឥន្ទ្រិយឲ្យមានបែបបទសណ្តាប់ធ្នាប់តើមានប្រយោជន៍អ្វី? ។

៨២ – ជីវិតនៃជនណា ដែលបណ្ដោយឲ្យថ្ងៃនិងយប់ ប្រព្រឹត្តកន្លងទៅទទេៗ មិនបានបរិច្ចាគទ្រព្យខ្លួនទៅជាទាន មិនរំសិកក្សនាគត ហើយប្រព្រឹត្តតាម និងមិនបរិភោគបំពេញផ្ទៃខ្លួនឯងទេ ជីវិតនៃជននោះ ដូចជាស្នប់នៃជាងដែក ស្ទូបស្រូសអាចដកដង្ហើមចេញចូលបាន ក៏ឈ្មោះថាស្លាប់ដែរ ។

៨៣ – មនុស្សកំណាញ់ តែងជីកកប់ទ្រព្យសម្បត្តិក្នុងខាងក្រោមដី ដោយហេតុឯណា, ដោយហេតុនោះមនុស្សកំណាញ់នោះឈ្មោះថាកសាងផ្លូវទៅខាងក្រោមគឺនរកទុកមុនៗ

៨៤ – នរជនណា កាលគិតតែពីបានទ្រព្យសម្បត្តិ តែងបិទផ្លូវសេចក្ដីសុខខ្លួនឯង, នរជននោះទុកដូចជាកែភារៈដ៏ធ្ងន់ឲ្យជនដទៃ យកខ្លួនជាភាជនៈ ទទួលតែទុក្ខលំបាកជំនួសគេទទេៗ (ព្រោះថាបើព្រះកាលមកនាំយកទៅហើយ លោកមិនឲ្យយកទៅតាមជាមួយផង) ។

៨៥ – ថាបើធ្វើជាសេដ្ឋី មានទ្រព្យច្រើន កំណាញ់

ស៊ុតហ្វាញមិនឲ្យមាន- ទំងមិនបរិភោគប្រើប្រាស់ខ្លួនឯង ឲ្យល្មមដល់ទ្រព្យ, នោះយើងទាំងអស់គ្នា គំះឈ្មោះថាមានទ្រព្យដូចជាសេដ្ឋីនោះដែរ មិនមែនដូច្នេះឬអី? ។

៨៦– ទ្រព្យសម្បត្តិនៃមនុស្សកំណាញ់ ទុកដូចទ្រព្យសម្បត្តិនៃជនដទៃស្រេចទៅហើយ ព្រោះមិនបានរើកយបរិភោគប្រើប្រាស់ដោយខ្លួនឯង ទំងមិនឲ្យជាទាន, បានតែពាក្យគេសរសើរថា "នេះជាទ្រព្យនៃអ្នកនោះ" ប៉ុណ្ណោះ លុះទ្រព្យនោះដល់នូវសេចក្តីសាបសូន្យទៅហើយ ឬក៏ខ្លួនត្រូវមរណៈនាំយកទៅបានតែសេចក្តីទុក្ខថែមទៀត ។

៨៧– ទ្រព្យនៃបុគ្គលកំណាញ់ មិនបានឲ្យទានដល់សមណៈព្រាហ្មណ៍ជាដល់ទេវតា ដល់ញាតិសន្តានទំងបរិភោគដោយខ្លួនឯងតែងវិនាសទៅដោយអគ្គិភ័យ ចោរភ័យ មរណៈភ័យ ។

៨៨– ទ្រព្យសម្បត្តិត្រូវមានគតិ ៣ យ៉ាងគឺ ចែកទៅ

ជាទានដល់ជនដទៃ ។ បរិភោគៈប្រើប្រាស់ដោយខ្លួនឯង ។ ទីង

វិនាសដោយហេតុផ្សេង ។ ទៅវិញ ។ អ្នកណាមិនបានឲ្យ

ជាទាន មិនបានបរិភោគខ្លួនឯង ទ្រព្យសម្បត្តិនោះធ្លាក់ទៅ

ក្នុងភក់ចេញ ៕

៨៩– ការឲ្យទានព្រមទាំងមានវាចាពីរោះ ។ ការចេះ

ដឹងព្រមទាំងការធ្លូនធ្លរ ។ សេចក្ដីក្លៀវក្លាព្រមទាំងការអត់ធន់ ។

ទីងទ្រព្យសម្បត្តិដែលប្រកបដោយការបរិច្ចាគទាន ។ មង្គល

ទាំង៤ប្រការនេះ កម្រកេបានណាស់ ក្នុងលោកនេះ ៕

៩០– ទ្រព្យណា ដែលគេឲ្យទាន ទ្រព្យណាដែល

ខ្លួនឯងបរិភោគទ្រព្យនោះ ។ ឈ្មោះថាជាទ្រព្យ នៃជនមាន

ទ្រព្យពិតប្រាកដមែន, ព្រោះថា បើខ្លួនមានទ្រព្យនោះស្លាប់

បាត់បង់ទៅ សម្បត្តិព្រមទាំងករិយា នឹងធ្លាក់ទៅជាគ្រឿង

វៀនដៃនៃជនដទៃពិត ។ ៕

៩១ – នរជនជាបណ្ឌិតមានប្រាជ្ញាល្អ តែងមិនរវល់

ចង់បានទ្រព្យសម្បត្តិ ដែលមិនត្រូវបាន (គង់សម្បត្តិប្រកបដោយទោស), មិនកើតទុក្ខសោកសៅក្តៅក្រហាយស្តាយទ្រព្យដែលវិនាសបាត់ទៅហើយ ... នឹងមិនរន្ធត់ជ្រប់ដល់ទៅបាត់ស្មារតីគង់ពេលដែលសេចក្តីក្រក្រមកដល់ប៉ុន្មាន ។

៩២– ទីឆ្ងាយដែលមានចម្ងាយ ១០០យោជន៍ មិនមែនជាឆ្ងាយណាស់ណាទេ សម្រាប់បុគ្គលជាប់តណ្ហា, ឯបុគ្គលមានស្រាស្នាសសម្បូរទ្រព្យមកដល់ដៃហើយ ក៏មិនរវល់អើពើប៉ុន្មាន ។

៩៣– បុគ្គលដែលផឹកអម្រឹតពោលគឺសន្តោស មានចិត្តក្សេមក្សាន្ត តែងបានទូវសេចក្តីសុខត្រជាក់ត្រជុំ, ឯបុគ្គលលោភដើររកទ្រព្យទៅខាងនេះ ទៅខាងនោះ ខ្វល់ចល់ញាក់ទ្រើក, តើបាននូវសេចក្តីសុខពីណា ? បុគ្គលគួរលះបង់ទ្រព្យដែលមានជាខាងរហើយកាន់យកភេទជាសមណៈ ស្វែងរកធម៌បុរាណទើបបានរកសេចក្តីសុខឃើញ ។

៩៤ – សូមឲ្យប្រជាជនទាំងឡាយសម្បូណ៌ដោយសេរីសម្បត្តិគ្រប់យ៉ាង, សូមឲ្យបានជាអ្នកព្យាយាមដ៏ខ្ជាប់ខ្ជួន, មានកិរិយាទាំងឡាយ សូមស្ថិតនៅលើជនអ្នកមានទ្រព្យ, សូម ..... ជនទាំងឡាយបរិបូណ៌ដោយទ្រព្យផង ដោយការឲ្យទានផង និងចាំអ្នកប្រតិបត្តិធម៌ដើម្បីទៅកាន់បរលោកផង ។

ចប់

# ទាសវគ្គ

១– បុគ្គលក្នុងលោកនេះ, ទោះប្រុស ស្រីក្តីចាស់ក្មេងក្តី ដែលបានកើតមកហើយ គួរកុំបណ្តោយខ្លួនឲ្យទៅជាខ្ញុំគេឡើយ ព្រោះថា អ្នកដែលទៅជាខ្ញុំគេតែងទទួលការៈដ៏លំបាក ត្រាតែអស់១ជីវិត សូម្បីតែអាហារត្រូវបរិភោគក៏មិនបានឆ្អែតប៉ុន្មាន ។

២– ចូរមើល ! គួរអាណិតអ្នកបំរើ ចូលចិត្តធ្វើខ្ញុំបំរើគេ ព្រោះតែចង់បានទ្រព្យ មនុស្សល្ងង់ចូលចិត្តទៅបំរើគេដរាប ដល់វិនាសឥស្សរភាពខ្លួនក៏មិនថា ។

៣– អ្នកធ្វើខ្ញុំបំរើគេ តែងអត់ទ្រាំលំបាកដោយត្រជាក់ ដោយខ្យល់ទឹកក្តៅថ្ងៃ ឥតបានប្រយោជន៍អ្វីសោះ, ឯអ្នកប្រាជ្ញខ្ញុំ ពេញកម្មៈ បើទុកជាលំបាកក៏បានសេចក្តីសុខជា

ផល ។

៤- ជនអប្បឥតប្រាជ្ញា សម្រាំងខ្លួនហើយសម្រាំងទៀតខ្លួនគ្រាន់តែបំរើជនដទៃជាទាស ព្រោះប្រាថ្នាទ្រព្យ, ដូចស្រ្តីជាមាសគូបតែខ្លួនឲ្យល្អទុកសម្រាប់តែបុរស ។

៥- ការតាំងខ្លួនមិនឲ្យជាប់ទ្រគេ តែងបានផលល្អសុខដល់ជីវិត, ថាបើជនណាមួយព្រមទៅក្នុងអំណាចគេ ហើយជននោះឈ្មោះថាមានជីវិត តើជនបែបណាវិញហ្នឹងដែលឈ្មោះថាស្លាប់ ? ។

៦- នាយទៅហ្វាយតែងត្រឡេកសំឡឹងមើលការខុសឆ្គងមិនបរិសុទ្ធជាប្រក្រតី នៃខ្ញុំបំរើដោយតែគណា អ្នកបំរើតែងតែរំពៃមើលតែកនោះ នៃម្ចាស់ដោយច្រើន ។

៧- នែអានេះ ! មកណេះ ! ទៅ ! ក្រោកឡើង ! និយាយទៅ ! នៅឲ្យស្ងៀម ! នេះជាសំដីពួកជនជាម្ចាស់ឬអ្នកធំមានសម្បត្តិច្រើន និយាយលេងផ្តេសផ្តាសចំពោះជនអ្នក

ក្រីក្រជាខ្ញុំបំរើដែលសេចក្ដីប្រាថ្នាទ្រព្យតាប់ត្រប្រាក់បានហើយ

៨– បើនៅក្រមដ៏មិនទំនាយយ៉ះច្រើនគេថាល្ងង់, បើនិយាយគេថា និយាយៈច្រើនពេកឬថាឆ្កួត; បើបេះអត់ធ្មត់គេថាខ្លាច, បើដើរមិនឈឺគេថា នាក់ជាតិ (ត្រកូលថោកទាប) បើនៅជិត គេថាហ៊ានពេក, បើនៅឆ្ងាយ ដោយមានទំនៃយគេថាញញើតញញើមពេក សូម្បីព្រះយោគី ក៏ផ្ចាប់ចិត្តម្ចាស់ឲ្យពេញបរិបូណ៌មិនបានដែរ, ដូច្នេះ! នាទីជាខ្ញុំបំរើគេនេះមានអាថ៌កំបាំងជ្រាលៈជ្រៅគួរតែស្ងួតណាស់តើ! ៗ

៩– អ្នកបំរើក្រោកឈរឬលើកដៃសំពះ ព្រោះតែម្ចាស់ក្រោក លះបង់ប្រាណ ព្រោះតែការពារជីវិតម្ចាស់ ទទួលសេចក្ដីទុក្ខទងឯង ព្រោះតែរកសេចក្ដីសុខម្ចាស់, ដូច្នេះខ្ញុំបំរើគេ! មានអ្វីល្ងង់ខ្លៅជាគតាបជាងនេះទៅទៀតហ្ន៎!

១០– នរជនណាព្រួយផ្ទួសគេ ទៅដែនយកការងារនៃជនដទៃមកធ្វើដំនួស ព្រោះតែប្រាថ្នាប្រយោជន៍ឲ្យនាយ

ទៅហើយ នរជននោះ ត្រូវគេសម្លាប់ចោលបង់ ហើយផែនដីកើត ផលប្រយោជន៍គ្មាន ។

១១– ធម្មតាមនុស្សជាតិដូចគ្នា ភាពជាខ្ញុំគេអ្នកប្រាជ្ញ តែងតិះដៀលដ៏ក្រៃលែង បណ្ដាខ្ញុំគេ អ្នកណាមិនបានធ្វើជាខ្ញុំគេទេ គួរកប់អ្នកនោះថាមានជីវិតរស់នៅនឹងគេដែរឬទេ ? ។

១២– រ៉ែធាតុដី ដ៏រ លោហធាតុ, រ៉ែឈើ ថ្ម សំពត់, រ៉ែនារី បុរស ទឹក ទាំងអស់នេះឃាតផ្សេងគ្នាជំណាស់ ។

១៣ – នរជនឥតប្រាជ្ញា ពិចារណាប្រយោជន៍ទទឹង មិនមែនប្រយោជន៍ ប្រព្រឹត្តកន្លងច្បាប់ច្រើនប្រការ មានប្រាជ្ញាគ្រាន់តែបំពេញផ្ទៃខ្លួនប៉ុណ្ណោះ នរជននោះហៅថាមនុស្សតិរច្ឆាន, ឯមនុស្សតិរច្ឆាននឹងបសុសត្វមានសេចក្ដីប្លែកគ្នាដូចម្ដេចខ្លះ ? ។

១៤– មនុស្សខ្លះចូលចិត្តនៅជាខ្ញុំបំរើគេ ត្រឹមតែ ៤ ប៉ុណ្ណោះ (៤/១០០) មនុស្សខ្លះទៀត សុខចិត្តនៅជាខ្ញុំបំរើគេលុះ

គ្រាតែ១០០.០០០បុកណៈ រីមនុស្សមួយពួកទៀតចិត្តប្រសើរ មិនសុខចិត្តនៅជាខ្ញុំបំរើគេ សូមឲ្យបានច្រើនជាង១០០.០០០ បុកណៈ ។

១៥– ជនណា ម្ចាស់មិនហៅ ដើរត្រគចូលទៅរក ម្ចាស់មិនសួរនិយាយថៃប៉ៃប្រច្រើន ដោយសំគាល់ខ្លួនថាជាទីគាប់ចិត្តនឹងជាទីស្រឡាញ់នៃម្ចាស់ជននោះឈ្មោះថា «ជនអប្បឥតប្រាជ្ញា» ។

១៦– ទោសត្រឡប់ទៅជាគុណ, គុណត្រឡប់ទៅជាទោសវិញ, ទីនះទោសនៅជាទោស គុណនៅជាគុណការ មិនមានលក្ខណៈជាម្ចាស់មាន៣ប្រការដូច្នេះ ។

១៧– ធម្មជាតិឆ្កែ បានឆ្អឹងសូម្បីអស់សាច់រលីងហើយ នៅសល់តែសរសៃ ខ្លាញ់ វាវ បន្តិចបន្តួច ក៏ត្រេកអររវើបរវុបដែរ, រីមនពិតឆ្អឹងនោះ មិនអាចឲ្យឆ្កែបង់សេចក្តីឃ្លានបានឡើយ ។

១៨– សេក្ខសីហៈ សូម្បីបានចចកមួយ មកនៅក្នុងក្រញាំខ្លួនហើយ ក៏នៅតែបោះបង់ចោល ហើយស្ទុះទៅចាប់សម្លាប់ដំរីសារមួយទៀត, ជនទាំងឡាយគោកយកលំបាកក្ដីណា តែងតែប្រាថ្នាចង់បាន ជាផលដ៏វៅតាមចំណង់ភាពខ្លួនជាសត្វលោក ។

១៩ – ឆ្កែលុតក្រោមជិតបាតជើងម្ចាស់ ហារមាត់បង្ហាញចង្កូម បក់កន្ទុយរវិច ៗ នៅទីដី ចាំទទួលសំណល់អាហារម្ចាស់បោះទៅឲ្យ, រីឯដំរីជាសត្វប្រសើរបៀនមើលម្ចាស់ដោយឫកមាំ លុះត្រាតែលួងលោមច្រើនយ៉ាងទើបបានបរិភោគ ។

២០– ជីវិតនៃមនុស្សណា សូម្បីតាំងនៅតែមួយខណៈ មិនបណ្ដោយខ្លួនឲ្យទៅជាខ្ញុំគេ មិនប្រាសចាកការបេះដូងសេចក្ដីព្យាយាមអង់អាចនិងកេរ្តិ៍ឈ្មោះយសស័ក្តិ អ្នកប្រាជ្ញពោលថា ជីវិតមនុស្សនោះពេញជាជីវិតដ៏ប្រសើរទៅនាលោក

នេះ ។ ព្រោះថាក្អែករស់នៅព្រោះតែការស៊ីវត្ថុសំណល់ តែគ្រឿងពលី ។

៤១– នរជនណាល្ងង់ សំគាល់ខ្លួនយ៉ាងនេះថា «អាត្មាអញគឺម្ចាស់ឬអ្នកធំ ប្រាជ្ញាសព្រាហ្មណ៍ហើយ» ដូច្នេះ នរជននោះគឺបុគ្គលគប្បីដឹងថា ទុកដូចជាគោបរោះដែលឥតស្នែង ។

៤២– សូមប្រជាជនទាំងឡាយរួចចាកក៏ខ្ញុំគេ សូមកុំពេញចិត្តនឹងការបំរើដទៃឡើយ, សូមឲ្យម្ចាស់ទាំងឡាយ ពោះបីអ្នកធំក្តី អ្នកមានទ្រព្យក្តី ស្គាល់នៅសេចក្តីនឿយព្រួយនៃជនអ្នកបំរើ ស្គាល់ដំរៀទឹកចិត្តអ្នកបំរើនឹងកុំគប្បីប្រើអំណាចរំលោភលើសិទ្ធិនៃជនទាំងឡាយនោះឡើយ, សូមឲ្យម្ចាស់ទាំងឡាយផង អ្នកបំរើទាំងឡាយផង ដល់នូវសេចក្តីសុខក្សេមក្សាន្តចាកទុក្ខ-ភ័យទាំងពួងសព្វកាលជានិរន្តរ ។

# មិត្តវគ្គ

១– បុគ្គលគប្បីស្វែងរកសេពគប់មិត្រឲ្យបានច្រើនចំនួនរាប់រយ ព្រោះថា ការអាស្រ័យមានអ្នកប្រាជ្ញមានចិត្តល្អ ជាមិត្រសម្ព័ន្ធត្រត់ព្រៀង ក៏អាចជួយកែខ្លួនឲ្យរួចគ្រោះថ្នាក់ឧបសគ្គៈបាន ។

២– ការចងបាច់វេញ្ញីតែមួយតូចៗ ឲ្យរួមគ្នាបាន ក៏អាចញុំាងការងារឲ្យសម្រេចប្រយោជន៍បាន ដូចជាប្រមូលវេញស្មៅជាទន្ទ្រាញអាចយកទៅចងដំរីចុះប្រេង ឲ្យជាប់ ទោលទៅណាមិនរួចបាន ។

៣– ការចងបាច់វង្សត្រកូលរបស់ខ្លួន សូម្បីតែបីនាក់ ក៏ជាការគាប់ប្រសើរណាស់ ដូចគ្រាប់ស្រូវដែលគេបកសំបកចេញហើយមិនអាចយកទៅសាបចណ្ដុះព្រោះពូជ ស្លូត

ណាស់ទៅបានទេ ។

៤– អ្នកមានចិត្តករុណាតែងពោលពាក្យទន់ផ្អែមជាទីគាប់ចិត្ត, អ្នកក្លៀវក្លាតែងមិនពោលអួតខ្លួន, អ្នកឲ្យទាន គឺឲ្យទានមិនរើសមុខ, អ្នកមានប្រាជ្ញាបណ្ឌិតភាពតែងមិនកោងកាច ។

៥– រីឯមេត្រីចិត្តនៃលោកសប្បុរសទាំងឡាយ សូម្បីមានទុក្ខសព្វមកដាច់ក្តីស្នេហាភ័ត្តា គុណប្រសើរមិនអាចផ្លាស់ប្តូរប្រែទេ ដូចដើមឈូក សូម្បីបាក់ពាក់កណ្តាលដើមក៏នៅតែមានជាប់សរសៃអន្ទាយ ។

៦– សន្តានចិត្តនៃលោកសប្បុរសទាំងឡាយ សូម្បីមានសេចក្តីក្រេវក្រោធកើតឡើង ក៏មិនអាចប្រែប្រួលអកប្បកិរិយា, ដូចជាគេមិនអាចយកគុបស្មៅ១គុបទៅដុតកំដៅទឹកសមុទ្រសាគរឲ្យក្តៅពុះទៅបានឡើយ ។

៧– ភាពជាបុគ្គលមានចិត្តបរិសុទ្ធ, ភាពជាបុគ្គលមាន

ចិត្តឲ្យទាន, ភាពជាបុគ្គលមានចិត្តមេត្តាករុណា, ភាពជាបុគ្គលមានចិត្តកប់អាន, ភាពជាបុគ្គលមានចិត្តទៀងត្រង់ ទាំងអស់នេះជាគុណសម្បត្តិនៃមិត្រ ។

៨– លោកអ្នកសប្បុរសទាំងឡាយ អាចជួយស្រោចស្រង់មិត្រចិត្តសប្បុរស ឲ្យរួចពីក្តីភ័យ ទុក្ខភ័យអស់កាលជានិច្ចបាន, ដូចដៃជួយប្រយុងដោះឲ្យផុតពីលង់ផុងជាប់ភក់បាន ។

៩– មិនពិត, សាធុជនមានចិត្តល្អ គេមើលទៅឃើញអាការៈដូចជាផ្លែដូង, ឯអ្នកដទៃទៀតមើលឃើញដូចផ្លែព្រា មានសំបកក្រៅរលោងស្រិលគួរជាទីពេញចិត្ត ។

១០– ជាតិលោហធាតុ ទាំងអស់អាចរលាយចូលគ្នាបាន ។ ព្រោះតែមានការរលាយជាលក្ខណៈ, ក្រុមបក្សីទាំងឡាយ រួបរួមចូលគ្នាជាហ្វូងបាន ព្រោះមានកងសាមគ្គីជាលក្ខណៈ, មនុស្សល្ងង់ដែលរួបរួមចូលគ្នាបាន ព្រោះមានភ័យធំលោភជាលក្ខណៈ, ឯសាធុជនមានមហាគុណ (ចិត្តល្អ)-

ប្រមូលគ្នាបានដោយទស្សនញ្ញាណ គឺស្គាល់ហេតុស្គាល់ផល ។

១១– ដរាបណា លោកប្រាសចាកពីសប្បុរសរឿយៗ ដរាបនោះ លោកនឹងធ្លាក់ទៅនៅក្នុងសង្គមអសប្បុរសរឿយៗ ដែរ ។

១២– នរជនមិនមានមិត្តចិត្តល្អ ឈ្មោះថាជាបុគ្គលសាបសូន្យ, ផ្ទះមិនមានកូនជាផ្ទះសូន្យស្ងាត់, ទិសមនុស្សល្ងង់ខ្លៅជាទិសសោះសូន្យ, សភាពអ្នកក្រីក្រជាសភាពសោះសូន្យជានិច្ចទាំងអស់ ។

១៣– ការចងស្ពានមេត្រីពិតអាចគ្នាជាប់រហូតដល់ថ្ងៃស្លាប់ជាទីបំផុត, សេចក្តីក្រេវក្រោធបាត់បង់ ខណៈនឹងការបរិច្ចាគទានឥតមានការលោះការល័យ នេះជាធម៌មាននៅក្នុងសន្តានចិត្តនៃបុគ្គលមានមហាគុណ ។

១៤– អ្នកដែលភ្ជាប់ចងស្ពានមេត្រីនឹងគ្នា ក្នុងដែល

កើតចេញពីទ្រូង១ អ្នកដែលជាប់ជាខ្សែស្រឡាយត្រូវជាវង្សត្រកូល១ អ្នកដែលការពារឲ្យផុតពីសេចក្ដីអន្តរាយ១ ទាំង៤ប្រការនេះបុគ្គលគប្បីដឹងថាជាវិធីត្រូវចងជាមិត្រ ។

១៥– វិស្សាសភាព នៃនរជនក្នុងមាតា, ក្នុងភរិយា, ក្នុងបងប្អូន, និងក្នុងបុត្រធីតា មិនស្មើដោយវិស្សាសៈភាពនៃមិត្រដែលកើតឡើងដោយសភាពប្រក្រតីមិត្រឡើយ ។

១៦– មិត្រភាពណា មានសភាពជាប្រក្រតីនិងមិត្រដែលកើតដោយបុណ្យប្រាថ្នា មិត្រភាពប្រកបដោយសភាពជាប្រក្រតីនោះ មិនលះបង់ចោលគ្នាក្នុងគ្រាវិបត្តិអន្តរាយឡើយ ។

១៧ - គេដឹងចិត្តមិត្រក្នុងគ្រាក្រ, ដឹងពាហនក្លៀវក្លាក្នុងសង្គ្រាម, ដឹងចិត្តស្មោះត្រង់ក្នុងកាលសងបំណុលគេ, ដឹងចិត្តភរិយាក្នុងពេលខ្សត់ទ្រព្យ និងដឹងចិត្តផៅពង្សក្នុងគ្រាវិនាសអន្តរាយ ។

១៨- អ្នកណា មិនលះបង់មិត្តក្នុងគ្រាទុក្ខ, គ្រាអន្តរាយ, ក្នុងគ្រាទុរ្ភិក្ស, ក្នុងគ្រាចលាចល, ក្នុងទ្វារព្រះរាជា, ទីងព្រៃស្មសានអ្នកនោះគេហៅថាជាមិត្តពិតវិញ ។

១៩- នរជនដទៃដែលធ្វើប្រយោជន៍ឲ្យយើងទុកជាមិត្តពិត, តែជាអ្នកមិនធ្វើប្រយោជន៍ឲ្យយើងក៏ទុកជាអ្នកដទៃ, រោគកើតក្នុងកាយយើងពិតៗ រកប្រយោជន៍គ្មាន ថ្នាំកើតក្នុងព្រៃធ្វើប្រយោជន៍ឲ្យយើង ។

២០- មិត្តណា ជាទីកើតសេនៃបីតិ ជាទីគាប់ភ្នែក ជាទីពេញចិត្ត ជាភាជន៍សម្រាប់ទទួលនូវសេចក្តីសុខ-ទុក្ខជាមួយគ្នា មិត្តនោះក្រកបានណាស់, មានមិត្តដទៃទៀតក្នុងសម័យមានទ្រព្យច្រើន, មិត្តណាមកពាំអានព្រោះតែចង់បាននូវគឺទ្រព្យមិត្តនោះឃើញមិនដេរជាសត្រូវចំពោះ, គ្រោះវិបត្តិទុកជាថ្មសម្រាប់ល្បងមើលមាសសុទ្ធ គឺមិត្តពិតទាំងឡាយនោះៗ ។

៦១– សភាព (លក្ខណៈ) នៃបុគ្គលទាំងអស់ក្នុងលោក នេះគេមើលឃើញច្បាស់ប្រាកដ, តែគុណធម៌ទាំងឡាយនៃបុគ្គលគេមើលមិនឃើញដោយងាយទេ, សភាពនៃបុគ្គលនិមួយៗ ក៏បាត់បង់នូវគុណធម៌ទាំងពួង ហើយចូលទៅស្ថិតនៅលើក្បាលបាន ។

៦២– ក្នុងលោកនេះ, មិនមានបុណ្យរាសនាជាងអ្នកជួបប្រទះសន្ទនាកកាយជាមួយនឹងមិត្រ, អ្នកដែលស្និតនៅរួមមួយអាទ្រីដោយមិត្រនឹងអ្នកដែលប្រាស្រ័យ ប្រាប់សុខទុក្ខទៅវិញទៅមកមួយអាទ្រីដោយមិត្រដូច្នេះទេ ។

៦៣– ទោះបីសត្វតិរច្ឆាន ដែលប្រព្រឹត្តល្អតែម្យ៉ាង; វិសេសៈស្និទ្ធស្នាល អាចឲ្យគេឃើញស្និទ្ធស្នាលបាន, ដូចជាសភាពនៃលោកសប្បុរសទាំងឡាយ នឹងជាប្រព្រឹត្តទៅផ្សេងក៏ឥតអ្វីមានឡើយ ព្រោះលោកមានសភាពសប្បុរសជាប្រក្រតី

៦៤– នរជនណា មិនជឿស្តាប់ភាសិតមិត្រសំឡាញ់

ដែលប្រាជ្ញាធ្វើប្រយោជន៍ឲ្យ, ក្ដីគយន្តកយស្ថិតនៅជិតអ្នក
នោះ, នរជននោះឈ្មោះថាធ្វើសេចក្ដីគ្រោះអវឲ្យសត្វ ។

២៥– កិរិយាមុជទឹកជ្រៅត្រជាក់ត្រជុំក្ដី, កិរិយាប្រដាប់
ដោយគ្រឿងដ៏ហើយដោយកែវមុត្តាក្ដី, កិរិយាប្រសព្រំតន្ត
ដោយគ្រឿងក្រអូបមានខ្លឹមច័ន្ទន៍ក្ដី និងជាធ្វើឲ្យបុគ្គលដែលក្ដៅ
អ្នកដោយកំដៅឲ្យត្រជាក់ស្រួល ក៏មិនមែន, តែមិនប្រសើរជាង
កាសិតនៃលោកសប្បុរសទាំងឡាយ ដែលចូលទៅប៉ះពាល់
ដោយក្ដីត្រជាក់មុតដោយបិតស្រះទ្រូងដ៏ក្រៃលែង ព្រោះលោក
ទុកកាសិតជាត្រម្ទុះ ដូចជាមន្តសម្រាប់ស្រូបយកចិត្តលោក
សប្បុរសទាំងឡាយ ។

២៦– ការសេពគប់នូវជនជាបណ្ឌិតទាំងឡាយ ១, ការ
បូជាដល់បុគ្គលដែលគួរបូជា ១ ការជាអ្នកមានបុណ្យបានធ្វើ
ទុកក្នុងកាលមុន ១ ការទូន្មានឥន្ទ្រិយ៍ឲ្យដល់នូវធម៌ស ១ ទាំង
៤នេះជាមង្គលដ៏ប្រសើរ ។

២៧- ការជាបុគ្គល បានរៀនសូត្រនឹងស្ដាប់ច្រើន១ ជាអ្នកស្ទាត់ជំនាញក្នុងទីសិល្បសាស្ត្រ ១ មានសេចក្ដីឈ្លៀវឆ្លាស ក្នុងការហាត់កម្មនឹងពាណិជ្ជកម្ម ១—ការពេះពោលពាក្យពីរោះ ផ្អែមល្ហែមទៅតាមកាល១ ទាំង៤នេះក៏ជាមង្គលដ៏ប្រសើរ, ។

២៨- កិរិយាផ្គត់ផ្គង់បំរើមាតា១ បំរើបិតា១ សង្គ្រោះដល់បុត្រនឹងភរិយា១ មានការងាររមិនច្របូកច្របល់គ្នា១ នឹងការងាររមិនមានទោស១ ទាំង៥ប្រការនេះជាមង្គលដ៏ឧត្តម ។

២៩-ការលះទ្រព្យជាទាន១ កិរិយាមិនសេពគប់ទុជ្ជន១ សេចក្ដីសង្គ្រោះដល់ញាតិនឹងមិត្រ១ ការមិនផឹកទឹកស្រវឹង១ នឹងគោរពដល់បុគ្គលគួរគោរព១ ទាំង៥នេះជាមង្គលដ៏ឧត្តម ។

៣០- ជាតិវិមច័ន្ទ សូម្បីមានដើមឆាប់ស្វិតក្រៀមក្រញាំ ក៏មិនអាចលះបង់ខ្លួនក្រអូប, ដំរីដ៏ប្រសើរដែលចូលទៅកាន់ទីសមរភូមិក៏មិនអាចលះបង់ដំណើរល្គនល្គាយ ជាតិអំពៅ

បើរុកជាគេយកទៅដាក់ក្នុងគាបហើយគាប កំមិនលះបង់សភាពផ្អែម, យ៉ាងណា, ឯជាតិបណ្ឌិតតែងមិនលះបង់មិត្រចិត្តមួយទឹងធម៌ល្អ សូម្បីមានសេចក្តីអន្តរាយមកដល់ខ្លួនយ៉ាងនោះ ៗ

៣១ – សម្រាប់ជនក្នុងលោកនេះ, អ្វីហ្ន៎ជាភាពនៃបណ្ឌិត? ការដឹងកំណត់ប្រមាណខ្លួន, អ្វីហ្ន៎ជាសេចក្តីស្នេហា? ភាពនៃបុគ្គលជាសប្បុរស, អ្វីហ្ន៎ជាសុខ? ការប្រាសចាករោគាពាធ, អ្វីហ្ន៎ជាធម៌? គឺការអាណិតអាសូរដល់សត្វលោក ៗ

៣២– មែនពិត, ភាពនៃបណ្ឌិតគឺការដឹងនូវកំណត់ប្រមាណខ្លួនកាលមានហេតុវិបត្តិកើតឡើង នរជនដែលមិនដឹងការកំណត់ប្រមាណខ្លួន តែងគប់ប្រសប់ក្តីវិបត្តិអន្តរាយគ្រប់ដំហានដើរ ៗ

៣៣– ព្រឹក្សាជាតិ មានពិសពុលគឺសំសាក់ផ្លែះ មាន

ផលទុកដូចជាមានរសផ្អែមតែពីរប្រការ គឺចំអ៊ាញ នៃរសទឹកអម្រឹតពោលគឺពាក្យកាព្យឃ្លោង និងសុភាសិត១, សមាគមមួយអន្លើដោយសប្បុរសទាំងឡាយ១ ៗ

៣៤– ចិត្តមិនមាំក្នុងគ្រាទុក្ខព្រួយ, ចិត្តអត់ធន់ក្នុងគ្រាសុខចំរើន សេចក្ដីអង់អាចក្នុងទីប្រជុំដោយសំដីថ្វីមាត់, ចិត្តក្លៀវក្លាក្នុងរណរង្គ, ចិត្តត្រេកអរក្នុងយស, និងចិត្តស្រវ់ស្រទេញក្នុងការប្រឹក្សា ទាំងអស់នេះជាលក្ខណៈមានជាប្រក្រតីចំពោះតែបុគ្គលមានមហាគុណ(១) ៗ

៣៥– អ្នកណាមិនះកពយ ហួសហេតុក្នុងគ្រាបានសុខចំរើន មិនរួចកំឡាំងចិត្តក្នុងគ្រាទុក្ខព្រួយ, មានសេចក្ដីក្លាហានក្នុងរណរង្គ មាតាដែលបង្កើតកូនមានលក្ខណៈបែបនេះ ក្នុងលោកនេះកម្រមានណាស់ ៗ

៣៦– នរជនណា លះបង់របស់ទៀងទាត់ទៅស្រវ់

(១)អ្នកមានចិត្តប្រសើរ

យករបស់មិនទៀងទាត់វិញ របស់ទៀងទាត់ក៏វិនាសបាត់សូន្យទៅ របស់ដែលមិនទៀងទាត់ក៏ហិនហោចបាត់ទៅទៀតដែរ ។

៣៧– បុគ្គលមានឥច្ឆាឈ្នានីស, បុគ្គលពោលពាក្យរិះគន់, បុគ្គលមិនសន្តោស, បុគ្គលមានក្រោធច្រើន, បុគ្គលមានតែសេចក្ដីរង្កៀសជានិច្ច និងបុគ្គលពឹងផ្អែកស៊ីតែដោយសារបុគ្គលដទៃ បុគ្គលទាំង ៦ បែបនេះ ត្រូវទទួលចំណែកនៃសេចក្ដីទុក្ខ ។

៣៨– ក្នុងលោកនេះទោស ៦ ប្រការ បុគ្គលដែលប្រាថ្នាសេចក្ដីសុខចំរើនគួរគប្បីលះបង់ចោល គឺដេកច្រមក់១ ខ្ជិលច្រអូស១ ភយ ១ ក្រោធ១ ទន្ធមុខ ១ និងឡេះឡាយយឺតយូរក្រោយគេ១ ។

៣៩– មាតា មិត្រ និង បិតា ត្រៃអង្គនេះ ជាអ្នកធ្វើហិតានុហិតតាមសភាពរបស់ខ្លួន, ឯអ្នកដទៃខ្លះទៀត ក៏ធ្វើហិតានុហិតបែបនេះដែរ ព្រោះគេយកនាទី មាតា មិត្រនិង បិតា

មកទុកជាដើមហេតុ ។

៨០- កិរិយាខ្មាយនូវអាថ៌កំបាំងក្តី លោភសម្ភក្តី ភាពជាបុគ្គលមានចិត្តរឹងរូសក្តី ភាពជាបុគ្គលមានចិត្តរបុលរបូចក្តី ភាពជាបុគ្គលមិនមានពាក្យសច្ចៈក្តី សេចក្តីក្រោធច្រើនក្តី ស្រវឹងល្មុកគន់លេងល្បែងក្តី ទាំងអស់នេះជាគ្រឿងប្រទូស្តនៃមិត្រ ។

៨១- ពាក្យសំដី បុគ្គលគប្បីរក្សាទុកគ្រប់កាលទាំងពួង ព្រោះក្តីវិនាសមកតែពីពាក្យសំដីអាក្រក់ ឬពាក្យសំដីដែលគេហាម, តែបើពាក្យសំដីណាល្អគួរនឹងនិយាយ ដែលគប្បីនឹងបានចំរើន ក៏និយាយទៅតាមកាលសម័យចុះ ។

៨២- នរជនណា មិនត្រេកអរចំពោះពាក្យជាសំតៀននៃមិត្រដែលប្រាថ្នាប្រយោជន៍ឲ្យ នរជននោះត្រូវវិនាសដូចជាអណ្តើកល្ងង់មិនជឿពាក្យហង្ស ជាសម្លាញ់ទាំងពីរដែលពាំនាំយកទៅ ដកបតែភ្លាត់ធ្លាក់ស្លាប់នោះហោង ។

៤៣– វាចាត្រជាក់មិត្រតែងចំរើន វាចាក្ដៅអាក្រក់តែងវិនាសមិត្រ, ដូចជាព្រះចន្ទ្រតែងជាទីគាប់ចិត្តជនគ្រប់ប្រភេទ, ឯព្រះអាទិត្យ តែងមិនពេញចិត្តដល់ជនអ្នកក្ដៅផ្លោះដែរ ៗ

៤៤– ដោយច្រើន មនុស្សនៅនាផ្ទៃក្រោមនេះ តែងមើលឃើញតែទោសរបស់គេ សូម្បីប៉ុនគ្រាប់ល្ង, ឯទោសរបស់ខ្លួន សូម្បីធំប៉ុនដូងទាំងសំបកក៏មើលមិនឃើញដែរ ៗ

៤៥– ផ្គាប់អ្នកមានចិត្តលោភ ដោយគ្រឿងរបស់ ផ្គាប់អ្នកធំមានបុណ្យស័ក្ដិដោយលំអុតលំឱនប្រណាម្យ, ផ្គាប់អ្នកប្រកបដោយមោហៈដោយពាក្យតាមបណ្ដោយ និងបញ្ជោរ ឯផ្គាប់បណ្ឌិតវិញ គប្បីពោលតែពាក្យសត្យ ៗ

៤៦– បុគ្គល គប្បីវៀរមិត្រ ដែលបង់បង្ខាញការងារ ក្នុងទីកំបាំងមុខ ហើយនិយាយពាក្យផ្អែមល្ហែមក្នុងទីចំពោះមុខ មិត្របែបនេះ ប្រៀបដូចជាឆ្នាំងដែលពេញដោយថ្នាំពិសពុល មានប្រឡាក់ដោយទឹកដោះផ្អែម ៕

៤៧– មនុស្សចិត្តអាក្រក់១ ពស់១ ក្របី១ ចៀម១ ទាំង ក្អែក១ មនុស្សមានសភាពទាំង៤នេះ បានសេចក្តីចំរើនព្រោះ តែអាងកាយសៀតវែបធ្វើវិស្សាសៈស្និតស្នាល, ព្រោះហេតុ នោះ បុគ្គលមិនគប្បីប្រគល់ឲ្យនូវវិស្សាសៈស្និទ្ធស្នាលចំពោះ បុគ្គលមានសភាព៤ពួកនេះឡើយ ។

៤៨– ជនណា ទៅចងមិត្រស្និទ្ធស្នាលនឹងសត្រូវ ឬភ-រិយាដែលមិនមានចិត្តប្រតិព័ទ្ធចំពោះខ្លួន ដោយអាងថាមាន ទ្រព្យសម្បត្តិច្រើន ជីវិតនៃជននោះឈ្មោះថាចូលទៅដល់ទីបំ ផុតនៃត្រត្រឹមនោះហើយ ។

៤៩– បុគ្គលមិនគប្បីស្និទ្ធស្នាលទុកចិត្ត មនុស្សទុជ៌ន, ទឹកទន្លេ, បុគ្គលមានសស្ត្រាវុធក្នុងដៃ, ជនបរទេស, សត្វមាន ក្រចកមុត, សត្វមានស្នែង, សត្វមានចង្កូមអសេរពិស ទាំង ស្រីក្នុងរាជត្រកូលទាំងឡាយ ។

៥០– បុគ្គលមានចក្ខុសាមាន្យ ទាំងសំគាល់បានដោយ

អាងហេតុថា «បេះពោលធម្មសាស្ត្រក៏មិនមែន» ឬថា "បេះស្វាធ្យាយធម្មសាស្ត្រក៏មិនមែនដែរ», មធុរសនៃទឹកដោះគោរមែងផ្អែមល្ហែមទៅតាមប្រក្រតីរបស់ទឹកដោះ យ៉ាងណា, សភាពនៃសត្វលោកក្នុងសំសារវដ្តនេះ លោកពោលថាដូចគ្នានោះឯង ។

៩១– បុគ្គលមិនគប្បីចងស្ពានមេត្រីឬធ្វើសន្តិភាពមួយអន្លើដោយមនុស្សទុជ៌នឲ្យសោះ, ព្រោះដូចធ្យូងបើកាលនៅក្តៅរមែងរលាកដៃ បើត្រជាក់រលត់ហើយរមែងប្រឡាក់ដៃទៀត ។

៩២– រីមនុស្សទុជ៌ន សូម្បីប្រដាប់ដោយគ្រឿងអម្ពរណ៍គឺចំណេះវិជ្ជា ក៏បុគ្គលគប្បីចៀសវាងឲ្យផុត ដូចសត្វអសេរពិស សូម្បីប្រដាប់ដោយកែវមណី រមែងមិនគួរយើងឲ្យភ័យឬអ្វី ? ។

៩៣– មែនពិត, មេត្រីនៃបុគ្គលមានចិត្តបរិសុទ្ធមានសភាពយ៉ាង, ឯសភាពនៃបុគ្គលចិត្តអាក្រក់មានសភាពយ៉ាង

ទៀត ។

៩៤- មនុស្សចិត្តអាក្រក់ ចិត្តគិតវៀច, សំដីនិយាយវៀច, កិរិយាប្រព្រឹត្តក៏វៀចទៀត, ឯបុគ្គលមានចិត្តមហាត្ម័ខ ចិត្តគិតសំដីនិយាយ នឹងកិរិយាធ្វើប្រព្រឹត្ត ធ្វើតែមួយ ។

៩៥- នរជនណា ចង់ចងសម្ពន្ធមិត្រ មេត្រីភាពម្តងទៀតចំពោះមិត្រដែលបានប្រទុស្តិ៍ម្តងរួចហើយ នរជននោះឯង៖ ឈ្មោះថា ទៅកាន់យកម្រិត្យតែម្តង ដូចមេសេះពផ្ទៃសេះអស្សតរដូច្នោះឯង ។

៩៦- ពាក្យដែលទុជ៌នពោល សូម្បីនិយាយញញឹមស្រស់ពីរោះផ្អែមដូចផ្ការីកពុំជួនកាល ក៏ញ៉ាំងភ័យឲ្យកើតឡើងបាន ។

៩៧- សេចក្តីពិត, សភាពនៃជនណាដូចម្តេច ជននោះមិនអាចកន្លងសភាពខ្លួនបានឡើយ បើលើកសុនខជាតិឲ្យធ្វើជាស្តេច នឹងមិនអង្គាមព្រួនាប់ស្បែកជើងឬអី ? ។

៤ ៥៨ របស់ណាអាចរបស់នោះនៅតែអាចពិតប្រាកដ,របស់ណាមិនអាចរបស់នោះ នៅតែមិនអាចពិតប្រាកដ, ដូចរទេះ
៥ បរទៅលើទឹកមិនរួចទេ ឯទូកក៏អុំលើគោកមិនបានដូច្នោះដែរ ។

៥៩– ទីណា មិនមានចាស់ព្រឹទ្ធាចារ្យ ទីនោះមិនមែនជាសភាទេ, នរជនណាមិនពោលធម៌ នរជននោះមិនមែនជាចាស់ព្រឹទ្ធាចារ្យទេ, ទីណាមានតែប្រវ៉ាន់ ទីនោះមិនមានពាក្យសត្យទេ ។

៦០– បើអ្នកណានិមួយ និយាយថាខ្ញុំមិនមានចិត្តអាក្រក់ព្យាបាទទេដូច្នោះក៏ដោយ បុគ្គលមិនគួរជឿពាក្យនេះ យកជាហេតុជាមិត្រស្និទ្ធស្នាលឡើយ, សេចក្ដីពិត អ្នកដែលមាន
១ គុណគឺការចេះដឹងច្រើន ក៏តែងមានភ័យកើតមកពីមនុស្ស
៨ ទុច្ចរិតទាំងឡាយដែរ ។

៦១– មិត្រណាជាទីស្រឡាញ់ពេញចិត្ត បើទុកជាកុហកបោកប្រាសយើងខ្លះ មិត្រនោះនៅតែជាទីពេញចិត្តដដែល,

ដូចកងកាយយើង ទុកណាជាមានគេតាមកបៀតបៀនប្រទុស្ត សព្វទាំងអស់ អ្នកណានឹងលះបង់មិនស្រឡាញ់កងកាយនេះបាន, នេះជាពាក្យៈបាកប្រាសនៃបុគ្គលទុជ៌នដែលប៉ងមកសម្ពន្ធមិត្រទៀត ។

៦២– មិត្រណាជាទីស្រឡាញ់ពេញចិត្ត សូម្បីធ្វើឲ្យយើងមិនពេញចិត្ត ច្រើនយ៉ាង. មិត្រនោះនៅតែជាទីស្រឡាញ់ពេញចិត្តដដែល, ដូចភ្លើង សូម្បីឆេះមន្ទីរមហាសាលហើយ អ្នកណាមួយដែលមិនទិយមកបអានភ្លើងទៀត, នេះក៏ជាពាក្យពាយផែបរបស់ទុជ៌នដែរ ។

៦៣– បុគ្គល គប្បីចៀសវាងសត្វមានស្នែង ៥០ហត្ថ សត្វរតលៀនដូចសេះ១០០ហត្ថ សត្វមានភ្លុកដូចដំរី១.០០០ ហត្ថ, ឯចៀសវាងពាលទូជិនដោយផ្លាស់ចាកទីកន្លែងនឹងកុំស្តីតប ។

៦៤– ម្ចាស់ណាជាអ្នកប្រវ័ញ្ចន៍, កំណាញ់, បំបាត់

គុណ, ប្រកបអត្ថ ទើបយកបុណ្យគ្រប់សង្កត់ ម្ចាស់មាន សភាពបែបនេះ បុគ្គលក៏គួរកុំសេពគប់ឡើយ ។

៦៥– បុគ្គលកុំគប្បីមេត្រីស្និទ្ធស្នាល ទើបបុគ្គលកាចកក្រោលឲ្យសោះ ទោះមានបុណ្យធំប៉ុណ្ណាក៏ដោយ, ព្រោះជាហេតុនាំឲ្យកើតកលហ ដូចគួមមានទឹកតិចកន្ទុះ បើបុគ្គលចូលលើក្បាលហើយទើបមិនត្រលែងឬ ? ។

៦៦– ម្ចាស់ភ្នាប១ លោភ១ គិតតែប្រយោជន៍ខ្លួន១ ចិត្តដាស់ប្តូរ១ មិនមានពាក្យសត្យ១ អ្នកបរទេស១ ជាទើប ពាក្យសរសើរ១ ទើបប្រព្រឹត្តខុសកង់កូនប្រពន្ធគេ១ ម្ចាស់ដែលមានលក្ខណៈពាំងនេះ ក៏គប្បីលះបង់ចោលដែរ ។

៦៧– គួរកុំគប្បីបិតនៅ ឬដើរទៅជាមួយមនុស្សអាក្រក់ សម្បី ទុម្ពយពេកឲ្យសោះ, ព្រោះជាការនៅជាមួយមនុស្សអាក្រក់នាំឲ្យកើតអសន្តិសុខ, ការសេពគប់ ឬនៅជាមួយខ្មីនសប្បុរស ឈ្មោះថាបានសន្តិភាព ។

៦៨– ជនពាលតាញ្ញកល់អាចញ៉ាំងជនដែលមានសេរី ឲ្យប្រព្រឹត្តក្រក់តាមបាន ព្រោះមានបំណងចង់បានប្រយោជន៍ខ្លួន, ការសេពគប់ជនពាលប៉ុនកល់នេះ មិនខុសដូចជាការលេងប្រឡែងជាមួយភ្លើង ឬ អ្វី ? ។

៦៩– ក្នុងលោកនេះ បើគេនិយាយឲ្យស្ដាប់ចិត្តដោយប្រើពាក្យឲ្យផ្អែមល្ហែមដូចទឹកឃ្មុំ, បើគេធ្វើឲ្យលុះក្នុងអំណាចនៃខព្ញាយមិច្ចាហើយ, បើគេមកពឹងពាក់ដោយធ្វើឲ្យជឿទុកចិត្តដូច្នេះ តើអ្នកណាឡើយ ដែលគេមិនបោកបញ្ឆោតបាន ? ។

៧០– លក្ខណៈមនុស្សទុជ៌ន, នៅមុខវាលុតក្រាបសំពះជិតបាតជើង នៅក្រោយអ្នកវាបេះឆ្អឹងជំនីស៊ី វានិយាយពាក្យផ្អែមល្ហែមល្អក់ល្អន មានលៃបខាយដល់ចិត្តល្ហិម ។ ជិតត្រចៀកអ្នក បើមានពេលចន្លោះវាលបចូលទៅបេះថ្លើមប្រមាត់ បេះដូងមួយរំពេចឥតកោតញញើតឡើយ ។ សត្វរុយវាបេះធ្វើគ្រាប់លក្ខណៈមនុស្សទុជ៌នទាំងអស់ ។

៧១– មនុស្សទុជ៌ន និយាយពីរោះគួរជាទីពេញចិត្តតែ មិនត្រូវយកជាហេតុមកស្និទ្ធស្នាល ព្រោះដោយសំដីពីរោះនោះទេ, ប្រៀបដូចទឹកឃ្មុំដែលជាប់នៅចុងអណ្ដាត គង់ចិត្តពេញដោយពិសពុលដ៏ក្ដៅក្រហាយពេលកល ។

៧២– បើជាសត្រូវហើយ បុគ្គលគួរកុំជឿទុកចិត្តស្និទ្ធស្នាលចងស្ពានមេត្រីឲ្យសោះ, ដូចជាទឹកដ៏ក្ដៅជាពុះខ្លាំងក្រៃ ។ ក៏អាចរំលត់ភ្លើងបាន ។

៧៣– ទៀនណាស់, មតិនៃសប្បុរសតាំងឡាយក៏អាចទន់ទេរទៅតាមសំដីទុជ៌នតាំងឡាយដែរ ជនដែលជឿទុកចិត្តទុជ៌នតាំងឡាយនេះ ក៏ដល់នូវសេចក្ដីវិនាសពិតប្រាកដ ។

៧៤– បុគ្គលគប្បីដឹងថាសេះលឿនត្រូវមើលសន្ទុះ មើល[illegible]មានកម្លាំងដោយផ្ទុកធ្ងន់ ដឹងទឹកដោះល្អមើលចុងថនា, ឯមេធាវីបណ្ឌិតដឹងពាក្យសត្យ ។

៧៥– ពេលធ្វើការជាការត្រូវដឹងចិត្តខ្ញុំបំរើល្អ និងអា.

ក្រក់ ពោះឋមានទុក្ខជាការត្រូវដីដល់វង្សត្រកូល ពេលគ្រោះ ថ្នាក់អគ្រក់ជាការត្រូវដីឯចិត្តមិត្រ ការវិនាសអស់ទ្រព្យ សម្បត្តិជាការត្រូវដីឯប្រពន្ធល្អ ...ៗ...

៧៦– អ្នកណាហ្ន៎ ចង់ចងពន្ធនឹងមនុស្សទុជ៌ន ? នរណាហ្ន៎នឹងមិនក្ដាញ់ បើមានគេសូមញយៗ ? នរណាហ្ន៎ដែលបានទ្រព្យហើយមិនរីកពយ ? នរណាហ្ន៎បានជាបណ្ឌិតហើយ មិនតាញ់កល់ក្នុងពិធីទុច្ចរិត ?

៧៧– ន ! ព្រះម្ចាស់ផែនពសុធាដ៏មានបុណ្យអើយ! ហេតុអ្វីកលោកព្រមទទួលទ្រមនុស្សទុជ៌នធបោកគេ ដែលគេប្រគល់ជំនឿគឺជឿទុកចិត្តអស់ពីពោះពីពុង នឹងដែលគេមានបរិសុទ្ធ ឲ្យនៅលើផ្ទៃផែនដីនេះដូច្នេះហ្ន៎ ? ៗ

៧៨– សូមសាធុជនទាំងឡាយ សាមគ្គីមូលត្រកូល ចងបាច់គ្នា ជាសាមគ្គីឲ្យមានមិត្រភាព! សូមប្រើជាជនក្នុងជន បទសម្បូណ៌ដោយសេរីសម្បត្តិគ្រប់ប្រការ សូមព្រះភូមិបាល

គេគ្រូប្រដាផងទៅលើផែនពសុធាដោយប្រពៃ ,  សូមទ្រង់ព្រះករុណាគ្រប់ព្រះអង្គព្រមទាំងមន្ត្រីគ្រប់ដំណែង  មានសេចក្តីពេញចិត្តនិយមប្រើនីតិសាស្ត្រ ទុកនីតិសាស្ត្រដូចជាព្រះជាយាថ្មីមួយព្រះអង្គទៀត! សូមព្រះមហាទេពដ៏មានបុណ្យជាំចមអមរនិករដ៏ទ្រទ្រង់នូវចន្ទ្រាចូឌាមណីប្រសិទ្ធិ ពរបវរសួស្តីផលមហាផនឲ្យប្រកបដោយវិបុលសុខសេរីសួស្តីជ័យមង្គលគ្រប់ទិនទិវទៅហោង ។

ចប់

# មន្ត្រីវគ្គ

១– ព្រះរាជា ត្រូវតែប្រើស្វែងរកមន្ត្រី ជាអ្នកចេះចាំធម្ម-សាស្ត្រនិងអាថ៌សាស្ត្រ ជាអ្នកមានពូជជាទាមុនធំ មាននាមល្បីល្បាញជាបណ្ឌិត ជាអ្នកបង្កើតទ្រព្យសម្បត្តិ ។

២– នរជនណាកើតក្នុងប្រទេសខ្លួន ប្រព្រឹត្តល្អបរិសុទ្ធតាមវង្សត្រកូល មានចិត្តស្អាត ស្ទាត់ជំនាញក្នុងសាស្ត្រ មានអាថ៌កំបាំង មិនតាំងខ្លួនជាអ្នកលេងល្បែងភ្នាល់ ហើយមិនប្រព្រឹត្តបរទារកម្ម នរជននោះទើបសមបានធ្វើជានាយករដ្ឋមន្ត្រី។

៣– នរជនណា មានភក្តីមានគុណបរិសុទ្ធល្អ ប្រសព្វ ហើយវៃឆ្លៀវឆ្លាត និងបដិភាណ នរជនបែបនោះសមបានធ្វើជាទូត ។

៤– ព្រាហ្មណ៍ អ្នកចម្បាំង និងជាពង្សមិនគួរលើក

ឲ្យធ្វើការគន់ឃ្មាំងទេ ព្រោះព្រហ្មណ៍សូម្បីមានសិទ្ធិត្រូវឲ្យ
ក៏មិនព្រមបើកឲ្យបើចុកជាឲ្យគឲ្យដោយលំបាក ។

៥- អ្នកចម្បាំងកាន់ការគន់ឃ្មាំងទ្រព្យទៀងណាស់ តែ
កាន់ក្រប៉ីសំដៃនឹងបុគ្គលិក, បើនៅគង់ប្រាញ គេគិតតែពីការញ់
ទ្រព្យសម្បត្តិទគអស់ ដោយការងារទូទៅគេត្រូវជាញាតិ ។

៦- ការមាត្យការឃ្មាំងព្រោក ព្រោះជាគូរសត្វតសន្ទិន
ឲ្យរៀប ។, សំពត់ផ្ទុតទឹក បើគេពួតអស់ក៏ដេះម្ចង់ទីងសម្រេច
ទឹកអស់ចេញក្លាយមិនមែនឬ ? ។

៧- ការចាយវាយហួសប្រមាណ, ការពិនិត្យគ្រប
គ្រាម៉ិនដិតដល់, ការបានទ្រព្យខុសហេតុគន្ធងឹជម៌ទីងការចាយ
វាយខ្ជះខ្ជាយ ទាំងអស់នេះលោកពោលថា " ការវិនាសនៃ
ឃ្មាំង " ។

៨- គន់ការធ្វើពលិកម្ម ១ គន់ការធ្វើវាហៈ ១ គន់
ការអ្នកពាយ ១ គន់ការកំហាត់បង់ខ្វាសត្រូវ ១ គន់ការដំកើង

យស១ ក្នុងការសង្គ្រោះមិត្រ១ ក្នុងការយោជាទីស្រឡាញ់១ ក្នុងផៅពង្សដែលក្រីក្រ១, វត្ថុទាំង៨ប្រការនេះលោកមិនហៅជាវិនាសទ្រព្យទេ ។ ..........

៩- ទូតសូម្បីនៅកណ្តាលសាលាដែលគេលើកប្រួនប្រាន ក៏មិនត្រូវនិយាយអ្វីក្រៅពីការខ្លួន អាស្រ័យដោយខ្លួនជាទូត គេមិនអាចសម្លាប់ ព្រោះហេតុនោះទូតគប្បីចរចាត្រង់ទៅត្រង់មកតាមសេចក្តីពិត ។

១០- ទូតសូម្បីជាអនារ្យជន និយាយពាក្យមិនគប្បីក៏មិនត្រូវសម្លាប់ដែរ ព្រោះគេជាមាត់នៃព្រះរាជា, កណ្តាលសាលាប្រជុំប្រានទូតមិនចរចាអ្វីក្រៅពីពាក្យបង្គាប់ ។

១១- នរណាជាអ្នកប្រាជ្ញ អាចស្គាល់ខ្លួនជាលោកទាបប៉ុំគាល់សត្រូវជាខ្ពង់ខ្ពស់ ព្រោះតែពាក្យទូតនិយាយជាប្រមាណ អាស្រ័យដោយហេតុ ដែលគេមិនត្រូវសម្លាប់ទូតទើបត្រូវតែនិយាយទាំងអស់សព្វការទាំងពួង ។

១២– នរជនណា ធ្លាក់ទៅក្នុងកិច្ចការណា គួរតាំងនរជននោះឲ្យចាត់ចែងទៅការនោះ នរជនដែលមិនប្រសព្វកិច្ចការទេ ស៊ូម្បីចេះដឹងសាស្ត្រវិជ្ជា ក៏រមែងធ្វើការមិនជិតដល់ដែរ (ដូចបុរាណពោលថា អ្នកចេះដប់មិនស្មើនឹងអ្នកប្រសព្វមួយ) ។

១៣– សតិគឺការចាំបាន១ ការប៉ិនត្រិះរិះសមហេតុផលក្នុងប្រយោជន៍ដ៏សំខាន់១ ការដឹងប្រាកដ១ ការម៉ឺងម៉ាត់១ ការចេះរកការប្រឹក្សាសម្ងាត់១ ទាំង៥ប្រការនេះជាគុណសម្បត្តិនៃមន្ត្រី ។

១៤– បពិត្រព្រះរាជា បុរសមាន៣ជាន់ គឺបុរសឧត្តម បុរសថោកទាប និងបុរសមធ្យម, ទ្រង់គប្បីចាត់ចែងឲ្យធ្វើការទៅតាមជាន់ទាំង៣នេះឯង ។

១៥– ព្រះភូមិបាល មិនគួរលើកដំកើងជនបរទេសអគន្តុក ឲ្យជានាម៉ឺនធំដោយការហេតុថា "ខ្ញុំពឹងការចាស់

ប្រព្រឹត្តខុស" ទេ អំពើនេះជាទោសធំណាស់ ព្រោះប្រជាជន
បរទេស យើងនឹងជឿទុកចិត្តបានថាទឹងមិនចំណាយពជ្យ
សម្បត្តិឲ្យវិនាសបង់ឬ ? ។ ........

១៦- មនុស្សទុជ្ជន បើទុកជាលើកដំកើងឲ្យមានយស
សក្តិជាទិច្ចក៏ដោយ ក៏នៅតែមិនមានចិត្តស្មោះត្រង់ មិនលះបង់
សភាពប្រក្រតីដើម, ដូចកន្ទុយឆ្កែ សូម្បីគេយកប្រេងរែតលាប
តាមឲ្យត្រង់ ក៏មិនលះបង់ចុងឯងស្ទុះទៅលើតាមប្រក្រតីវា
ឡើយ ។

១៧- ធម្មតាកន្ទុយឆ្កែ ទុកជាគេយកប្រេងរែតឲ្យត្រង់
យកទៅរុំបង់យកសំពត់រុំរស់ ១២ ឆ្នាំ ក៏ឥតអំពើ, កាលណាគេ
ស្រាយចំណងចេញ ក៏ត្រឡប់កងកន្ទុយក្រង៉ក់ឡើងវិញដូច
ប្រក្រតីដើម ។

១៨- អ្នកនគរ តែងគោរពអស់កាលជាទិច្ច ចំពោះ
ជនណាដែលព្រះនរបតីលើកដំកើង, ជនណាដែលព្រះនរបតី

មើលងាយហើយ ជននោះក៏ត្រូវអ្នកនគរមើលងាយដែរ ។

១៩ - ព្រះរាជាអង្គណា យកអ្នកទោកម្មស្ត្រី ពុំនោះសោតកូនក្មេងធ្វើជាមន្ត្រីប្រឹក្សា ព្រះរាជាអង្គនោះនឹងត្រូវប៉ុនដោយខ្យល់គំនយោបាយមិនល្អ ហើយនឹងលេចលង់ក្នុងសមុទ្រគឺការងារ ។

២០ - ព្រះរាជាអង្គណា មានះពង្ស មានព្រះរាជគ្រូនឹងមន្ត្រីសុទ្ធតែជាអ្នកបញ្ចោរលើកជើង ព្រះរាជាអង្គនោះនឹងសូមព្រះសេរីៈជយគុណធម៌នឹងថវិកាជាតិដោយឆាប់រហ័ស ។

២១ - ព្រះរាជាអង្គណា ប្រគល់ព្រះរាជស្រី (អធិបតេយ្យរបស់ព្រះរាជា) ឲ្យដាច់ខាតដល់មន្ត្រីណាហើយ ក្តី វិនាសអន្តរាយនឹងកើតមានប្រាកដឡើង, គង់វៀរនេះព្រះអង្គនោះនឹងទ្រង់ផ្ទុំកើតទុក្ខសោកសៅក្តៅក្រហាយ, ដូចមនុស្សខ្វាក់ឥតអ្នកដឹកដៃ ។

២២ - គង់កាលណា ព្រះភូមិបាលទ្រង់តែងតាំងមន្ត្រី

ណាមួយជាឯកអគ្គជាប់ការៈក្នុងភព្វ, ក្នុងកាលនោះសេចក្តី ស្រវឹងយសតែងហូរចូលទៅគ្រប់សន្តានចិត្តមន្ត្រីនោះ ដោយអំណាចមោហធម៌ មន្ត្រីនេះឯងតែងចំណាយបន្ទូរការងារឲ្យវិនាសដោយអំណាចស្រវឹងយស និងក្តីលុបប្រមូលមិនខាន, កាលបើការងារវិនាសហើយសេចក្តីលោភអន្ទះអន្ទែង និងបក្ខក្តីចង់បានការអំណាចជាប់ក្នុងខ្លួនឯង ឲ្យកើតឡើងក្នុងចិត្តជាលំដាប់តទៅ, ដោយអំណាចសេចក្តីលោភអន្ទះអន្ទែងចង់បានការអំណាចជាប់ខាតខ្លួនឯងនេះជាមូលហេតុ, មន្ត្រីនោះនឹងទ្រុស្តិ៍ច្រើនតម្ចាស់ឲ្យដល់ក្ខ័យប្រាណមិនខាន ។

៦៣– គ្រប់កាលចំនួន អាមាត្យទាំងអស់ដែលនឹងត្រូវតែងតាំងហើយមិនគួរឲ្យបរិបូណ៌ទ្រព្យទេ, អ្នកប្រាជ្ញទាំងឡាយប្រាប់ទុកទេសថា "ឬទ្ធិគិការមានទ្រព្យច្រើនអាចផ្លាស់ប្តូរចិត្តមនុស្សឲ្យទៅឆ្វេង ១ បាន» ។

៦៤– នរណា បានទ្រព្យសម្បត្តិហើយមិនឡើងតាន?

នរណាលុះក្នុងវិស័យអំណាចខ្លួនហើយ អាចរំលេចទុក្ខទោសអន្តរាយបាន ? នៅលើផែនដីនេះ នរណាមានចិត្តនឹងមិនព្រោយខ្លួនដួលព្រោះស្រី ? មួយទៀត នរណាជាទីស្រឡាញ់នៃព្រះរាជា ? ក្នុងលោកនេះនរណាមានអំណាចខ្លាំងមិនចូលទៅក្នុងកណ្ដាប់ដៃនៃព្រះកាល ? នរណាជា អ្នកសូមទានគេហើយបានដល់សេចក្ដីគោរពខ្ពង់ខ្ពស់ ? មួយវិញទៀត នរណាដែលធ្លាក់ខ្លួនទៅក្នុងអន្ទាក់នៃខ្មាំង ហើយបានត្រឡប់ទៅជាបុរស រុណីដោយក្ដីក្សេមក្សាន្ត ។

២៥— មែនពិត, ព្រះរាជាដូចជាបិតាក្រោកការពារប្រជាករឲ្យផុតពីក្ដីអន្តរាយដែលកើតអំពីចោរ ពីអាមាត្យមុខមន្ត្រី ពីសត្រូវក្រៅប្រទេស, ពីបរិវារជំនិតព្រះអង្គនឹងសេចក្ដីលោភរបស់ព្រះអង្គឯង ។

២៦— ព្រះនរបតីដែលទ្រង់ឈ្លាសយល់ ស្គាល់សេវកាមាត្យថា «អ្នកនេះមានប្រាជ្ញា មានភក្ដី អ្នកនោះមានសេច-

ក្តីក្លៀវក្លាហាន ឬប្រកបព្រមដោយលក្ខណៈ២ប្រការនោះ តែង បរិបូណ៌ដោយសេវកាមាត្យ ទាំងឡាយ ដែលមានគុណសម្បត្តិ ។

២៧– ប្រយោជន៍អ្វីដោយជនភក្តី តែមិនមានសមត្ថភាព? ប្រយោជន៍អ្វីដល់ជនអង់អាចតែមិនធ្វើឲ្យសម្រេចប្រយោជន៍? ។

២៨– នរជនមានប្រាជ្ញា ទឹងមានសេចក្តីប្រព្រឹត្តម៉ឹងម៉ាត់ សូម្បីជនដទៃមើលងាយថា មិនបានការអ្វីនោះ ក៏មិនគប្បីសន្ទិះសង្ស័យថា «វិនាសសាបសូន្យឡើយ» ភ្លើងសូម្បីបុគ្គលយកទៅដាក់ខាងក្រោម, ក្នុងកាលណាក៏ដោយអណ្តាតភ្លើងមិនដែលឆេះទៅក្រោមឡើយ តែងតែឆេះទៅខាងលើជាដរាប ។

២៩– គ្រាវិបត្តិ នរជនត្រូវស្គាល់ប្រាជ្ញានៃពពួកញាតិសន្តាន ភរិយានិងសេវកាមាត្យ សក្តិនករព្រមទាំងខ្លួនឯងឲ្យ

ដូចជាថ្មសម្រាប់ពិសោធន៍មើលមាសសុទ្ធ ។

៣០— សេវកាមាត្យណា មានសេចក្ដីប្រាជ្ញាគិត មាននិស្ស័យមុឺងម៉ាត់មានប្រាជ្ញ ដើរតាមហែហមព្រះរាជាគ្រប់កាលទាំងពួង ដូចជាស្រមោលអន្ទោលតាមប្រាណ ធ្វើតាមព្រះរាជបញ្ជាមិនហ៊ានរុញ្ញាក សេវកាមាត្យនោះ សមនៅក្នុងព្រះរាជដំណាក់បាន ។

៣១— ចេះពោលពាក្យឲ្យសមតាមកាលៈទេសៈ ធ្វើខ្លួនឲ្យប្រែជាជនស្រឡាញ់ប្រាកដស្មើនឹងសប្បុរស ចេះក្រោធឲ្យសមតាមឋានៈសក្ដិខ្លួន អ្នកណាចេះធ្វើដូច្នេះ អ្នកនោះសមបានធ្វើជាមន្ត្រី ។

៣២— មានការចេះដឹងល្អ១, មានសីលធម៌ក្នុងចិត្ត១, មានសេចក្ដីប្រព្រឹត្តតាមគន្លងធម៌១ ធ្វើខ្លួនឲ្យជាប្រយោជន៍ដល់មនុស្សជាតិដូចគ្នា១ ទាំង៤ប្រការនេះជាលក្ខណៈរបស់មន្ត្រី ។

៣៣— នរជនណា កពូនទ្រព្យសម្បត្តិ សូម្បី១កាក

ណែតសម្រាប់ព្រះពជាដើម្បីថវិកាជាតិ ខេផននោះហើយឈ្មោះ

ជា «ដាំអាមាត្យពិតប្រាកដមែន» ។

៣៤– អាមាត្យគួរមានលក្ខណៈដូចដាំក្អមតាមសម្ដីសឿ

ពេលាចាក់ចេញតិច ពេលាដងបានច្រើន ។

៣៥–ដោយច្រើន អាមាត្យកាន់អំណាចបើគេសង្កត់

សង្កិនតែត្បិតហើយធ្វើឲ្យចំរើនព្រះរាជទ្រព្យម្ចាស់ផែនដី ប្រៀប

ដូចជាបូសគោ បើគេប្របាច់ហើយធ្លាយខ្ទុះចេញ ។

៣៦–ការណាព្រះពជាទ្រង់រាប់អានជនទាំងពួងស្មើភាគគ្នា

មិនឲ្យមានវិសេសផ្ទុកគ្នា, ៖ស្បាហៈនៃជនដែលមានសមត្ថ-

ភាពប្រឹងប្រែងធ្វើការងារទើងសាបរលាបអួនថយចុះទៅ ។

៣៧–ប្រើមធ្យោបាយដកយសសក្តិ ត្រូវគ្រាមើលជា

និច្ច ប្រមាណឲ្យឡើងទាំងទី ផ្ទាស់ចេញពីនាទីនេះជាប្រសាសន៍

វិធីនៃម្ចាស់ផែនដីដែលធ្វើចំពោះអាមាត្យ ។

៣៨–បុគ្គលមិនគប្បីប្រើយកន្ទើយចំពោះកិច្ចការរបស់

សេវកៈ ដែលបានបំពេញមុខការនាំចំបរិបូណ៌ហើយៈនោះទេ គប្បីលើកដំកើងសេវកៈនោះ ដោយរង្វាន់ ដោយទឹកចិត្តជ្រះថ្លា ដោយកាតាពោលសរសើរនិងមើលដោយភ្នែក ។

៣៩– នរជនណា ដឹងថាគួរឬមិនគួរប្រកប ដើម្បីកំចាត់បង់នូវសេចក្តីវិនាស នរជននោះដឹងថា "ទីនេះ មានអន្តរាយ" ដូច្នេះហើយមិនលេចលង់ផុងគំនិតថាឲ្យវិនាសក្នុងគ្រាក្រខ្វល់បានឡើយ ។

៤០– សេវកាមាត្យ បើមិនទាន់ប្រាប់ម្ចាស់ឲ្យដឹងមុន មិនត្រូវធ្វើអ្វីតាមទំនើងចិត្តខ្លួនឡើយ លើកលែងតែកិច្ចការត្រូវការពារម្ចាស់ ។

៤១– បុគ្គល កាលបើនៅក្នុងដំណែង តាំងចិត្តធ្វើការជាឧបការៈមិនសំគាល់ខ្លួនថាធ្វើការខុសទេ តែងយកឧបការៈជាទង់ជ័យបាំង ហើយនឹងធ្វើការបំផ្លាញប្រទេសទាំងមូល ។

៤២– លួចទ្រព្យសម្បត្តិដែលបានមក, ប្រវ៉ាន់បំបាត់

ទ្រព្យ, បណ្ដោយតាមចិត្តម្ចាស់, ព្រោះយកទ្រព្យនឹងការងារ, ភាពជាប់គុណឥតវិហារៈ, កើតកើនសប្បាយទាំងអស់នេះជាគ្រឿងប្រទូស្តនៃអាមាត្យទាំងឡាយ ។

៤៣– អាហារទឹកដោះដ៏ពិសពុល ធ្មេញដែលរង្គើ និងអាមាត្យប្រទូស្ត ទាំងអស់នេះត្រូវកកាយដកចោលឲ្យទាល់តែអស់ដល់បាទដល់ឫសគល់ទើបបានសេចក្ដីសុខ ។

៤៤– ការបណ្ដុះបណ្ដាលឲ្យចំរើន ឬការពង់អានលើកដំកើងឲ្យប្រសើរនឹងអាចញុំាង មនុស្សវិលខូច ចិត្តអាក្រក់ឲ្យត្រេកអរពេញចិត្តដូចម្ដេចកើត ? ដូចដើមឈើមានពិសពុល សូម្បីយកទឹកអម្រឹតទៅស្រោចស្រប ក៏មិនត្រឡប់ចេញផ្លែផ្កាជាវិប្រាថ្នាបានដូច្នោះដែរ ។

៤៥– នរជនណា ណែនាំព្រះរាជា ក្នុងការមិនគួរធ្វើជាជាការគួរធ្វើដើម្បីផ្គាប់តាមចិត្តព្រះនរបតី ដោយអែបផ្គាប់បុណ្យ នរជននោះសូមធ្វើជាមន្ត្រីឬទេ? ការធ្វើឲ្យលិចបាត់ព្រះ

ទ័យម្ចាស់ ប្រះសើរជាងការធ្វើឲ្យម្ចាស់វិនាស ព្រោះការនេះ គ្រាន់តែជាកិច្ចមិនគួរប៉ុណ្ណោះទេ ។

៤៦– មនុស្សទ្រុះវិនាសយស; មនុស្សមានចិត្តមិនស្មើបាត់ត្រកាត, មនុស្សគេលឥន្ទ្រីយ៍ មិនមានត្រកូល, មនុស្សលោភមិនមានធម៌, មនុស្សច្រើសេចក្ដីអន្តរាយខាតផលវិជ្ជា, មនុស្សកំណាញ់វិនាសសេចក្ដីសុខ. ឯព្រះនរបតី មានតែអាមាត្យអែបអបស្រីផលាភយស វិនាសពង្ស ។

៤៧– អ្នកនាំដែលប្រព្រឹត្តហៅហាងតាមទំនើងចិត្តខ្លួន ឬដែលខូចចិត្តក្នុងការធ្វើនយោបាយ រមែងមិនបានទទួលផលដ៏ពិសាលបានឡើយ សេចក្ដីចំរើនតែងធ្លាក់មកលើដៃជនអ្នកមាននយោបាយល្អនឹងសេចក្ដីក្លៀវក្លាហាន ។

៤៨– ក្លៀវក្លា តែងបានទ្រព្យ ជនបរិភោគអាហាររលួយឆ្ងាយតែងមិនមានរោគ, ជនមិនមានពេរតែងបាននូវសេចក្ដីសុខ ជនមានព្យាយាមតែងបានដល់ត្រើយនៃវិជ្ជា, ជនមាន

វិន័យតែងបានសេចក្ដីចំរើនទ្រព្យសម្បត្តិនិងយសសក្ដិ ។

៤៩– សំពៅ គេសាងសម្រាប់ទូងសមុទ្រសាគរ ដែលគេធ្វើងបានដោយក្រ, ប្រទីបៈគេសាងសម្រាប់អុចស្រោលបំភ្លឺក្នុងពេលងងឹតអន្ធការ, វិជនីគេធ្វើសម្រាប់បក់ក្នុងពេលមិនមានខ្យល់, កន្ទេរគេធ្វើសម្រាប់ហ៊ុំកហ៊ុំទដីការពារទ្រនង់ងងឹតមុខចុះប្រែង, នាម៉ឺនព្រះរាជាតាំងឡើងដើម្បីជាព្រះនេត្ររបស់ទ្រង់, ដូចនោះ នៅក្នុងលោកនេះមានរបស់អ្វីមួយ ដែលសង្ខារកាត់តែងបង្កើតហើយទុកដាក់តាមចិន្ដា, ហេតុនេះសូម្បីតែព្រះព្រហ្ម ដែលមានព្រហ្មវិហារធម៌ដ៏ខ្ពង់ខ្ពស់ល្អ ក៏ខំម្ចាក់ព្យាយាមក្នុងការទូន្មានប្រៀនប្រដៅសត្តានមនុស្សទុជនដែរ ។

៥០– ប្រាជ្ញមន្ត្រី គេឃើញច្បាស់ក្នុងពេលធ្វើការជាស់ស្ពានមេត្រីប្រាជ្ញាគ្រពេទ្យ គេមើលឃើញច្បាស់ក្នុងពេលព្យាបាលរោគកាច – ព្រោះជាកិច្ចការដែលប្រព្រឹត្តទៅល្អហើយនរណាមួយមិនអួតខ្លួនជាជាងល្អិត ? ។

៨១– ដោយពិត, ជនណាអប្បឥតប្រាជ្ញា សូម្បីប្រាថ្នាធ្វើការឆោរគួចគាច តែងសំដែងអាការៈខ្សោះខ្សុះ, ឯអ្នកមានប្រាជ្ញាសូម្បីប្រាថ្នាធ្វើការធំៗ ក៏នៅនឹងថ្កល់ដូចថ្ម មិនសំដែងអាការៈខ្វេះខ្វះ ។

៨២– មន្ត្រីអាក្រក់ណា ដែលមិនធ្វើឲ្យភ្លាត់ខុសក្នុងផ្លូវនយោបាយ? ជម្ងឺណា ដែលមិនទាក់ដោតអ្នកណាដែលបរិភោគចំណីអាហារមិនល្អ? ទ្រព្យសម្បត្តិណា ដែលមិនធ្វើឲ្យនរជនទៀនតាន? នរជនណាដែលម្រិត្យមិនសម្លាប់? នរណាដែលស្ត្រីធ្វើឲ្យលុះក្នុងវិស័យយក់ ហើយមិនរសាប់រសល់ខ្វល់ខ្វាយក្នុងចិត្ត? ។

៨៣– ការមិនហ៊ានប្រារព្ធធ្វើការអ្វី ព្រោះភ័យខ្លាចតែពីខុស នេះជាលក្ខណៈនៃបុរសគំរក់ទេ, ដូចជានរណាលះបង់នូវអាហារភោជនមិនហ៊ានបរិភោគ ព្រោះខ្លាចអាហារមិនរលួយ ។

៥៤– នាវជនណាមួយ លះបង់សេចក្តីសុខផ្ទាល់ខ្លួន ទំធ្វើការជាប្រយោជន៍ប្រទេស ការពារនិងប្រតិបត្តិតាមច្បាប់របស់រដ្ឋ នាវជននោះ ពេញជាមនុស្សមួយគួរគប្បីយើងលើកជាគំរូបាន ។

៥៥–ក្នុងពេលណា ឬ កាលៈទេសៈណា ដែលមានអយុត្តិធម៌មកប៉ះពាល់ដល់ប្រទេសជាតិ ឬក៏ដល់ពលរដ្ឋជាតិ ពេលនោះ ឬ កាលៈទេសៈនោះ បុគ្គលគប្បីក្រោកឡើងប្រយុទ្ធច្បាំងនឹងអយុត្តិធម៌នោះ តាមវិន័យ ក្លាហានរបស់សមត្ថភាពខ្លួន, អ្នកណាធ្វើបានដូច្នោះ អ្នកនោះសមបានដំណែងជាអ្នកកាន់ចង្កូតនាវាគឺប្រទេសជាតិនេះណាស់ ។

៥៦–ដោយពិត, សព្វកិច្ចការទាំងពួង បើធ្វើឲ្យតឹងរឹងហួសវិន័យពេក ឬក៏ធូរថយហួសច្បាប់ពេក ក៏ជាហេតុនាំឲ្យខូចប្រយោជន៍ដល់ប្រទេសជាតិវិញ ក្នុងពេលដែលគេធ្វើតាមពុំបាន ឬក៏ក្នុងពេលដែលគេប្រព្រឹត្តធូរថយគ្មានវិន័យពេក;-

ដូចជាពិណាបើគេតឹងក៏ដាច់ បើធូរពេកក៏មិនពីរោះទៀត ។

៩៧– ប៉ុន្តែក្នុងកាលណាក៏ដោយ បុគ្គលគួរកុំបណ្ដោយខ្លួនឲ្យលុះក្នុងអគតិធម៌ឲ្យសោះ សូម្បីតិចតួច, ព្រោះថាបើបណ្ដោយយូរៗទៅ ជាហេតុនាំឲ្យខូចដល់គុណសម្បត្តិរបស់យើងក្នុងអនាគតកាលពុំខាន ។

៩៨– ទ្រព្យសម្បត្តិណា ដែលឡើងដោយអធម៌ ទ្រព្យសម្បត្តិនោះអាចធ្វើឲ្យបុគ្គលលុះក្នុងអគតិធម៌, ទ្រព្យមានសភាពនោះអាចហិនហោចចុះទៅជាលំដាប់ៗ យ៉ាងយូរបំផុតមួយដំណរ, ដូចដំណក់ទឹកដែលបុគ្គលដាំលើចង្ក្រាន តើមិនរីងខ្លះឬអ្វី ? ។

៩៩– មិនមែនជាតែគុណធម៌ទេ, ទ្រព្យសម្បត្តិ, យសស័ក្តិ, សេចក្ដីចម្រើន, ការសប្បាយភ្លើតភ្លើនចិត្ត ដែលកើតអំពីអំពើទុច្ចរិតមនុស្សព្រមតាំងទៅតាំ ក៏តែនឹងផ្ដន្ទាសាអស់កាលជានិច្ច, ព្រះអាទិត្យ ព្រះច័ន្ទ ពេលសន្ធ្យាទីងទៅតា

តែងតែនាំអោយកើតទុច្ចរិតរបស់ទុជ៌នសព្វ ៗ កាល ។

៦០– បុគ្គលដែលដឹកនាំ ធ្វើការជាប្រយោជន៍ដល់ជាតិ ជាអ្នកឈ្លាសវៃក្នុងនីតិសាស្ត្រ មានសេចក្តីក្លាហាន មានវិន័យ មានពាក្យយាម ទាំងលះបង់ការសប្បាយក្តើតក្តើនចិត្ត ពោលស្រវ៉ះ, ជនណាមួយទៅប្រទុស្តប្រើទុច្ចាយកោល បន្ទុសបាត់រុកដោយក្តីល្មោភ ជននោះឈ្មោះថា សាធក់សនា អាក្រក់របស់ប្រទេសជាតិ ព្រមទាំងទុកសម្រាប់ញាតិរបស់ខ្លួនក្នុងអនាគតកាល ។

៦១– ទុជ៌នដែលប្រើអំណាចបុណ្យហួសមាត្រា, ប្រព្រឹត្តអំពើទុច្ចរិត, បំបិទមាត់កស្ត្រ, បំបាំងទោសខ្លួន, យកអំណាចនីតិប្រតិបត្តិជាន់ទុក, ប្រកបដោយអគតិធម៌, បំផុតបំផ្លាញផលរបស់ប្រទេស, ក្តិបពន្ធ័បនជនស្លូតក្នុងនីតិសាស្ត្រ, រដ្ឋណាប្រកបដោយបុគ្គលមានសភាពបែបនេះសូម្បីតែម្នាក់ធ្វើជាមន្ត្រី រដ្ឋនោះនឹងលប់បាត់ពីផែនទី លោកយ៉ាងឆាប់

ទោស ។

៦២– បុគ្គលមិនគប្បីនិន្ទារិះគន់ បន្តុះបង្អាប់បុគ្គលនានាពាល បង្កាច់បំពារះជនណា ដែលធ្វើការជាប្រយោជន៍មាតុភូមិឲ្យសោះ, ដូចជាបុគ្គលអ្នកខ្ជិលច្រអូស មិនគប្បីរិះគន់អ្នកមានព្យាយាមឡើយ ។

៦៣ – បុគ្គលដែលធ្វើការល្អដើម្បីប្រយោជន៍សាធារណៈជន មិនគប្បីប្រកាន់ខឹងចងគំនុំនឹងទុជ្ជនអាក្រក់ឡើយ ទុកណាជាទុជ្ជននោះពោលបង្ខូចដាក់ទណ្ឌកម្មណាក៏ដោយ ពន្លឺព្រះអាទិត្យបើទុកជាពពកបាំងជិតក៏គង់មានពន្លឺរះភ្លឺចាំង មកបំភ្លឺមនុស្សបានដែរ ។

៦៤– បុគ្គល អ្នកប្រព្រឹត្តល្អធ្វើការជាប្រយោជន៍ដល់សាធារណៈជនកុំគប្បីខ្លាចពាក្យនិន្ទារិះគន់, ការមើលងាយ, ការបៀតបៀន និងទណ្ឌកម្មអាក្រក់ របស់មនុស្សពាលឲ្យសោះ គប្បីដាស់ដល់មុខការខុសបុគ្គលពាលវិញ អ្នកប្រាជ្ញ

ភិតៗតែងកោតសរសើរដល់បុគ្គលមានសភាពបែបនេះ បុគ្គលនោះឈ្មោះថា បានត្រាយផ្លូវនាំសុខក្នុងប្រទេសក្នុងអនាគតកាល ។

៦៤– នរជន មិនគប្បីក្រោធតបត, ព្យាបាទ, គុំគួន និងធ្វើកម្មអាក្រក់ ចំពោះអ្នកប្រាជ្ញណាដែលបានជំទាស់ដល់មុខការខុសឆ្គងដែលខ្លួនគិតធ្វើ គប្បីតែសំដែងទោសដែលមានដល់អ្នកនោះវិញ អ្នកណាអាចធ្វើយ៉ាងនេះអ្នកនោះទុកជាមានបាបកម្មយ៉ាងណា ក៏មិនអាចទៅទុគ្គតិភពឡើយ ។

៦៥– បុគ្គលគប្បីខំសិក្សានូវសាស្រ្តាឲ្យបានចេះដឹងគ្រប់ៗគ្នា ព្រោះថាសាស្រ្តាវិជ្ជាជាគ្រឿងកាត់បង់នូវសេចក្ដីសៅហ្មងអនេកជាគ្រឿងបើកបង្ហាញនូវអាថ៌កំបាំង អ្នកណាចេះសាស្រ្តវិជ្ជាអ្នកនោះទុកដូចជាមានភ្នែកភ្លឺ ។

៦៧– សេវកាមាត្យ ត្រូវវៀរហេតុ ៣ យ៉ាងចេញ, គឺគប្បីបរិភោគកាមគុណឲ្យលើសនិងព្រះរាជា, មិនគប្បីពោល

ពាក្យទ្រគោះបោះបោកគបក, គប្បីតបតែងខន្តីឲ្យសមតាម ឋានៈខ្លួន ។

៦៨–រាជអាមាត្យគួរគប្បីគិតថា ព្រះរាជាមិនមែនជា មិត្រ សាច់សាលោហិតទេ ព្រះរាជាពិតជាម្ចាស់ផែនដី ដែល សម្រាប់គ្រងនូវភោគសុខ ។

៦៩–អាមាត្យកាលចូលគាល់ ព្រះមហាក្សត្រគប្បី វៀរទោស៦ប្រការគឺ កុំឲ្យឆ្ងាយពេកជិតពេកដល់ម៉ាំងព្រះភក្ត្រ, កុំឲ្យជិតទីអាសនៈព្រះអង្គ, កុំអង្គុយលើខ្យល់ដាល់ព្រះអង្គ, កុំអង្គុយចំមុខព្រះភក្ត្រ, កុំអង្គុយត្រង់ទីទាបពេក, កុំអង្គុយខ្ពស់ ជាងអាសនៈព្រះរាជា ។

៧០–បុគ្គលក្នុងលោកនេះ បើព្រះរាជាលះបង់ចោល លែងរាប់អានហើយតែងដល់នូវការទុក្ខសោកថយ សូម្បី មានបញ្ញានឹងវិជ្ជាច្រើនស្មើនឹងព្រះសមុទ្រក៏ដោយ, ដូចកែវមណី មានដម្លៃច្រើន បើមិនមានមាសព័ទ្ធទេនឹងគប្បីបានរុងរឿងដូច

ម្តេចបាន ? ។

៧១– បុគ្គល គួរគប្បីអត់សង្កត់សេចក្តីក្រោធ ចំពោះ សមណៈព្រាហ្មណ៍, ព្រះរាជា, ទេវតា, ចាស់ព្រឹទ្ធាចារ្យ, កូនក្មេងនិងមនុស្សឈឺទាំងឡាយ ។

៧២– សេវកាមាត្យ តែងរកម្ចាស់ប្រកបដោយគុណ គឺមានចិត្តសទ្ធា ជាអ្នកអត់ធន់ ស្គាល់ដម្លៃពាក្យបានដោយក្រពេកណាស់ ។

៧៣– សូមមន្ត្រីទាំងឡាយក្រេបជញ្ជាក់នូវអត្ថរសនៃនីតិសាស្ត្រនេះឲ្យបានគ្រប់ៗគ្នា សូមឲ្យជាអ្នកមានគុណសម្បត្តិគ្រប់គ្រាន់, សូមព្រះរាជាទាំងឡាយកុំគាប់ព្រះទ័យនឹងមន្ត្រីដែលគ្មានគុណសម្បត្តិ ដែលនៅចំពោះព្រះភក្ត្រលើកជើងបញ្ជោរអែបអបឡើយ, សូមមន្ត្រីទុច្ចរិតទាំងឡាយដែលជាអ្នកបំបែកសាមគ្គីភាព ជាអ្នកប្រាថ្នាប្រយោជន៍ផ្ទាល់ខ្លួន រសាត់តាមធម្មជាតិឲ្យបាត់អស់ទៅ, សូមមន្ត្រីទាំងនោះជាអ្នកមាន

ចិត្តស្មោះត្រង់នឹងព្រះរាជាម្ចាស់ផែនដី ព្រមទាំងប្រជារាស្ត្រព្រះ
អង្គគ្រប់ៗកាល, សូមឲ្យប្រជារាស្ត្រទាំងឡាយមានភក្តី ចំពោះ
ព្រះរាជាម្ចាស់ផែនដីផង ចំពោះមន្ត្រីដែលជាព្រះនេត្រ
របស់ព្រះអង្គផង ។

ចប់

# រាជវគ្គ

១– តាមធម្មតា, បុគ្គលត្រូវកក្កាស់ផែនដីឲ្យបានទុកជាបឋមរួចហើយទើបសឹមកកកាយទឹកទ្រព្យ ជាះបើមិនមានស្ដេចគ្រប់គ្រងរក្សាទេ តើនឹងត្រូវកកកាយទឹកទ្រព្យធ្វើអ្វីក្នុងលោកនេះ ។

២– បើមិនមានព្រះនរបតី ជាអ្នកគ្រប់គ្រងដឹកនាំដោយប្រពៃទេ ប្រជាជនទុកដូចជានាវាមិនមានអ្នកកាន់ចង្កូត នឹងវង្វេងលេចលង់ក្នុងសមុទ្រជលធី ។

៣– ព្រះនរបតីការគ្រប់គ្រងរក្សានូវប្រជាជន ប្រជាជនធ្វើឲ្យបំរើនព្រះនរបតី, ការគ្រប់គ្រងប្រសើរជាងសេចក្តីបំរើន

បើមិនមានការគ្រប់គ្រងរក្សាសេចក្ដីចំរើននោះទេ សេចក្ដីចំរើន
នឹងវិនាសបាត់បង់ទៅវិញ ។

១ ៤– ម្ចាស់ផែនដីជាទីពឹងនៃរដ្ឋទាំងឡាយ ដូចភ្លៀងជាទីពឹងនៃសត្វទាំងឡាយ, បើភ្លៀងអាក់អួល សត្វលោកអាចញុំាងជីវិតឱ្យប្រព្រឹត្តទៅបានខ្លះ បើព្រះរាជាមិនប្រកបដោយធម៌ពលរដ្ឋរស់នៅមិនបានទេ ។

៥– ទឹកជាកំពែងការពារជាតិទាំងឡាយ ប៉មជាកំពែងការពារអ្នកនៅក្នុងប៉ម ទ្រូងជាកំពែងការពារសត្វទាំងឡាយមានខ្លួនជាដើម សេនានុភាពនៃព្រះរាជាជាកំពែងការពារកងពលអរិន្ទកផ ។

២ ៦– នរជនណា បរិសុទ្ធដោយត្រកូល ដោយផៅ
៣ ពង្ស ដោយអាចារៈធម៌ មានតបៈតេជៈដ៏ខ្លាំងខ្លា ប្រកបដោយធម្មចរិយា នឹងនីតិកោសល (ជំនាញក្នុងនយោបាយ) នរជននោះសមនឹងបានជាស្តេចលើផែនដីនេះ ។

៧- ការឲ្យរង្វាន់ត្រូវ១ ការពោលពាក្យគួរឲ្យចង់ស្តាប់១ ប្រព្រឹត្តនាំតែប្រយោជន៍១ ការតាំងខ្លួនឲ្យស្មើ ៗ គឺប្រើបុគ្គលឲ្យល្មមពេញចិត្តដល់ប្រជាជន១ ទាំង៤ប្រការនេះជាសង្គហៈរបស់ព្រះរាជា ។

៨- អង្គរបស់រាជមាន៩ប្រការគឺ មានព្រះរាជាជាប្រធានរបស់ប្រទេស១ មានមហាមាត្យជាអ្នកឈ្លាសវៃជាប្រធានសម្រេចកិច្ចការរាជការ១ មានប្រទេសដែលជាមិត្រស្និទ្ធ១ មានទ្រព្យបរិបូណ៌ល្មមដល់ការគ្រប់គ្រងប្រទេស១ មានអ្នកប្រាជ្ញជំនាញខាងនីតិកោសលជាច្រើន១ មានបន្ទាយមាំមួន១ មានទាហានសម្រាប់ការពារប្រទេសឲ្យបានបរិបូណ៌១ មានប្រជារាស្ត្រស្លូតត្រង់១ មានបុរោហិតនិងអ្នកប្រវត្តិសាស្ត្រដែលមានចំណេះវិជ្ជាស្ទាត់ប្រាកដ១ ។

៩- មកុដ១ ព្រះខ័ន១ សុវណ្ណបាទុក១ វាលវិជនី១ ស្វេតច្ឆត្រ ១ ទាំង ៥ នេះជាវត្ថុសម្រាប់រាជ្យៈ មានន័យមួយ

ទៀតជា មកុដ១ ព្រះខ័ន១ សុវណ្ណបាទុក១ ព្រះខណ្ឌចាម ១ ស្វេតច្ឆត្រ១ ។

១០- ទសពិធរាជធម៌ សម្រាប់ព្រះរាជាប្រតិបត្តិទឹងនាំ អស់នាម៉ឺនតូចធំព្រមទាំងប្រជារាស្ត្រប្រតិបត្តិតាមផងមាន ១០ ប្រការគឺៈ១-ការឲ្យទាន ២-ការរក្សាសីល៥ជានិច្ចឬរក្សាសីល ១០ ម្តងម្កាល, ៣-ការបំណាយព្រះរាជទ្រព្យទំនុកបំរុងនគរ, ៤-មានសេចក្តីស្មោះត្រង់, ៥-មានសេចក្តីទន់ភ្លន់សុភាពរាបសា, ៦-ការកាន់ឧបោសថសីលតាមកំណត់ម្តង ៗ, ៧-មិនដុតកំដៅក្រហាយអ្នកដទៃ, ៨-មិនបៀតបៀនអ្នកដទៃ ៩-មានសេចក្តីអត់ធន់, ១០-មិនបំពារបំពានលើច្បាប់លោកនិងច្បាប់ធម៌ ។

១១- ព្រះរាជា ជាប្រធាននៃមនុស្សទាំងឡាយ ដូចមហាសមុទ្រជាប្រធាននៃស្ទឹងទាំងឡាយ, ព្រះរាជាប្រកបដោយធម៌ ប្រជារាស្ត្រទាំងពួងរមែងនៅជាសុខ, ព្រះរាជាមិន

ក្រោធតបអ្នកដែលក្រោធហើយប្រជាកស្ត្រមែនបូជា ។

១៦– ព្រះកដាដាគ្រឿងប្រាកដនៃប្រទេស ជាអ្នកទ្រង់នូវគ្រឿងចម្បាំងទេបសង្ហា. ដូចព្រះអាទិត្យបើបញ្ចេញរស្មីរៀបរោគា បើមានមន្ទិលគឺអព្ភបាំងជិតងងឹតហើយមិនរោភាទេ ។

១៣– កាលបើព្រះចមពលបំព្រះនេត្រហើយ(ទេវទ្គត់) លោកវាងមូលកប់ទង្គកតាមដែរ, កាលបើទ្រង់តេឌ(កេត) វៀងលោកតាំងមូលកំកេតវៀងដែរ, ដូចជាព្រះអាទិត្យ កាលបើព្រះអាទិត្យអស្តង្គតកយ្ហេ. កាលបើព្រះអាទិត្យរះករកទទួល ។

១៤– ម្ចាស់ផែនដី១ អាមាត្យ១ អាណាចក្រ១ បន្ទាយ១ ឃ្លាំង១ ស្រែឡាន្ទុភាព១ សម្ពន្ធមិត្រ១ ពលវដ្ត១ សង្គមប្រជាករ១ តាំងអស់នេះ ជាអង្គនៃរាជ្យគ្រប់ប្រទេសជាតិ ។

១៥– ភាពជាមហាអំណាច១ មានមន្ត្រីចំណេះវិជ្ជា១

មានកម្លាំងសត្តានុភាព១ ទាំង៣នេះឈ្មោះថាកដភ័ណ្ឌ ។

១៦– គុណសម្បត្តិរបស់ព្រះរាជាមាន៤ប្រការគឺ មានពាក្យសត្យ១ សេចក្តីអង់អាច១ សេចក្តីអាណិត១ និងបរិច្ចាគទាន១ ព្រះមហាបាលខ្វះគុណសម្បត្តិទាំងនេះ ហើយត្រូវបានពាក្យគេហៅខ្នាពិតប្រាកដ ។

១៧ - ប្រមឹកស្រា, ស្រើងដោយនារី, វក់ការបរបាញ់, លេងល្បែងភ្នាល់, បំជាន់ទ្រព្យសម្បត្តិ, វាចាអាក្រក់ និងទណ្ឌកម្មដ៏អាក្រក់ ទាំងនេះជាសេចក្តីអន្តរាយរបស់ព្រះរាជា ។

១៨– ស្តេច, ស្ត្រីក្រមុំនៃត្រកូល, សមណៈព្រាហ្មណ៍ មន្ត្រី, ចោរ, ក្របក, ឈ្មេញ, សក់និងនរជន បើគេដកចេញពីកន្លែង (ជំណែង) មិនល្អទេ ។

១៩– តាមធម្មតាមក, ព្រះរាជាទ្រង់ផ្ទំតែយាមមួយទ្រង់តើន, បណ្ឌិតដេកអស់យាមពីរ, គ្រហស្ថដេកអស់យាមបី, ស្មូមយាចកដេកអស់យាម៤ទើបភ្ញាក់ ។

៤០- ហេតុដែលវិបត្តិផលគឺ ព្រះមហាក្សត្រិយ៍ទ្រង់ចាត់ការមិនបានគិតគូរមុន, បណ្ឌិតចិត្តសប្បុរសមានសេចក្ដីក្រោធច្រើន, នរជនបរិភោគកាម រិលច្រអូសមិនប្រឹងប្រែង និងអ្នកបួសក្នុងសាសនាមិនប្រតិបត្តិតាមវិន័យសិក្ខា ។

៤១- នរជនដែលពោលពាក្យសត្យមិនរើះហើយអាចសម្រេចផលមាន៣ពួកគឺ ព្រះមហាក្សត្រទ្រង់ពុះជ្យ១ សមណៈព្រាហ្មណ៍១ និងបណ្ឌិតចិត្តសប្បុរស១ ពាក្យសំដីនៃជនទាំង៣ពួកនេះ បើពោលហើយមិនអាចគប្បីកែប្រែវិញទេ, ដូចទឹកមាត់បើគេស្ដោះចេញចាកមាត់ហើយ មាននរណាហ៊ាននឹងអាចលិទ្ធយកវិញ? ។

៤២- ព្រះរាជា គប្បីធ្វើប្រទេសរបស់ព្រះអង្គឲ្យមានពលរដ្ឋបរិបូណ៌ ដោយការនាំយកប្រជាជនពីបរទេស ឬពុំនោះទំនុកបំរុងប្រជាជនដោយការឲ្យបាននឹងពប់អាន, មួយទៀតប្រទេសដែលមានប្រជាជនច្រើនមកពីបរទេសនោះ អាច

កត្តួនទ្រព្យសម្បត្តិជាសេដ្ឋីបាន ។

២៣ - ប្រក្រតីឥភលវេជ្ជ សូម្បីចំរើនធំប៉ុណ្ណាក៏ដោយ បើព្រះពជាជាម្ចាស់លះបង់ចោលហើយ មិនអាចនៅសុខបេរ បានទេ, ដូចជន្ទូទ្រីជាកេវ្យទេវតា បើនជនដល់កាលមរណៈ ហើយនឹងធ្វើអ្វីកើត ។

២៤– ព្រះពជា អង្គណាមានសេចក្តីកំកពយ នឹងសេចក្តីក្រោធស្ទើរ ភ្លាមានសេចក្តីត្រេកអរក្នុងសាស្ត្រនឹងអាច មានសេចក្តីទុកចិត្តនូវអាមាត្យអស់កាលជានិច្ច, ផែនដីគប្បី បានចំរើននូវទ្រព្យអស់កាលជានិច្ច ចំពោះព្រះពជាអង្គនោះ ។

២៥ - ព្រះពជាអង្គណា ប្រមូលកៀតទ្រព្យសម្បត្តិសូម្បី ១កាកណិតផែលមិនគួរទុះទាយ ក៏នការមិនគួរពោយតុកស្ទើ ទីនព្រះពដទ្រព្យមួយពាន់ទិសុះ តែដល់ការគួរហើយទ្រង់ត្រូវ បរិច្ចាគ ទ្រព្យតាំងកោដិ លក្ខ (ទ្រព្យ-ព្រេង-សេរី-សំណាង) តែនមិនលះបង់នូវសីពា: គោលតព្រះពជាអង្គនោះទៀយ ។

២៦ - ព្រះពជា ជាភាជន៍សម្រាប់ទ្រទ្រង់នូវភោគសុខ (គឺសុខដែលកើតអំពីទ្រព្យសម្បត្តិ) មិនមែនជាភាជន៍សម្រាប់ទ្រទ្រង់នូវកដការទេ, កាលបើកដការវិនាសខូចខាតហើយ មន្ត្រីត្រូវជាប់ទោស ។

២៧– ព្រះភូមិបាល សូម្បីមិនមានការចេះដឹង ក៏អាចទទួលសេចក្តីចំរើនយ៉ាងឯកបាន ដោយសេពគប់អ្នកចេះដឹងវិជ្ជា ប្រៀបដូចព្រឹក្សដែលដុះនៅក្បែរទឹកដូច្នោះ ។

២៨– បើទ្រង់មើលងាយអ្នកចេះដឹង ទ្រង់មុនតែជនអប្បឥតប្រាជ្ញាជាប់ជាប់រាវ, តពៅអាស្រ័យហេតុនេះ ទ្រង់នឹងមិនមានជនអ្នកប្រាជ្ញនៅក្បែរព្រះអង្គឡើយ ព្រោះការមិនស្គាល់ទឹកវិធីនេះឯង, កាលបើពង្សណា លះបង់សេវកាមាត្យជាអ្នកប្រាជ្ញហើយ, ពង្សនោះមិនមានផ្លូវនៃយោបាយល្អទេ, បើវៀបក្តិនយោបាយល្អហើយ ប្រទេសជាតិតាំងមូលនឹងគប់លេច ឬ វិនាសបាត់ចេញពីភពផែនដីលោកនេះឥតសង្ស័យ

ឡើយ ។

២៩– ភរិយាខ្លួនឯង នៅក្នុងកណ្តាប់ដៃនៃស្តេចដទៃគ្រប់គ្រង ដូចជាភាជន៍ សម្រាប់គ្រងនូវបាបអប្បមង្គល ព្រះរាជាប្រព្រឹត្តលើសច្បាប់ ដូចជាសីហៈសម្លាប់ដំរី (ព្រោះសីហៈសម្លាប់ដំរី ទោសធ្លាក់មកសត្វសីហៈ ដោយសាច់ និងឆ្អឹងដំរីត្រូវបានជាអាហារសត្វដទៃ) ។

៣០– មេគោ សម្រាលកូនគោ សុទ្ធសឹងតែមានទ្រង់ទ្រាយដូចមេគោដោយច្រើន រីមេគោបង្កើតកូនបានជាម្ចាស់គោ (គោឧសុភ) មានស្នែងវែងស្ទួនដល់ផងខ្លួន កម្រមានណាស់ ។

៣១– នរជនណា យកធម៌ដាក់ពីមុខ មិនរវល់ថាគិតឲ្យម្ចាស់ ស្រឡាញ់ ឬមិនស្រឡាញ់ ហើយអាចហាមពោលពាក្យពុះពារចំពោះពាក្យមិនជាទីពេញចិត្តម្ចាស់ផង នរជននោះទុកជាមិត្រនៃព្រះរាជា ។

៣២– ព្រះនរបតី ជាប់ព្រះទ័យស្អិតក្នុងកាម មិនគយគន់មើលកិច្ចការរាជការ និងផលប្រយោជន៍របស់ប្រទេសជាតិ ប្រព្រឹត្តធ្វើតែតាមទំនើងព្រះទ័យ ស្រវឹងពន់ពេកក្រៃដូចដំរីចុះប្រេង, កាលតមក ទ្រង់កើតមានក្សត្រគ្រប់សក្តិ ធ្លាក់ព្រះអង្គទៅក្នុងគ្រោះគ្រាំ គឺសេចក្ដីសោកសល់ហើយ, ទ្រង់តែងដាក់ទោសទម្លាក់ទុសមកលើអាមាត្យមុខមន្ត្រី មិនបាននឹកនាដល់ទោសពៃរ៍កើតឡើងដោយព្រះអង្គហើយ ។

៣៣– ក្នុងកាលណាក៏ដោយ ព្រះរាជាមិនគប្បីមើលងាយនូវអាមាត្យដែលធ្លាប់នឹងរៀន នឹងសេចក្ដីអាប់ឱនជាមួយព្រះអង្គដោយយល់ថា វាគ្រាន់តែជា "អាមាត្យ ១" ដូច្នេះឡើយ ។

៣៤– ក្នុងកាល ព្រះរាជាងងឹតងងល់ដោយការស្រវឹងរាជ្យតែងធ្លាក់ខ្លួនព្រះអង្គទៅក្នុងការអាក្រក់ច្របូកច្របល់ ដូចជាដំរីធ្លាក់ជាប់ភក់ មានតែមន្ត្រីជាមិត្រពិតប្រាកដទេ ទើបលូកដៃ

ចូលទៅជួយព្រួយទំស្រង់ព្រះអង្គបាន ។

៣៥– ម្ចាស់ណា គិតតែខ្លួនម្នាក់ឯងឥតពិចារណាកាច ច្រនែនមិនដឹងឧបការៈគេ ម្ចាស់នោះត្រូវអ្នកបំរើដែលប្រសើរ លះបង់ចោល ។

៣៦– សេវកាមាត្យ ដូចគ្នានឹងគ្រឿងអលង្ការណៈជាវិការៈនៃមាស បើគេយកកែវមណីទៅប្រដាប់គ្រឿងអលង្ការណៈជាវិការៈនៃសំណកែវមណីនោះ មិនមានពន្លឺប្រះធ្លុះប្រភ្លឺផងមិនល្អរុងរឿងផង តែការនេះជាកំហុសជាងមាសដោយឡែកទេ ។

៣៧– លើកកញ្ចក់ទៅតុបលើកំពូលមកុដ សម្រេច កែវមណីយកៈទៅប្រដាប់កងជើងវិញ នេះជាទោសនៃកែវមណីឥតអង្គមាន ជាទោសនៃជាងមាសល្ងង់មិនចេះប្រើមិនស្គាល់ដំរៀបទេតើ ? ។

៣៨– កែវមណីយកទៅប្រដាប់ជើង កញ្ចក់យកទៅប្រដាប់សិរសារ ហេតុជាដូចនេះរបស់ណាដូចម្ដេចរបស់នោះ

ទៅតែដូច្នោះដដែល គឺកញ្ចក់នូវជាកញ្ចក់ កែវមណីនៅជាកែវមណី ។

៣៩– ពាក្យដែលត្រឹមត្រូវគួរដល់ការងារ សូម្បីជាសំដីនៃក្មេង អ្នកមានប្រាជ្ញាក៏គួរកាន់យក, បើមិនមានពន្លឺព្រះអាទិត្យទេ ពន្លឺចង្កៀងប្រទីប នឹងមិនមានប្រយោជន៍ឬអ្វី ? ។

៤០– អាមាត្យដែលធ្លាប់លេងល្បែងជាមួយនឹងស្ដេច តែងមើលងាយស្ដេចគ្រប់កាលនាំផ្ដួល ព្រោះការធ្លាប់ស្និទ្ធ ។

៤១– ព្រះរាជា មិនត្រូវដាក់ទណ្ឌកម្មដល់ជនដទៃ ដោយអាងតែយកពាក្យពោលបង្កាច់នៃជនដទៃទៀយ, គួរគប្បីសាកសួរឱ្យឃើញទោសប្រាកដដោយខ្លួនឯង សឹមត្រូវចាប់ចងដាក់ទោសបុគ្គលនោះត្រូវបូជា ។

៤២– នរជន មិនបានពិចារណាគុណនឹងទោសឱ្យឃើញម៉ត់ចត់តាមវិធីមុនសិនទេ មិនគួរអាណិតលើកលែងឬ

ដាក់ទោសវណ្ណកម្មទេ ដូចការមើលងាយ យកដៃលូកចូលទៅ ទ្រាតពស់ ឈ្មោះថាយកសេចក្តីវិនាសមកឲ្យខ្លួនឯងពិតប្រាកដ ។

៤៣– ដោយច្រើន, ព្រះរាជាតែងគាប់ព្រះទ័យនឹងអាមាត្យមិនមានគុណសម្បត្តិ នារីទាំងឡាយតែងសេពគប់ទុជ៌ន ទ្រព្យសម្បត្តិតែងហូរទៅរកតែមនុស្សកំណាញ់ ឯភ្លៀងតែងបង្អុរចុះលើកំពូលភ្នំ និងមហាសមុទ្រ ។

៤៤– ព្រះនរបតី តែងរាប់អាន ជៀបុគ្គលណាដែលនៅជិតជាប់ព្រះអង្គ ទោះមនុស្សនោះល្ងង់ទៀតក្តី ឬមិនបានទទួលខ្លួនដោយប្រពៃក្តី, ឧបមាព្រះរាជា, ស្ត្រីភាពបុលតាជាតិតែងព័ទ្ធព័ទ្ធ ចំពោះតែអ្នកណា ឬដើមឈើណាដែលនៅជិត ។

៤៥– ព្រះរាជា តែងជួបប្រទះតែមនុស្សបញ្ជោររឿយៗ ឯមនុស្សដែលមិនសូវជួបប្រទះនោះ គឺមនុស្សដែលចង់និយាយ

ឬចង់ស្ដាប់តែសេចក្ដីពិត សូម្បីរឿងមិនពេញចិត្ត ។

៤៦– មែនពិត, នរជនណា កាន់យកហេតុណាមួយជាទិដ្ឋិហើយទើបត្រូវក្រោធ នរជននោះកាលបើកំចាត់បង់ហេតុនោះបានហើយនឹងបាត់ក្រេវក្រោធ ហើយកើតសេចក្ដីជ្រះថ្លាក្លាម, បើចិត្តនៃនរជនណា ក្រេវក្រោធស្អប់ដោយមិនមានហេតុធ្វើដូចម្ដេចហ្ន៎ នឹងញ៉ាំងចិត្តនរជននោះ ឲ្យស្ងប់ហើយត្រេកអរបាន ? ។

៤៧– ព្រះនរបតី សូម្បីអាមាត្យប្រតិបត្តិដោយការប្រយ័ត្នប្រយែងដ៏ក្រៃលែង, ក៏មិនសព្វព្រះទ័យត្រេកអរប៉ុន្មាន, តែរឿងនេះទុកជាប្លែកដូចម្ដេចកើត ? ឯអាមាត្យណាមួយដែលគោរពភក្ដីដោយល្អហើយត្រឡប់បានទៅជាសត្រូវវិញនេះទើបប្លែកអស្ចារ្យមែន ។

៤៨– អាមាត្យខ្លះជាអ្នកប្រាជ្ញជាអ្នកស្វាមីភក្ដិស្និទ្ធស្នេហាធ្វើឧត្ដមប្រយោជន៍ចំពោះព្រះរាជាពិតៗ ត្រឡប់ជាបានក្ដីស្អប់

ហើយវិញក៏មាន, មានអាមាត្យខ្លះទៀតក្បត់ព្រះកជាដោយប្រក្បក្រឡាំងៗត្រឡប់ជាបានមេត្រីភាពវិញក៏បាន, ទុចរិតនៃព្រះកជាជាទីជ្រកកោននៃជនទនេះ ប្លែកអស្ចារ្យច្រើនប្រការអ៊ីម្ល៉េះហ្ន៎! សេវកធម៌ (នាទីនៃអាមាត្យ) នេះមានប្រស្នាញែកញែក សាំញ៉ាំស្មុគស្មាញណាស់ សូម្បីព្រះយោគីមានបញ្ញា ក៏មិនអាចប្រតិបត្តិឲ្យល្អបរិបូណ៌បានឡើយ ។

៤៩ — ដោយច្រើន, ព្រះកជាតាំងព្រះទ័យចំពោះទៅលើមន្ត្រីណាដែលមិនជាទីពេញចិត្តនៃជនទាំងពួង, មន្ត្រីនោះច្រើនតែប៉ុនប្រ៉ុខបាយនាដកិត្តិ ប្រើការពោលពាក្យបញ្ជោរលើកដើងកេចំនងណាដែលត្រូវចំណុចព្រះទ័យ ទីងការមិនជាប្រយោជន៍ដល់ប្រទេសជាតិ ។

៥០ — បុគ្គលអាចកត់សំគាល់នូវទឹកចិត្តនៃបុគ្គលដទៃដែលបិតនៅខាងក្នុង ដោយអាការៈខាងក្រៅបាន គឺដោយឥរិយា ដោយគតិ ដោយកិរិយា ដោយទឹកសំដី ដោយវិការៈ

នៃរក្ខុកទឹងមុខមាត់ ។

៥១– ពាក្យសំដី ដែលបុគ្គលពោលហើយ សូម្បីតែបសុសត្វក៏ចាប់យកសំដីបាន, សេះទឹងដំរីដែលគេបានហ្វឹកហ្វឺនល្អហើយ កាលបើគេបង្គាប់អាចនាំយកជនទៅបាន, ជនជាបណ្ឌិតសូម្បីគេមិនទាន់ហាមាត់ចេញនិយាយ ក៏អាចដឹងទាន់ ព្រោះប្រាជ្ញាមានផលដ៏ប្រសើរគឺដឹងនូវចិត្ត នៃជនដទៃដែលមានអាការៈចេញមកខាងក្រៅ ។

៥២– មានរបស់អ្វីមួយ ដែលល្អទឹងមិនល្អទៅតាមសភាពរបស់វាឬទេ? របស់ណាគាប់ចិត្តទឹងជនណា របស់នោះឈ្មោះជាល្អសម្រាប់ជននោះ ។

៥៣– សេះ, សាស្ត្រាវុធ, សាស្ត្រវិជ្ជា, ពិណ, សុន្ទរ-កថា នរជនទឹងនារី វិសេសឬមិនវិសេស ប្រើបានល្អទឹងមិនបានល្អ ស្រេចហើយតែវិធីនៃម្ចាស់អ្នកប្រើអ្នកបង្គាប់បញ្ជាទេ ។

៥៤- ក្នុងកាលណាក៏ដោយ ព្រះច័យភូមិបាលដែលបន្ទ្រព្រះអង្គព្រះញាណ៍បែរទៀបែកហើយ តវិញមិនជាប់ទេ ដូចកងដៃជាវិការនៃកែវផលិតដែលជនឲ្យបែកហើយ ជនណាហ្ន៎ មានអំណាចអាចតឲ្យជាប់ដូចដើមវិញបាន ? ។

៥៥- ក្នុងកាលណាក៏ដោយ, បុគ្គលមិនគប្បីព្រះញាណ៍ធ្វើឲ្យម្ចាស់ផែនដីលែងពឹងពាក់សេវកាមាត្យជាអ្នកប្រាជ្ញទេ, បើសេវកាមាត្យធ្វើឲ្យម្ចាស់លែងពឹងហើយ ទីងដល់សេចក្តីវិនាសឥស្សរៈយសម្ចាស់មិនខាន ។

៥៦- ប្រាជ្ញាប្រសើរខ្ពង់ខ្ពស់ជាងកម្លាំង ការអប្បឥតប្រាជ្ញានាំឲ្យធ្លាក់ខ្លួនទៅតាមដូចដំរី, តែការពោលដូច្នេះដូចហ្វូងដំរីដោយស្គរយោសនាឲ្យលាន់ឮឥតគ្រាប់បែកដំរីទេ ។

៥៧- ធ្វើគុណដល់អសប្បុរស១០០ដងមិនបានផល និយាយពាក្យសុភាសិតដល់មនុស្សល្ងង់១០០ដងឥតអំពើ និយាយពាក្យពិរោះដល់មនុស្សគេ១០០ដងឥតប្រយោជន៍, ប្រើ

ទបាយស្រាថ្នាំ ១០ដងចំពោះដែនឥតការត្រិះរិះពិចារណាក៏មិនបានការ ។

៥៨- នៅលើដើមច័ន្ទន៍មានពស់, នៅក្នុងក្រពាំងដែលដេរដាសដោយផ្កាឈូកមានក្រពើ, នៅក្នុងភោគទ្រព្យមានជនពាលអ្នកកេងកន្លងឈ្លានីស, ក្នុងលោកនេះ សេចក្តីសុខប្រាសចាកខ្វាំងថ្នាក់ចិត្តមិនដែលមានសោះឡើយ ។

៥៩- នៅគល់ដើមច័ន្ទន៍មានអសិរពិស, នៅផ្កាច័ន្ទន៍មានឃ្មុំកាច នៅមែកច័ន្ទន៍មានពានរ, នៅចុងដើមច័ន្ទន៍មានខ្លាឃ្មុំដូច្នេះនៅដើមច័ន្ទន៍តាំងមូល ឥតមានផ្នែកត្រង់ណាដែលមិនមានសត្វចង្រៃអាក្រក់អាស្រ័យនៅទេ ។

៦០- ត្រូវឲ្យវិនាសភាគផែនដីខ្លះ ឬក៏ត្រូវឲ្យវិនាសអាមាត្យដែលមានគុណសម្បត្តិទាំងប្រាំ ? ការវិនាសអាមាត្យទុកដូចជាមរណៈនៃព្រះរាជាទាំងឡាយ, ឯការវិនាសភាគផែនដីគេអាចដណ្តើមវិញបាន មិនមែនដូចខ្លះ ខាតអាមាត្យ

ឡើយ ។

៦១– ហុចដៃបក់ហៅពីចម្ងាយ ក្នែកក្រឡេកមើល ដោយអាការៈស្រឡាញ់ពេញចិត្ត, ហៅឲ្យអង្គុយអាសនៈរួមជាមួយនាក់ណាម្នាក់ លូកដៃទៅត្រកងខ្នប ដោយក្តីស្នេហា. សំដែងអាការៈអើពើទៅនៅសាកសួរ ដោយពាក្យជាទីស្រឡាញ់ពេញចិត្តតែខាងក្នុងពេញទៅដោយពិសពុល, ខាងក្រៅទឹកសំដីផ្អែមដូចទឹកឃ្មុំ ស្ទាត់ជំនាញដោយកលោបាយបោក, ទុនាដកវិធី(កិកក្ខល់ទុបាយអ្នកពាំ)បែបថ្មីនេះ ពួកទុជនសិក្សាយកមកប្រើជាល្បែងបានហ្ន៎ ? ។

៦២– នរជនទៀតទាត អាចប្រឌិតរបស់ដែលមិនពិតឲ្យមើលឃើញថា ជារបស់ពិតប្រាកដបាន ដូចចិត្តកំប្រសព្វ ប៉ុនប៉ាវ អាចគូររូបលើផ្ទៃក្របស្មើឲ្យក្ដុះស្រមោល គេមើលទៅឃើញមានតាបក្ខស់ទៅតាមចិត្តបាន ។

៦៣– មនុស្សរើនុះ វិនាសយស មនុស្សមានចិត្តមិន

ស្មើបាត់មិត្តភាព មនុស្សកែលឥន្ទ្រីយ៍មិនមានត្រកូល មនុស្ស ពេញកមិនមានធម៌ មនុស្សធ្វើសេចក្ដីអន្តរាយវិនាសផលវិជ្ជា, ឯព្រះនរាធិបតីមានតែអាមាត្យ អែបអបស្រវឹងលាភយស វិនាសពាក្យ ។

៦៤– មែនមិត, ដូចជាបិតា ត្រូវតែការពារប្រជាករឲ្យផុតពីភយន្តរាយដែលកើតអំពីចោរ, អំពីអាមាត្យមុខមន្ត្រី, ពីសត្រូវក្រៅប្រទេស, ពីបរិវារជិតព្រះអង្គ និងសេចក្ដីលោភរបស់ព្រះអង្គឯង ។

៦៥– ព្រះភូមិបាល សូម្បីតាំងនៅក្នុងយោពូនវ័យ (ឬពាលល្ងង់ខ្លៅ) បុគ្គលមិនគប្បីមើលងាយព្រះតេស្ដាទុកដូចជាជនសាមញ្ញទេ, ព្រោះជាព្រះរាជា ជាទេវតាមានស័ក្ដិធំមកប្រាកដព្រះអង្គជាព្រះកាយមនុស្ស ។

៦៦– ហេតុដែលគួរឲ្យភ័យខ្លាចមានពីរប្រការ គឺអស-និបាត (រន្ទះ) និងតេជានុភាពនៃព្រះរាជា, អសនិបាតធ្លាក់

បានតែមួយកន្ទេច ឯគេជាទុកាគារនៃព្រះរាជាធ្លាក់នៅជុំវិញខ្លួនយើង ។

៦៧- ដីគ្រាន់តែពាល់ កុជង្គនាគគ្រាន់តែព្រួលពិស ព្រះរាជាគ្រាន់តែក្រោធ មនុស្សទុជ៌នស្ញុំញញឹម ទាំងអស់នេះ សុទ្ធតែធ្វើឲ្យដល់នូវសេចក្តីស្លាប់ទាំងអស់ ។

៦៨- កិរិយាមិនធ្វើតាមអាជ្ញានៃព្រះនរេន្ទ្រ កិរិយាមិនអើពើចំពោះសមណៈព្រាហ្មណ៍ កិរិយាដេកផ្សេងពីភរិយា ទាំងអស់នេះឈ្មោះថាស្លាប់មិនបាច់ប្រហារដោយសាស្ត្រាវុធឡើយ ។

៦៩- ព្រះពាយមិនរំលើងឫសគល់ស្មៅទាំងឡាយដែលទាប ៗ ហើយទន់ពោនក្រាបស្រពាប់ទៅតាមខ្យល់សព្វ ៗ កាល, តែរមែងរំលើងឫសដើមឈើធំខ្ពស់ ៗ, រីអ្នកធំហៅហានរមែងបំបាក់បំបបអ្នកធំហៅហានដូចគ្នា ។

៧០- ព្រះរាជាទតព្រះនេត្រដោយក្រៃលែងចំពោះជនណា ពោះជាព្រះរាជបុត្រក្តី ពោះជាអាមាត្យក្តី ឬជន

បរទេសក្តី លក្ខីតែងតែទៅជាសេរីនៃជននោះ ។

៧១– បុគ្គលគួរបូជាព្រះអាទិត្យពីក្រោយខ្នង បូជាភ្លើងពីខាងពោះ បូជាម្ចាស់ផែនដីដោយកាយនិងចិត្តនិងប្រតិបត្តិធម៌ដើម្បីទៅកាន់បរលោកដោយមិនមានមារយា ។

៧២– ការចិញ្ចឹមខ្ញុំបំរើដែលផ្ទុកអាស្រ័យនៅជាមួយ ការសេពគប់បូជាម្ចាស់ ការប្រតិបត្តិធម៌និងការប្រសូត្រកូន ទាំងអស់នេះឥតមាននរណាលូកដៃទៅធ្វើជំនួសទេ ។

៧៣–ការពឹងពាក់ព្រះនរបតី អ្នកប្រាជ្ញត្រូវការចង់បាន ដើម្បីធ្វើឧបការៈជួយមិត្រ និងដើម្បីបំផ្លាញសត្រូវនរណា ហ្ន៎ ! ពឹងពាក់ព្រះនរបតីព្រោះតែហេតុបំពេញផ្ទៃខ្លួនប៉ុណ្ណោះ ។

៧៤– បើអ្នកណា មានជីវិតរស់នៅបានញុំាងជនដទៃ ច្រើននាក់ឲ្យមានជីវិតរស់នៅបានផង សូមឲ្យអ្នកនោះមានអាយុយឺនយូរ សត្វក្អែកវាមិនអាចបំពេញផ្ទៃវាបានដោយចំពុះវាឬ? ។

៧៥– ការប្រព្រឹត្តចិញ្ចឹមជីវិត ដែលលោកអ្នកសប្បុរសទាំងឡាយសរសើរនៅក្នុងលោកនេះ ដោយគុណណា គុណនោះ បុគ្គលអ្នកមានគុណត្រូវគេក្ដុកដោយប្រពៃផង គួរធ្វើឲ្យចំរើនទៀតផង ។

៧៦– ក្នុងសង្គ្រាម ជនណាកេចបាញ់ព្រួញដើរដោស ព្រះធរណីដ៏ល្អនេះ ដោយសេចក្ដីអង់អាច ដោយទ្រង់ក្រាយ នើតនីនដោយការពេះដ្រាលជ្រៅ ជននោះ កាលនៅជិតព្រះរាជា ក៏ត្រូវនិយាយដោយញញើតញញើម ដោយសេចក្ដីគោរពខ្លាចព្រះចេស្ដា, នៅចំពោះព្រះភក្ត្រ ត្រូវធ្វើគារវកិច្ចបែបនេះជាដើម ។

៧៧– នៅចំពោះព្រះភក្ត្រព្រះរាជា នៅកណ្ដាលប្រជុំពាលទីននៅក្នុងទីប្រជុំស្រីផ្កាមាស សូម្បីនរជនមានសំដីមាត់ក៏មានចិត្តខ្វបខ្វាយទៅជាតក្រិនតក្រនទីមចាំមដែរ ។

៧៨– ពន្ទិតខ្ញាំសត្វជាអនេក ដូចកលមារយាស្ត្រីមាន

ព្រហ្ម គឺថាត្រង់តាមសេចក្ដីពិត ឬមិនត្រង់តាមសេចក្ដីពិតខ្លះ ពោលពាក្យផ្ទើរ ឬក៏ជាទីស្រឡាញ់ខ្លះ, ធ្វើកាចឃោរឃៅ ពុំនោះសោកអាណិតអាសូរខ្លះ, កំណាញ់ស្វិតស្វាញ ពុំនោះ ខ្វលាយជួយទ្រព្យដាដើមទុនខ្លះ, បំណាយព្រះរាជទ្រព្យជា មិច្ច ឬ ពុំនោះសោកទៀត ប្រមូលគៀរគរគេនាំគុំទ្រព្យ សម្បត្តិឲ្យបានច្រើនខ្លះ ។

៧៩– នរជនណា ចង់សម្លាប់ម្ចាស់ ព្រោះប្រាថ្នារាជ្យ ឬក៏ដោយការមើលងាយគំនិត ទោសនរជននោះ បើឲ្យសម តាមកំហុសមានតែបទ១ទេ គឺប្រហារជីវិត មិនមែនធ្វើដោយ បការដទៃទៀតឡើយ ។

៨០– នរជនដែលធ្វើអន្តរាយដល់ជីវិត (ធ្វើគត់ព្រះរាជា) នោះបិតាឬបងក្ដី ពុំនោះជាបុត្រឬមិត្រសំឡាញ់ក្ដី ព្រះរាជាប្រាថ្នាសេចក្ដីចំរើន ត្រូវតែសម្លាប់ចោលចង់ ។

៨១– ការអត់ធុនចំពោះសត្រូវ ឬមិត្រជាគ្រឿងលំអរ

នៃអ្នកប្រាជ្ញដែលបំពេញព្រឹត្ត (ធម៌) ពិតមែនហើយ, តែទុកនូវសត្វដែលមានកំហុសនេះ ត្រឡប់ជាគ្រឿងប្រទុស្តនៃព្រះរាជាទាំងឡាយវិញទេ ។

៨២- ព្រះរាជាអាណាតហួសមាត្រា, ព្រាហ្មណ៍បរិភោគសាច់មិនបន្ទោះ, ភរិយាមិននៅក្នុងឱវាទ, មិត្រមាននិស្ស័យបង់ធ្វើឲ្យអន្តរាយ, អ្នកបំរើនឹងខឹង, ភ្នាក់ងារពេទ្យប្រហែស ទឹងមនុស្សអកតញ្ញូ នាំឲ្យគ្នាលះបង់គោលទ្រព្យប្រ-ឡោះចេញ ។

៨៣- សេចក្តីសន្តោសជាវិបត្តិនៃព្រះរាជា, សេចក្តីមិនសន្តោសជាវិបត្តិនៃសមណៈព្រាហ្មណ៍, ក្តីអៀនខ្មាសជាវិបត្តិនៃស្រ្តីជាមាស ក្តីមិនអៀនខ្មាសជាវិបត្តិនៃកុលធីតាទាំងឡាយ ។

៨៤- បុគ្គលដែលកើតមកក្នុងលោកនេះ គប្បីធ្វើនូវពលិកម្ម៥យ៉ាងគឺ គប្បីជួយបង់ពន្ធអាករដល់ម្ចាស់ផែនដី

ជួយទំនុកបំរុងញាតិ, ធ្វើបដិសណ្ឋារៈទទួលភ្ញៀវ, ធ្វើបុណ្យឧទ្ទិសដល់ញាតិដែលស្លាប់ទៅហើយ, និងធ្វើសក្ការៈបូជាដល់ទេវតាដែលជួយដោះទុក្ខយើង ។

៨៥– សូមព្រះភូមិបាលទាំងឡាយ រក្សាប្រជាជនទៅលើផែនពសុធាដោយប្រពៃ ហើយស្ថិតនៅក្នុងទសពិធរាជធម៌ជានិច្ចជានិរន្តរតទៅ។ សូមព្រះករុណាគ្រប់ព្រះអង្គទាំងព្រះទ័យជាសប្បុរស មានសេចក្តីពេញចិត្តនិយមប្រើនីតិសាស្ត្រ ទុកនីតិសាស្ត្រនេះដូចជាព្រះជាយាចមួយព្រះអង្គទៀត។ សូមសាធុជនទាំងឡាយ សាមគ្គីមូលត្រកូលបងប្អូនគ្នាជាសាមគ្គីឲ្យមានមិត្រភាព។ សូមប្រជាជនក្នុងជនបទសម្បូណ៌ដោយសេរីសម្បត្តិគ្រប់ការ។ សូមទេវតាមានសក្តិធំប្រសិទ្ធពរបវរសួស្តីដល់មហាជន ឲ្យប្រកបដោយវិបុលសុខសេរីសួស្តីជ័យមង្គលគ្រប់ទិនទិវារាត្រីទៅហោង។ ។

ចប់.

# សង្គ្រាមវគ្គ

១ – ក្នុងកាលខ្វះ សេចក្ដីអត់ធន់ជាគ្រឿងលំអនៃបុរស ដូចក្ដីអៀនខ្មាស ជាគ្រឿងលំអនៃស្ដ្រីទាំងឡាយ; តែក្ដីក្លាហានជាគ្រឿងលំអនៃបុរសក្នុងកាលត្រូវគេមើលងាយ ដូចការមិនអៀនខ្មាសជាគ្រឿងលំអនៃស្ដ្រី ក្នុងកាលសេពសន្ថវៈ ដូះប្ដាះដែរ ។

២ – នរជនណា កាលមើលឃើញការមានកម្លាំងទទឹង ការឥតកម្លាំងនៃខ្លួនទទឹងសត្រូវហើយ មិនស្គាល់ប្រភេទផ្សេងគ្នាទៀត នរជននោះត្រូវសត្រូវមើលងាយ ។

៣ – ដកបណា ក្ដីភ័យក្ដារៈមិនទាន់មកដល់ទេ ដកបនោះបុគ្គលគប្បីប្រុងប្រយ័ត្នដល់ភ័យនោះ, បើភ័យមកដល់ហើយ គប្បីក្លាហានតស៊ូនឹងភ័យនោះតាមគំនិតដែលខ្លួនបាន

គិតទុកមុនស្រេច ។

៤– គួរប្រើចារបុរស ក្នុងការស៊ើបអង្កេតឲ្យដឹងសេចក្តីជាគួរធ្វើនឹងមិនគួរធ្វើ ក្នុងប្រទេសខ្លួន នឹងបរទេសជាមុនសិន ព្រោះចារបុរសជាព្រះនេត្រានៃព្រះរាជា, ព្រះរាជាអង្គណាមិនមានសូម្បីតែម្នាក់ ព្រះរាជាអង្គនោះ ទុកដូចជាមនុស្សខ្វាក់ពិត ៗ ។

៥– ព្រះរាជាត្រូវបញ្ជូនចារបុរស ឲ្យយកភេទជា តាបស ឲ្យចូលទៅសិក្សាសាស្ត្រដ៏ក្នុងបុណ្យស្ថាន ក្នុងអាស្រម ឬក្នុងទេវស្ថានផ្សេង ៗ ។

៦– មន្ត្រីការសម្ងាត់នេះ បើដឹងដល់ត្រចៀក៦ ហើយតែងបែកធ្លាយ ហើយខ្ជាយទៅដោយការនិយាយតៗគ្នា ហេតុនេះព្រះរាជាគប្បីរក្សាការសម្ងាត់បានចំពោះតែរូបព្រះអង្គនឹងមនុស្សជាគំរប់ពីរប៉ុណ្ណោះ ៗ

៧– កាលបើមន្ត្រីការសម្ងាត់បែកធ្លាយហើយ ទោស

តែងធ្លាក់ស្រាចមកលើព្រះកជា ទោសនេះមិនងាយបុគ្គល
កែសម្រួលឲ្យបានងាយទេ នេះជាមតិអ្នកនយោបាយ ៗ

៨– ការៈ នៃបារបុរស ត្រូវលួងលោមបោកផន
បរទេសដោយឲ្យត្រូវគាប់ចិត្ត ដូចជាបង្ហាញបាច់សៅឲ្យ
គោសុី ដើម្បីចាប់ចងផ្ដាច់, ការលួងលោមបោកផនឲ្យ
ជឿទុកចិត្តហើយ តាំបាច់ប្រើសេចក្ដីក្លៀតក្លាតអ៊ីប៉ុន្មាន ដូច
ជាការប្រហារដនដែលដេកស្លាយើងហើយ តាំបាច់ប្រើសេច-
ក្ដីអង់អាចជាជាតិបុរសអ៊ីប៉ុន្មាន ៗ

៩– ពិតណាស់ នរជនណាដឹងថាខ្ជិនពោលពាក្យ
សច្ចៈដូចខ្លួនដឹងដែរ នរជននោះត្រូវខ្ជិនលួងលោមបោកបាន
ដោយងាយ ហើយនឹងត្រូវទទួលផលគឺសេចក្ដីវិនាសអន្តរាយ
ក្នុងអនាគត ៗ

១០– អ្នកប្រាជ្ញបើមានកិច្ចការណាមួយ ដែលត្រូវធ្វើ
ទានមិនបាន សូម្បីតែសត្រូវក៏ត្រូវយើងទូលលើក្បាល ហើយ

ដែលអាចគ្រាតែបានសម្រេចកិច្ចរបស់មាតុប្រទេសដែរ ។

១១– ត្រូវព្យាយាមបំបែកសត្រូវឲ្យបែកបាក់គ្នា វិធីបំបែកនេះមិនមានអ្វីដទៃក្រៅពីការញុះញង់ ព្រះពលទាហាន កងពលសត្រូវ ព្រោះហេតុនោះត្រូវព្យាយាមតាំងពលទាហាន របស់ប្រទេសសត្រូវឲ្យទាល់តែបាន ។

១២– ក្នុងការផ្ដើមធ្វើសង្គ្រាម សេវកណាមិនមានការពិចារណាមត់ចត់ ដឹកនាំព្រះរាជាឲ្យធ្វើសង្គ្រាម ឬឲ្យលះបង់ប្រទេសជាតិចោល សេវកនោះសមជាអាមាត្យឬទេ? សមជាមន្ត្រីឬទេ?

១៣– ជនទាំងឡាយ មិនធ្លាប់ចូលសង្គ្រាម តែងអួតអាងថាខ្លួនក្លៀវក្លា នរណាមួយដែលមិនទាន់ឃើញសមត្ថភាពនៃសត្រូវទេ ម្តេចឡើយមិនទៀងចិត្តទ្រទង់? ។

១៤– ក្នុងកាលណាក៏ដោយ ព្រះរាជាគប្បីយកឈ្នះសត្រូវដោយការផ្សះផ្សាខ្លះ ដោយការបំបែកបែកខ្លះ ដោយ

ប្រើឧបាយបំបែកសាមគ្គីខ្លះ  គប្បីប្រើឧបាយទាំងនេះឬប្រើឧបាយណាមួយៗ  ធ្វើដូចម្ដេចក៏ឲ្យកើតសង្គ្រាមបាន ។

១៥- នរជនណាមិនទាន់ដល់ការគួរ ហើយធ្វើសង្គ្រាម អ្នកនោះឈ្មោះថាមនុស្សល្ងង់ ព្រោះថាការច្បាំងតទល់អ្នកមានកម្លាំង  ប្រាកដដូចជាការប្រើស្លាបរុយឲ្យហោះដូច្នេះ ។

១៦- ការច្បាំងទល់អ្នកមានកម្លាំងជាង ដូច្នេះមិនមានជាឧទាហរណ៍ទេ  មនុស្សច្បាំងតទល់ដំរី ឈ្មោះថានាំម្រឹត្យុមកឲ្យឥតសង្ស័យ ។

១៧- ក្នុងកាលណាក៏ដោយព្រះរាជាគប្បីព្យាយាមយកជ័យជំនះ ចំពោះសត្រូវដោយការមិនច្បាំងឲ្យបាន  ព្រោះកាលបើអ្នកទាំងពីរខាង ច្បាំងតយុទ្ធគ្នាហើយគេមិនសូវឃើញមានជ័យជំនះទៀងទាត់ទេ ។

១៨- បុគ្គល មិនគប្បីអាចគាស់លើកដុំថ្មធ្ងន់ ដោយកម្លាំងមនុស្ស បានស្មើដោយការប្រើកំណាត់ឈើទេ  យ៉ាង

ណា ដោយការខំប្បាយតែបន្តិច គេអាចសម្រេចប្រយោជន៍ធំយ៉ាងនោះ, នេះហើយការប្រើកក្រក់ខំប្បាយមានផលធំណាស់ ដូច្នេះ ។ ...

១៩– មែនពិត ការប្រឹងហួសកម្លាំងជាខបស្គុំខាងដើមនៃការសម្រេចសព្វកិច្ចការទាំងអស់ ចំកស្មូប្យត្រជាក់ទីនមិនចំណាយក្តីបានឬអ្វី ? ។

២០– កសិកម្មដែលបានផលល្អ មកពីការគេប្រឹងព្យាយាមធ្វើល្អ មិនចត់ទៅតាមកាលវេលាយ៉ាងណា នរយោបាយនេះគេធ្វើដោយម៉ត់ ហើយអស់កាលយូរជង់ទើបបានផល មិនមែនធ្វើដោយកញ្ចក់កណ្តៀតទេ ។

២១– ភ័យនៅឆ្ងាយ មានក្តីខ្លាច (គឺគប្បីប្រុងប្រៀប) ភ័យមកដល់ជិតមានសេចក្តីក្លៀវក្លា (គឺក្រោកតស៊ូមិនរុញរា) នេះជាគុណលក្ខណៈមហាបុរស កន្ត្រាវិបត្តិនៅនាលោកនេះ មហាបុរសជាអ្នកសំដែងខ្លួនជាធំជេន ។

២២– នវជនបេះដឹងនយោបាយ (ទីតិសាស្ត្រ) ត្រូវនៅក្នុងគ្រឿងការពារដូចអណ្ដើកនៅក្នុងស្នូក ហើយត្រូវបេះអត់ធន់ គ្រឿងប្រហារទៅសត្រូវផង កាលបើកាលគួរមកដល់ ហើយគប្បីលោតឡើងតស៊ូ ដូចពស់មានអាសិរពិស ។

២៣– នវជនបេះនយោបាយ អាចរំលើងឫសគល់សត្រូវទោះធំតូច ឬក៏ប៉ុនគ្នាបាន ដូចខ្សែទឹកអាចនាំយកឈើ ឬស្មៅទាំងឫសទាំងគល់បានដូច្នោះដែរ ។

២៤– គួរសាងបន្ទាយការពារ ហើយឲ្យមានគូធំ ។ មានប្រាការខ្ពស់ ។ មានគ្រឿងយន្ត មានទឹក មានភ្នំ មានខន្ទពលខ្វក់ចន់នឹងគ្រឿងការពារ ។

២៥– សម្បត្តិបន្ទាយការពារមាន៧ប្រការដូចខាងលើនេះ ត្រូវកសាងឲ្យមាំធំ សត្រូវចូលប្រយុទ្ធលំបាកជាទីបំផុត ត្រូវមានឃ្លាំងដាក់ស្បៀងអាហារ ទឹកស្រូវអង្ករ ហើយឲ្យមានផ្លូវចេញចូល ។

២៦- ប្រទេសជាតិដែលឥតបន្ទាយការពារ គឺឥតមាន ម័កឹង ដូចជាមនុស្សម្នាក់គីសំពៅកណ្ដាលសមុទ្រ ។

២៧- រដ្ឋមន្ត្រី១ ព្រះរាជមិត្រ១ ព្រះរាជទ្រព្យ១ ព្រះរាជអាណាចក្រ១ បន្ទាយព្រះអង្គ១ កងពលព្រះអង្គ១ នឹងសម្ពន្ធមិត្រ១ ទាំង៧ផ្នែកនេះជាសារវន្តនៃរដ្ឋាភិបាល ។

២៨- បន្ទាយ១ មេទ័ព១ រដ្ឋមន្ត្រីឃ្លាំង១ អគ្គរាជទូត១ បុរោហិត១ ហោរាសាស្ត្រ១ នឹងពេទ្យ១ ទាំង៧នេះ ទុកជាទីប្រឹក្សានៃព្រះរាជា ។

២៩- ទាហានជើងម្នាក់នៅក្នុងបន្ទាយ សម្លាប់ទាហានសត្រូវបាន១០០នាក់ ទាហានជើង១០០នាក់ សម្លាប់ទាហានសត្រូវបាន១០០០នាក់ ព្រោះហេតុនោះការតាំងបន្ទាយការពារទុកមុនជាកិច្ចសំខាន់មួយ ។

៣០- ការប្រមូលគរទុកនូវស្រូវអង្ករជាស្បៀងអាហារ ប្រសើរជាងប្រមូលទុកនូវទ្រព្យឯទៀត, ព្រោះថាពេជ្រទទឹម

ដែលបុគ្គលយកមកក្រាទុកក្នុងមាត់ មិនអាចធ្វើឲ្យធំរីកច្រើនទៅបានទេ ។

៣១– បណ្តាវត្ថុទានរសជាតិគេទាំងអស់ អំបិលគេទុកជាវត្ថុមានរសប្រសើរជាងគេ បុគ្គលគប្បីស្វែងរកអំបិលទុកកុំបីឃ្លាត ព្រោះថាបើឥតអំបិលហើយសម្លគេទុកដូចជាគោម័យ ។

៣២– បុគ្គលគប្បីប្រឹងប្រយ័ត្នកុំឲ្យជនបរទេសជាសត្រូវចូលមកនៅអាស្រ័យជាមួយបាន ព្រោះជនបរទេសអាចបំបែកមន្ត្រី រដ្ឋាយាចឬព្រះរាជាម្ចាស់ផែនដីឲ្យបែកសាមគ្គីទៅក្រោយកម្លាំងមិនខាន ហើយអាចមើលឃើញការមានកម្លាំងនិងការឥតកម្លាំងរបស់យើងទៀតផង ជនណាស៊ូទុស្សាលចំពោះសត្រូវ ដោយការពេះអានក្តី ដោយយល់ខុបការក្តី ជននោះទុកដូចជាមនុស្សដេកលក់លើដើមឈើ ហើយបេក្ខាត់ធ្លាក់មកដល់ដីទើបភ្ញាក់ដឹងខ្លួន ។

៣៣- បើសត្រូវស្គាល់ចំណុចខ្សោយរបស់យើង និងសេចក្ដីក្លៀវក្លារបស់យើងហើយ គេនឹងចូលទៅដល់ក្នុងចិត្តគំនិតយើងខាងក្នុងទៀត ហើយសម្លាប់យើងពេលបន្ទៀត, ដូចកើនៈនេះឈើស្អុតតែងនេះរូវហូតដល់ខ្លឹមខាងក្នុង ។

៣៤- កាលណាសាមាគ្យជាពួកអ្នកមានចិត្តស្រឡាញ់មានភក្ដីយាំហើយវិនាសចំពោះសត្រូវ កាលណោះគប្បីធ្វើសង្គ្រាម ព្រោះជាការធ្វើសង្គ្រាមដោយធម៌ មិនមែនជាវិធីត្រឹមត្រូវទេ ។

៣៥- ត្រូវបានភាគផែនដី សម្ពន្ធមិត្រ បានមាស នេះជាផល៣ប្រការដែលគេត្រូវធ្វើសង្គ្រាម កាលណាបើគេប្រាកដជាបានផលទាំង ៣ ប្រការនេះហើយ កាលនោះគេត្រូវធ្វើសង្គ្រាម ។

៣៦- មនុស្សល្ងង់ណា មិនបានពិចារណាសេនានុភាពពៃរីហើយចូលទៅប្រយុទ្ធដោយស្រេកន មនុស្សល្ងង់

នោះនឹងបានទុបមុខជាប់ នេះជាសច្ចៈឥតសង្ស័យឡើយ ។

៣៧– នរជនណា ទ្រាំតក់នឹងកិច្ចការណា គួរតាំង នរជននោះឲ្យចាត់ចែងការនោះ នរជនដែលមិនធ្លាប់ប្រសព្វ កិច្ចការនេះ សូម្បីចេះដឹងសាស្ត្រវិជ្ជាក៏មែនធ្វើការមិនដឹតដល់ ដែរ ។

៣៨– នរជនណាមិនមានប្រាជ្ញាខ្លួនឯង សាស្ត្រវិជ្ជា នឹងធ្វើអ្វីដល់ជននោះកើត? នរជនខ្វាក់ភ្នែកទាំងសងខាងកញ្ចក់ នឹងធ្វើប្រយោជន៍អ្វីឲ្យដល់នរជននោះបាន ? ។

៣៩–ដោយពិតនរជនអប្បឥតប្រាជ្ញា សូម្បីប្រាថ្នាធ្វើ ការតូចតាច តែងសំដែងអាការៈទ្រេះទ្រះ, ឯអ្នកមានប្រាជ្ញា សូម្បីប្រាថ្នាធ្វើការធំ ១ នៅនឹងថ្កល់ដូចថ្មមិនសំដែងអាការៈ ទ្រេះទ្រះឡើយ ។

៤០– សេចក្តីសោកសៅ ចម្ងាយចង់ទៅសេចក្តីភ័យ, សេចកាល់ចំណាយចង់ទៅសោភាគ្គងើរទៅក្តៅ, ព្រះពេចក្ស

ទម្លាយបង់នូវងងឹត, ការមិនតបគុណ ទម្លាយបង់នូវសេចក្ដីល្អ, ការបានធ្វើអ្វីមួយជាទីស្រឡាញ់ ទម្លាយបង់នូវការខូចចិត្ត, នយោបាយល្អ ទម្លាយបង់នូវការវិបត្តិ, នយោបាយមិនល្អ ទម្លាយបង់នូវសេរីសួស្ដីដែលខ្លួនបានហើយ ។

៤១– សេចក្ដីពិត, សភាពនៃជនណាដូចម្ដេច នរជននោះមិនអាចប្រព្រឹត្តក្នុងសភាពខ្លួនបានឡើយ បើលើកឲ្យសុនខជាតិឲ្យធ្វើជាស្ដេច ក៏នឹងមិនអាចធៀមទ្រទាប់ជើងនៃស្បែកឬអ្វី ? ។

៤២– នរជនណា លះបង់ពេលពួកបក្សខ្លួន ហើយត្រេកអរចូលដៃនឹងបរបក្ស (ជនបរទេសជាសត្រូវ) វិញ នរជននោះជាមនុស្សល្ងង់ ត្រូវបរបក្សសម្លាប់ពេលបន្ទៀតមិនខានឡើយ ។

៤៣– ជាបើបុគ្គលរត់ចេញពីសង្គ្រាម ក៏ស្ងួមរក្ខម ហើយមិនមានភ័យពីក្ដីស្លាប់ទៀតទេ ដូច្នេះក៏គួរគេរត់ចេញ

ទៅវិញដែរ តែសេចក្ដីស្លាប់ជាធម៌ទៀត សម្រាប់សត្វគ្រប់រូបគ្រប់នាមហើយ ហេតុអ្វីក៏ឲ្យកិត្តិយសខ្លួន ប្រឡាក់សៅហ្មងដោយឥតប្រយោជន៍ ។

៤៤– ភពលោកនេះ មានតែការបែកធ្លាយដូចជាការពពុះពពាននៃរលកទឹក ដែលខ្យល់ទាក់បក់រលាយហើយ ការលះបង់ជីវិតដើម្បីប្រយោជន៍ដល់ជនដទៃ (ជាជាតិរួមឈាមជាមួយ) ឈ្មោះថាប្រកបកិច្ចការជាបុណ្យ ។

៤៥– ឯជនណា ក្លៀវក្លាហានលះបង់ជីវិតដើម្បីម្ចាស់ក្នុងសង្គ្រាម មានភក្តីចំពោះអ្នកចំពាម ជាបុគ្គលកតញ្ញូ ឯជននោះទៅកាន់ស្ថានសួគ៌ ។

៤៦– អ្នកប្រាជ្ញគប្បីលះបង់ទ្រព្យធន ទាំងជីវិតផង ដើម្បីជាប្រយោជន៍ដល់ជាតិ ថាបើសេចក្ដីស្លាប់ជាធម៌ទៀត គួរលះបង់អត្តភាពខ្លួនទើបប្រសើរ ។

៤៧– ឯជនណាប្រតិព័ទ្ធនឹងជនណា (ឬសញ្ជាតិជា

មួយគ្នា) គប្បីមានការខ្ពង់ខ្ពស់ក្នុងការជោគជាំបមួយអន្ទើដោយ ជននោះ, នាជននោះគួរប្រគល់ជីវិតជនទ្រព្យធន ដល់ជននោះដើម្បីប្រកបកិច្ចការទាំងពួង ។

៤៧– វីរៈបុរសជាតិអ្នកចម្បាំង ដែលសត្រូវឡោមព័ទ្ធជាប់ហើយ គេបំណាន់ប្រហារជីវិតបង់ក្នុងទីណាក៏ដោយមិនតក់ស្លុតលះបង់ឋានៈជាកូនប្រុស នឹងបានទៅដល់អមរលោក ។

៤៨– មេគោសម្រាលកូនគោ សុទ្ធសឹងតែមានទ្រង់ទ្រាយដូចមេគោដោយច្រើន ពីមេគោបង្កើតកូនបានជាម្ចាស់គោមានសែនសំស្បើនដល់ដង្ខូនកម្រមានណាស់ ។

៤៩– ម្ចាស់ណា គិតតែខ្លួនឯងម្នាក់ឥតពិចារណាគាបទ្រង់មិនដឹងទុក្ខបការៈគេ ម្ចាស់នោះត្រូវអ្នកបំរើដែលប្រសើរលះបង់ចោល ។

៥០– ទាហានទាំងម្ចាស់ត្រូវស្គាល់ចិត្តគ្នាទៅវិញទៅមក មានសេចក្តីភក្តីយ,- មានចិត្តជាប់លះបង់ជីវិតជាពលី, ជាអ្នក

មានត្រកូល, ជាអ្នកតីមទ័ពសសេរីហើយតាចកម្រមតលពៃ

រីបានគេយប្រពៃ ។

៨១– ពាហានណា ទៀនសេះចុលប្រយុទ្ធសម្បីទៅតា

កំរំបាកទីងរ៉ះតល្អះភាហាននោះបាន ព្ទះតែរីបើទុកជានៅ

ក្ចាយកំទុកដូចជាឆ្កាត់មកនៅក្នុងកណ្ដាប់ដៃស្រេចហើយ ។

៨២– មនុស្សគ្រីនលោក ចូលទៅច្បាំងដោយក្លាហាន

ព្រោះចង់បានកិត្តិយសរីមាស់របស់ខ្លួន មិនមែនចង់បានស្រាក់

តីទ្រព្យទេ ។

៨៣– ថាបើបុគ្គលគប្បីបានទូវកិត្តិយស ដែលទៀន

ពាក់មិនមានមន្ទិលតីការបរិច្ចាគកាយ ដែលផ្ទុកដោយគ្រឿង

មន្ទិលសៅហ្មងស្មោកគ្រោកមិនទៀនពាក់នេះបាន បើដូច្នោះ

តើបុគ្គលទីងមិនគប្បីបានទូវគុណធម៌គឺកិត្តិយសនោះឬអ្វី? ។

៨៤– សរីរៈ (កាយ) ទីងតិត្តិគុណា មានចន្លោះតាំង

នៅក្ដាយពីភ្លាះទូង់លទ្ធាចណាស់,. សរីរៈនេះរលត់រលាយ

នៅក្នុងខណៈ ឯកិត្តិគុណស្ថិតនៅហេតុផលរបស់កល្យាណទី
បុរសគប្ប ។

៥៥– ស្លាប់ហើយ បានកើតក្នុងឋានសួគ៌ សម្រាប់សត្រូវហើយបានសេចក្ដីសុខ ធម៌ពីប្រការនេះឯងជាធម៌មានគុណប្រសើរបំផុត គេធ្វើបានដោយកម្រក្រៃលែងមានតែបុរសមានចិត្តក្លៀវក្លាហានទេទើបអាចធ្វើបាន ។

៥៦– បើមានជ័យត្រូវបានទ្រព្យសម្បត្តិឬភាគផែនដី បើបានជាស្លាប់វិញក៏ត្រូវបានជាកស្ដាស្រីទេវអប្សរបរិវារកញ្ញា, កាយរមែងនេះ ជារបស់ត្រូវបែកធ្លាយទៅមួយខណៈៗទេ ហេតុអ្វីក៏ញញើតញញើមមិនហ៊ានស្លាប់ក្នុងរណរង្គ ។

៥៧– «ការស្លាប់និងការកើតវិញ» ជាធម៌ទៀងពិតប្រាកដ ហេតុនេះនរជនជាអ្នកប្រាជ្ញ គប្បីលះបង់នូវទ្រព្យធន នូវជីវិតផង ដើម្បីការពារមាតុប្រទេសជាប្រយោជន៍ដល់បច្ចាជនជាជាតិរួមឈាម ។

៥៨– នរជនក្រៀវក្រាហារ លះបង់ជីវិតធ្វើជាទាន ដើម្បីម្ចាស់កងសង្គ្រាម មានភក្ដីចំពោះអ្នកចំបាំង ជាបុគ្គលកតញ្ញូ, កាលធ្វើទានថែបទនេះលោកហៅថា «ជីវិតទាន» ស្លាប់ហើយមិនបានកើតក្នុងឋានសួគ៌ឥតសង្ស័យឡើយ... ។

៥៩. បុគ្គលភប្បីជ្រាបថា, នរជនណាចូលប្រយុទ្ធក្នុងសង្គ្រាម បានតាំងចិត្តអធិដ្ឋានថា «សូមឲ្យកើតជាជាតិដូចដើមវិញ» ការស្លាប់នៃនរជននោះអាចចូលមកកើតជាទីដើមវិញ យ៉ាងយូរ៧ថ្ងៃ, ៧ខែ ឬក៏៧បក្ស នេះជាសច្ចៈ, ព្រោះជាបុគ្គលមានចិត្តជាប្រធាន មានចិត្តជាធំ ជាងសហជាតិឯមិតាំងពុយ ។

៦០– នរជនណាក៏ដោយ សូម្បីលេចលង់ក្នុងកណ្ដាលសមុទ្រ ឬធ្លាក់ពីលើភ្នំ ឬក៏ត្រូវនាគ-ពស់ចឹក បើមិនទាន់ដល់កាលស្លាប់ទេ អាយុនៃនរជននោះ នៅតែថែរក្សាជីវិតិន្ទ្រីយ៍ឲ្យរស់នៅតទៅបាន ។

៦១- មនុស្សលោក សូម្បីត្រូវរស់ ១០០ ឆ្នាំ បើមិនទាន់ដល់កាលក៏មិនស្លាប់ តែបើដល់កាលមរណៈហើយ សព្វបើមុតដោយស្បៀងថ្នាំឪសថ ឬឆ្មាំគពីលើខ្នើយក៏ដោយ ក៏ស្លាប់ដែរ ។

៦២- វត្ថុណាមួយ មិនមានគេថែរក្សា តែបើមានបុណ្យជួយថែរក្សាក៏អាចរស់នៅឬគង់នៅបាន, វត្ថុណាមួយដែលគេថែរក្សាប្រយ័ត្នប្រយែង តែបុណ្យរាសីនាមិនជួយថែរក្សាផង ក៏វិនាសអន្តរាយទៅបាន, ប្រៀបដូចទុជនដែលគេបោះបង់ចោលក្នុងកណ្តាលព្រៃជ្រៅ ក៏គង់មានជីវិតរស់នៅបាន, ឯនរជនខ្លះគេថែរក្សាដោយប្រយ័ត្នប្រយែង ទុកក្នុងប្រាសាទឬក្នុងរូងផ្ទះក៏អាចស្លាប់ទៅបានដែរ ។

៦៣- ជនខ្លះក្រៀវក្រា តែងបានទ្រព្យជនបរិភោគអាហារល្អឆ្ងាញ់ តែងមិនមានរោគ ជនមិនមានរោគតែងបានសេចក្តីសុខ ជនមានពព្យាយាមតែងបានដល់ត្រើយនៃវិជ្ជា

ជនមានវិន័យតែមិនបានសេចក្តីចំរើនទ្រព្យសម្បត្តិ និងយសស័ក្តិ

៦៤– ចាពោនអ្នកចម្បាំង មានវិន័យល្អ ព្រមព្រៀងគ្នា មានទឹកចិត្តដាច់ខាត សុទ្ធតែជាវីរៈយោធា សូម្បីតែ៥០០ នាក់ក៏អាចសំរាប់វាយសត្រូវបាន ១ វាហិនី[១]បាន ។

៦៥– កងទ័ពមានចំនួនតិច តែសុទ្ធសឹងវិញ្ញូជនវិន័យ ប្រសើរកងទ័ពមានចំនួនច្រើន តែសុទ្ធតែយោធាអសំពាស មិនល្អទេ ព្រោះយោធាអសំពាសបណ្តាលឲ្យចាញ់ឆាប់ ហើយនាំឲ្យខាងបានវិញ្ញូជនយកជ័យថែមទៀតផង ។

៦៦– សេចក្តីពិត ស្រី (គឺជ័យជំនះសេរីសួស្តី) ឯណា ដែលបុគ្គលមិនគប្បីបានដោយតម្លៃនៃការបរិច្ចាគកាយ ស្រី នោះសូម្បីមានការត្រេកត្រអាលយ៉ាងណាៗ ក៏មិនតែងទៅរកបុគ្គលអ្នកចេះតែនឹងទីសាស្ត្រ (នយោបាយ) ។

---

១) គឺ ១ កងទ័ព មានដំរី ៨១, រថ ៨១, ទាហានសេះ ២៤៣, ពលថ្មើរជើង ៤០៥នាក់ ។

៦៧- អ្នកប្រាជ្ញ គប្បីលះបង់ទ្រព្យផង ជីវិតផង ជា ពលីកម្មដើម្បីការពារជាតិ ការបរិច្ចាគជីវិតក្នុងអំពើល្អបែបនេះ ជាកិត្តិយសប្រសើរណាស់ បើសេចក្តីកើតមិនសេចក្តីស្លាប់ ជាធម៌ទៀង ។

៦៨- បុគ្គលមិនគប្បីធ្វេសប្រហែសដោយគិតថា ឈ្នះ បានប្រទេសហើយដូចេះមិនគួរទេ ព្រោះថាការមិនអាទរើយ អាចបំផ្លាញព្រះពុទ្ធសាសនាចក្របាន ដូចជាដកក្ទើទ្បុះសោភា វិនាសបាន ។

៦៩- អ្នកប្រាជ្ញពោលថា បន្ទាយដែលមានសេចក្តី អន្តរាយ គឺបន្ទាយមិនមាំគ្រាំគស្បៀងមិនបាន, គូចពក, មេបញ្ជាការល្ងង់ឬគម្រក់ ការពារមិនល្អ មានតែយោធាកម្សាក ។

៧០- គ្រពើដែលហៅហានពន្លក បើចេញផុតពីរកហើយ គឺអន់អំណាច, សីហៈសូម្បីសាហាវយង់ឃ្នង បើចេញផុតពីព្រៃហើយដូចគ្នានឹងសត្វចចក ។

៧១– បណ្ដាទីតាំងឡាយ មានស្ទឹង ព្រៃ ភ្នំ បន្ទាយ ជាដើមណាមានភ័យ សេនីយត្រូវលើកព្យូហ៍ក្នុងពេលយាត្រាទ័ពទៅក្នុងទីនោះ ។

៧២– សេនាបតី ព្រមជាមួយមេកងពលក៏បានត្រូវដើរទៅមុខទ័ព. ត្រូវដាក់ស្ត្រី ម្ចាស់ដែនដី ឃ្លាំង ទ័ពពលដែលកំឡាំងខ្សោយនៅកណ្ដាលទ័ព ។

៧៣– ត្រូវដាក់កងទ័ពសេះ នៅស្លាបទ័ពទាំងសងខាង នៅខាងទ័ពសេះត្រូវដាក់ពលរថ នៅសងខាងពលរថត្រូវដាក់ពលដំរី នៅសងខាងពលដំរីត្រូវដាក់ពលថ្មើរជើង ។

៧៤– សេនាបតីត្រូវដើរទៅខាងក្រោយទ័ព ដើម្បីកម្លាកម្លាំងចិត្តកងពលដែលអន់ថយឲ្យក្លាហាន ព្រះកជា ទាមកេមះដោយដេមន្ត្រីជាទីប្រឹក្សា ទីទំរៈយោធាច្រើនជាអង្គបញ្ញាការកងទ័ព ។

៧៥– ត្រូវយាត្រាទ័ពចូលទៅក្នុងដែនពហុស៊ ទីងកំព្រ

ព្រៃដោយកងពលដំរី ក្នុងវាលដោយកងទ័ពសេះ ក្នុងទឹក ដោយកងជើងទឹក ក្នុងទំនាំទួលដោយកងពលថ្មើរជើង ។

៧៦- ក្នុងផ្លូវវៀចវេរលោកសំដែងទុកថា ត្រូវក្បួនដំណើរ ដោយកងពលដំរី ផ្លូវស្រឡះត្រូវប្រើកងទ័ពសេះ ឯកងពលថ្មើរជើងប្រើបានគ្រប់ពេលទាំងពួង ។

៧៧- គម្ពីរប្រយុទ្ធសង្គ្រាមព្រះរាជាទុកក្នុងរទេះ ឬតាមផ្លូវ ដែលគេទៅបានដោយលំបាក សូម្បីព្រះអង្គមានយោធា ទៅហានទោមកេមរក្សាហើយក្តី ទ្រង់ក៏ត្រូវចូលទៅកាន់ យោធិនត្រូវទាបត្តិចាញ់ឈ្នះ ។

៧៨- ព្រះរាជាប្រថាប់នៅទីណា ត្រូវឃ្លាំងនៅទីនោះ មិនមានឃ្លាំងពាក់មានពល ព្រះរាជាទ្រង់ត្រូវប្រកបដោយ ព្រះទ័យទូលាយ ទ្រង់ត្រូវប្រទានរង្វាន់ដល់យោធាគ្រប់គ្នា តែសេចក្តីពិតយោធាណាមួយដែលមិនច្បាំងដើម្បី ព្រះរាជា ? ។

៧៩– មនុស្សមិនមែនជាទាសនៃមនុស្សទេ មនុស្សជាទាសនៃទ្រព្យ ការបានទៅជាបុគ្គលខ្ពង់ខ្ពស់ ឬការធ្លាក់ចុះទៅជាបុគ្គលថោកទាប ស្រេចហើយតែមានទ្រព្យ ឬក្រីក្រទ្រព្យតែប៉ុណ្ណោះ ។

៨០– ត្រូវចូលប្រយុទ្ធកុំឲ្យបែកទ័ព ហើយប្រយ័ត្នមើលគ្នីគ្នា កងទ័ពណាទន់ខ្សោយកម្លាំង ត្រូវប្រមូលមកទុកកងកណ្ដាលក្បួនទ័ព ។

៨១– គប្បីចូលទៅប្រយុទ្ធកងទ័ពពល ដោយកងទ័ពរថ និងទ័ពសេះ កងទ័ពទឹកដោយកងទ័ពទូកនិងដរ, កងទ័ពព្រៃ និងព្រៃញាតស្បាត់ដោយកងទ័ពជើង, កងទ័ពគោកដោយដំរី ដែលទឹងអាវុធផ្សេងៗ ៕

៨២– បណ្ដាកងទ័ពទាំងអស់ កងទ័ពដំរីជាកងទ័ពជាងឯក សម្រាប់ព្រះមហាបាល មិនមានកងទ័ពអ្វីប្រសើរជាងឡើយ ព្រោះដំរីសុទ្ធតែអវៈយវៈរ៉ប៉ុណ្ណោះ កំទុកថាជា

សាវុធ ៨ ប្រការបានស្រេចហើយ ។

៨៣– សេះជាកម្លាំងនៃកងទ័ព គេទុកជាកំពែងដើរបាន ព្រោះហេតុនេះ បើព្រះរាជាអង្គណាប្រកបដោយកងទ័ពសេះច្រើនក្រៃលែងជាងសត្រូវហើយ កំណោះជាមានជ័យក្នុងយុទ្ធសង្គ្រាម ។

៨៤– លោកពោលថា កងទ័ពដែលប្រសើរនោះ គឺកងទ័ពដែលមាននិស្ស័យក្លៀវក្លាពីកំណើត ប៉ិនប្រសប់ក្នុងការប្រើសាវុធមានគក្ត ធន់ទ្រាំក្នុងការទ្រាយកម្លាំង ហើយមានទាហានក្សត្រជាប្រមុខដោយច្រើនផង ។

៨៥– ព្រះរាជាប្រាថ្នាជ័យ ដោយមិនធ្វើកងទ័ពព្រះអង្គឲ្យលំបាកក្តៅក្រហាយ កងទ័ពដែលរួយស្រពន់ដោយដើរផ្លូវឆ្ងាយ សត្រូវយកជ័យបានដោយងាយ ។

៨៦– ពិណរក ទ្រនង់យង់យួន ជិលៈម្ជិមមានពាក្យសត្យ ត្រូសប្រហែស ខ្លាច មិនម៉ឺងម៉ាត់ ល្ងង់ខ្លៅ មើល

ងាយ ។ល។ តាំងអស់នេះជាលក្ខណៈសត្រូវដែលបរ

បក្សយកជ័យជំនះបានដោយងាយ ។

៨៧– នឿយហត់ដោយដើរផ្លូវឆ្ងាយ ចំមតាមដោយ

ស្ទឹងទន្លេ ភ្នំទីទៃព្រៃ គក់ស្លុតដោយអគ្គិភ័យសម្បើម រហោម

រហោមដោយឃ្លានបាយក្រហាយទឹក ។

៨៨– ធ្វេសប្រហែស ខ្វះស្បៀងអាហារ មានពក្រាដ៏

ទឹងទុំកិត្យ បៀតបៀន គ្រប់គ្រងកងពាហនមិនល្អមិនបាន

អស់ពេលច្រើន ប្រឡូកប្រឡល់លំបាកដោយភ្លៀងទឹកខ្យល់ ។

៨៩– បំបាំងដោយកក់ទឹងទឹក រសាត់រសាយខ្ចាត់

ខ្ចាយខ្ទះបៀតដោយសត្រូវ សែនក្ររកនៃតែមានប្រការ

ដូច្នេះ សត្រូវអាចពិឃាដបានដោយងាយ ។

៩០– ការបរាជ័យចូលប្រយុទ្ធ ព្រះរាជាគប្បីចត់ព្រះ

នេត្រគ្រួតត្រាមើល ហើយពោលពាក្យលើកទឹកចិត្តយោធា

ឲ្យក្លាហានឲ្យចូលតស៊ូជាញសត្រូវ សូម្បីសុនខកាលបើ

ម្ចាស់ឈ្មោះពេស្យានាំផិតហើយនឹងសំដែងខ្លួនដូចជាសីហា ពិតប្រាកដមិនមែន ឬអ្វី ? ។

៩១-ម្ចាស់ផែនដី, អាមាត្យ, អាណាចក្រ, បន្ទាយ, ឃ្លាំង, សេនានុភាព, សម្ពន្ធមិត្រ, ពលរដ្ឋ, សន្តិមប្រជាករ, ទាំងអស់នេះជាអង្គនៃរាជ្យក្រឹត្យប្រទេសជាតិ ។

៩២- គប្បីបំផុតបំផ្លាញ សម្លាប់សត្រូវ ញាំញីសត្រូវឲ្យខ្ចាយ ដោយការបំផ្លាញកុំឲ្យមានបន្ទាយ មានភូមិ មានគ្រឿងជំរុំ កាលចូលទៅបរទេសហើយ ត្រូវបញ្ជូនអ្នកបើព្រៃទៅជាមុន ។

៩៣-ទ្រង់ត្រូវបំផុតបំផ្លាញរឿយៗ នូវកលស្បៀងស្រូវ អង្ករសត្រូវ ហើយត្រូវបង្អត់កុំឲ្យមានទឹកមានអុសត្រូវទំលាយទំនប់ទឹកក៏តែងទឹកមន្ទីរ ។

៩៤ - ព្រះមហាបាលត្រូវដាក់កងពលថ្មើរជើង ទៅនៅមុខទ័ពកាលបើបង្ក្រាបសត្រូវបានហើយ ព្រះអង្គត្រូវប្រជាប់

នៅកំពប់អិកដ៏សត្រូវឲ្យរាបទាប ។

៩៥– គន្លឹះបរមគិច្ច នៃយុទ្ធសង្គ្រាម ការអភិបាលពល និងការទុកឲ្យសព្វគ្រប់ គេទុកជាគោលដ៏សំខាន់ព្រោះការក្រោប សត្រូវកងវិសវាតែក្នុងជាជីវិតនៃកងពល ។

៩៦– កិច្ចដ៏សំខាន់បំផុត ត្រូវចងស្ពានមេត្រីនឹងស្ដេច យុវរាជ ឬនាយករដ្ឋមន្ត្រីរបស់ប្រទេសសត្រូវបានហើយ គប្បី បំបែកសាមគ្គីខាងក្នុងក្រុមសត្រូវដែលមានចិត្តមិនមាំ ។

៩៧– លុះដល់ទៅបាយសង្គ្រាមយ៉ាងនេះបានហើយ គប្បី សម្លាប់មិត្រជំហៅការនៃសត្រូវនោះចោលចេញ កុំនោះចាប់ បង្ហាញមុខមន្ត្រី ឬ គូនចៅបះការឃុំឃាំងទុក ធ្វើដូចជាបំបែក គូនគោះហើយចាប់មគោដូរចោះ ។

៩៨– កុំនោះសោតចូលដៃនឹងមន្ត្រី កដបភោក គូនចៅ សត្រូវឬព្រះវង្សាយាទរបស់ប្រទេសសត្រូវ ដោយឲ្យទ្រព្យ សម្បត្តិមាស-ប្រាក់ ស្ត្រីក្រមុំមានរូបល្អ ដូចជាបញ្ញាញស្ដុះ

បង្កាគេគារហើយចាប់ផ្ដោះ ។

៩៩– ញុះញង់បំបែកឲ្យកើតក្ស័ត ១ ខ្សោយពន្ធុកឲ្យ បានយុរ១ ចូលលុកទោមកាយ ១ ក្លាហានក្រៃលែង ១ ពាំង ៤ នេះលោកពោលថាជាមធ្យោបាយ សម្រាប់កាយបន្ទាយឲ្យ បែក ។

១០០– ការកាន់យកពាក្យបញ្ញាម៉ត់ចត់ ១ សំដែងទឹក ចិត្តក្លាហានមុះមុត ១ គយុទ្ធបញ្ចាំងម៉ឺងម៉ាត់ ១ ជយចំពោះឲ្យ រៀបរយល្អ ១ បើកាលយ៉ាងនេះមកដល់ហើយបុគ្គលគប្បី ធ្វើភាព តាមការដែលអាចធ្វើបាន. កុំរង់ចាំឡើយ ។

១០១– ការមិនជ្រះថ្លា ១ ការបាក់មុខញយ ១ ការ មិនឲ្យចំណែកដល់បុគ្គលម្នាក់ៗដែលត្រូវបានចំណែក១ ការ ពន្យារពេលវេលាចែក១ ការមិនធ្វើតបច១ ចំណុចអស់នេះជា ហេតុនាំឲ្យព្រាងើយកន្តើយពីគ្នា ។

១០២– ព្រះកថា គប្បីធ្វើឲ្យប្រទេសព្រះអង្គ មានពល

រដ្ឋច្រើនបរិបូណ៌   ដោយការកៀរយកប្រជាជនពីបរទេសម្តុំ នោះទំនុកបំរុងប្រជាជនដោយការឲ្យភានទទឹងកប់ការ ប្រទេសណាមានពលរដ្ឋច្រើនប្រទេសនោះឈ្មោះថា មានកម្លាំងច្រើនក្នុងយុទ្ធសង្គ្រាម ។

១០៣- ក្នុងកាលណាជនណាចេះចាយទ្រព្យសម្បត្តិឲ្យជនដទៃស្មើភាគគ្នា មានចារបុរសចេះលាក់លៀមការសម្ងាត់ទុកដោយល្អ មានការប្រើក្ញុយ៉ាងស្ងាត់ មិនពោលពាក្យអសុរោះចំពោះសព្វមនុស្សរាល់ឡាយ ក្នុងកាលនោះជននោះអាចគ្រប់គ្រងប្រឹថពីដែលមានសាគរជាខបខណ្ឌបាន ។

១០៤- វីរះយោធា ដែលមានគ្រឿងការពារទុកល្អរក្សាការសម្ងាត់ទុកដោយប្រពៃ យាត្រាទ័ពដំណាសំណាន់ភានតាប់ហើយមានរបៀប ចូលទៅផុតកំដៅសត្រូវណាដែលមានកម្លាំងស្មើភាគគ្នាឲ្យខាន សត្រូវដែលក្តៅក្រហាយខាននោះ ទឹងចូលមកធ្វើសន្តិភាព ព្រោះហេតុតែសេចក្តីខាន

នោះឯង ។

១០៥- ការផ្សះផ្សារ១ ការចែករំលែក១ ការញុះញង់បំបែក១ ការផ្តន្ទាទោស១ តាំង៤ប្រការនេះជាឧបាយយកឈ្នះ ។

១០៦- ឧបាយដើម្បីចាប់ផ្តើមធ្វើការ១ រកពលនិងទ្រព្យសម្បត្តិ១ ការលៃលកនៅដើម្បីកាលៈទេសៈ១ ឧបាយការពារមិនឲ្យចាញ់១ តាំង៤ប្រការនេះជាអង្គនៃការប្រឹក្សា ។

១០៧- អានុភាពនៃឧស្សាហៈ១ អានុភាពនៃការប្រឹក្សា១ អានុភាពនៃព្រះរាជា១ តាំង៣ប្រការនេះហៅថា «អានុភាព» (អានុភាពគឺ សក្តិក្នុងចម្បាំងមាន៣ប្រការ គឺ ឧស្សាហសក្តិ១ មន្ត្រីសក្តិ២ ប្រភុសក្តិ៣ ។

១០៨- សូមព្រះរាជាតាំងឡាយ កុំបានជួបប្រទះសឹកសង្គ្រាមដែលប្រកបដោយពលដ៏រ, តែៈ សត្រូវចំណាន១ នឹងយោធាទាំងឡាយជួបប្រះឡើយ សូមឲ្យអរិទ្ធកផ្តួកបច្ចា

មិត្រពាក់បង្ខូចបង្ខាចព្រះបារមី ដោយគ្រាន់តែរៀលគីព្រះកជ នយោបាយហើយរត់ខ្វាត់ខ្វាយទៅពួនលាក់ខ្លួននៅនាព្រៃភ្នំក្រ ថ្ងៃរាសគ្រប់កាលវេលាទៅហោង ។

ចប់

# សន្តិភាពវគ្គ

១– អ្នកប្រាជ្ញ កាលបើនឹកឃើញដល់សេចក្តីចំរើនហើយ ត្រូវនឹកដល់សេចក្តីវិនាសផង ការធ្វេសប្រហែសសប្បាយភ្លេចគិតដល់សេចក្តីវិនាសផងទេ, សេចក្តីចំរើនដែលខ្លួនបានហើយ តែងធ្លាក់ស្រឹមចុះទៅហិនភាពអនាគតយ៉ាងឆាប់ ៗ

២– ជនណាមួយត្រេកអរមុន ចំពោះប្រយោជន៍ដែលមិនទាន់មកដល់តាមគំនិតដែលខ្លួនគិតទុក ជននោះនឹងទទួលសេចក្តីទុក្ខ ក្តៅក្រហាយ ស្តាយក្រោយក្នុងអនាគតមិនខាន ៗ

៣– បុគ្គលគប្បីប្រាថ្នាធ្វើសន្តិភាព ចំពោះសត្រូវដែលមានកម្លាំងស្មើគ្នា ការយកជ័យជំនះក្នុងសង្គ្រាមតែងមិនទៀងទាត់ទេ ៗ

៤– នរណាហ៊ានទះឈ្មោះជាលួង បើយកខ្លួន, មិត្រសម្លាញ់ រេហ៍ពល, កដ្ឋរបស់ខ្លួន, ទីដែលគេហៅឈ្មោះទៅព្រោះពោលនៅក្នុងផ្ទាំងប៉ះបើក គឺសេចក្ដីសង្ស័យមិនច្បាស់ក្នុងចិត្តក្នុងសង្គ្រាម ? ។

៥– យុទ្ធសង្គ្រាម ដូចកាលក៏ខ្លួចភាគតាំងសង្វាងក៏បាន, ដូចបាញ់ដុំឈ្មោះទៅវិញទៅមកក៏បាន ដូចជាកន្ត្រេះដូនកាំត្រាច់ចុះក្រោម កាំជ្រួចឡើងលើផ្លាស់ប្ដូរវេនគ្នាដូច្នោះ ។

៦– បុគ្គលមានពាក្យសច្ចៈ ១ បុគ្គលមានការព្យជាតិ ១ បុគ្គលប្រព្រឹត្តធម៌ ១ បុគ្គលអនារិយជាតិ ១ បុគ្គលមានបងប្អូនច្រើន ១ បុគ្គលមានកម្លាំង ១ បុគ្គលធ្លាប់មានជ័យក្នុងយុទ្ធសង្គ្រាមច្រើនដង ១ ទាំង ៧ ប្រភេទនេះ លោកពោលជាត្រូវធ្វើសន្តិភាព ។

៧– បុគ្គលមានសច្ចៈ តែងរក្សាសច្ចៈទៀងទាត់, នរណាធ្វើសន្តិភាព មួយអន្លើដោយបុគ្គលមានពាក្យសច្ចៈ

សន្តិភាពមែនមិនប្រែប្រួលទេ, បុគ្គលជាអារ្យជាតិសូម្បីខូចខាតដល់ជីវិតក៏មិនព្រមលះបង់កិត្តិយស មិនព្រមដើរទៅតាមវិធីដែលជាអនារ្យជាតិឡើយ ។

៨- មែនពិត, ជនដែលបានរៀនឈ្មោះថា ជាអ្នកទ្រទ្រង់ធម៌ហើយ កាលបើត្រូវគ្រោះអន្តរាយ នរណាៗក៏ទៅជួយថែរក្សាដែរ, អាស្រ័យដោយការពប់អាននៃប្រជាជនចូលទៅដឹងគុណធម៌នៃខ្លួន អ្នកទ្រទ្រង់ធម៌ដែលជាទីពប់អាននៃជនដទៃ បុគ្គលណាមួយទៅធ្វើអន្តរាយមិនបានដោយងាយទេ ។

៩- កាលបើសេចក្តីវិនាស ចូលមកដល់ជាតិហើយ សូម្បីអនារ្យជន យើងក៏គួរធ្វើសន្តិភាពដែរ ព្រោះថា បើវៀរមិនអាស្រ័យអនារ្យជននោះហើយ យើងមិនអាចធ្វើឲ្យយើងរស់នៅទៀតបានឡើយ ។

១០- ឫស្សីដុះជាគុម្ពក្រាស់ ជិតប្រកិតគ្នាតាមកោម

ព័ទ្ធដោយដៃឬស្សី មានបន្លាស្កេកស្កះ បុគ្គលមិនអាចចូលទៅកាប់កាត់ឬស្សីនោះបានដោយងាយទេ យ៉ាងណា បុគ្គលដែលមានបងប្អូនច្រើនក៏យ៉ាងនោះដែរ ។

១៧– ពាក្យដែលនិយាយថា «ត្រូវច្បាំងតស៊ូនឹងអ្នកមានកម្លាំង» ដូច្នេះ មិនមានឧទាហរណ៍ណាជានិទស្សនៈទេ ក្នុងកាលណាក៏ដោយ ដុំពកមិនរសាត់កាន់ទីច្រាសខ្យល់ឡើយ ។

១៨– ជនគ្រប់គ្នា ទីឋាន គ្រប់កន្លែង គ្រប់កាលវេលា បុគ្គលរមែងចុះយ៉មព្រមតាញ់អានុភាព នៃវីរៈបុរសដែលធ្លាប់មានជ័យច្រើនជនណាស់មកហើយ ។

១៩– អ្នកធ្លាប់មានជ័យក្នុងយុទ្ធសង្គ្រាម ច្រើនដង ហើយទៅធ្វើសន្តិភាពជាមួយនឹងព្រះរាជាអង្គណា សត្រូវនឹងព្រះរាជាអង្គនោះ នឹងលុះក្នុងអំណាចនៃព្រះអង្គភ្លាម ដោយអានុភាពនៃការចងស្ពានមេត្រីសន្តិភាពនោះ ។

១៤– បុគ្គលដែលយើងមិនគប្បីធ្វើសន្ថិភាពជាមួយ នោះមាន២០ពួកគឺ ១.ក្មេង, ២.មនុស្សចាស់, ៣.មនុស្សឈឺរ៉ៃ, ៤.មនុស្សដែលញាតិបណ្ដេញៈចោលបង់, ៥.នាយខ្មះច, ៦.បរិវារខ្មាច, ៧.នាយលោក, ៨.បរិវារលោក;

១៥– ៩.មនុស្សដែលមានប្រក្រតីព្រាងើយកន្ទើយ, ១០.មនុស្សដែលមានចិត្តជាប់ក្នុងកាមគុណ, ១១.មនុស្សមានចិត្តផ្លាស់ប្ដូរច្រើន (ចិត្តមិនទៀងទាត់), ១២.មនុស្សទិទ្ទាទៅគាទីងសមណៈព្រាហ្មណ៍;

១៦– ១៣.មនុស្សមានព្រេងសំណាងអាក្រក់, ១៤.មនុស្សជឿព្រេងសំណាង, ១៥.មនុស្សត្រូវអន្តរាយដោយទុរ្ភិក្ស, ១៦.មនុស្សមានចិត្តសាហាវសាយក្ដុងក្តីអន្តរាយហើពល;

១៧– ១៧.មនុស្សមិនរនៅប្រទេសខ្លួន,- ១៨-

មនុស្សមានសត្រូវច្រើន, ១៩. មនុស្សមិនប្រកបដោយវេលា, ២០. មនុស្សមិនកាន់សច្ចៈនិងធម៌, មនុស្សដែលមិនត្រូវធ្វើសន្ធិភាពមាន ២០ ពួកដូចបានពោលមកនេះ ។

១៨- បុគ្គល ២០ ពួកនេះ មិនត្រូវធ្វើសន្ធិភាពជាមួយឡើយ មានតែធ្វើសង្គ្រាមតបវិញតែប៉ុណ្ណោះ ព្រោះថាបុគ្គល ២០ ពួកនេះ កាលបើបានធ្វើសង្គ្រាមហើយ មុខជាធ្លាក់ទៅក្នុងអំណាចសត្រូវពិតប្រាកដហើយឆាប់រហ័សផង ។

១៩- ធម្មតាលោកតែងមិនពេញចិត្តធ្វើសង្គ្រាមមួយនឹងអ្វើ ដោយកូនក្មេង ព្រោះកូនក្មេងមិនមានអំណាច, ម្យ៉ាងទៀតកូនក្មេងមិនយល់ផលនៃការច្បាំង ទើបការមិនច្បាំងទេ ។

២០- មនុស្សចាស់នឹងមនុស្សឈឺរើរ៉ៃ មិនមានសូហៈនិងអង់អាចទេ ជនពីរពួកនេះ សូម្បីតែបងប្អូនឯងក៏មើលឃើញឥតសំខាន់ឡើយ ។

២១- មនុស្ស ដែលត្រូវញាតិទាំងពួងបណ្ដេញចោល

បង់គេអាចចំលាយបានដោយងាយ  ព្រោះញាតិតាំងឡាយ ដែលមានគ្រោះដល់ខ្លួន  នឹងសម្លាប់ជនពួកនេះតាលបង់មិន ទាន ។

២២– នាយខ្លាច  តែពោលសង្គ្រាម  នឹងដល់នូវ សេចក្តីវិនាសដោយខ្លួនឯង  បរាជ័ខ្លាចក៏តែពោលម្ចាស់ខ្លាច សង្គ្រាមដូច្នោះដែរ ។

២៣– នាយល្បោក  តែងមានបរាជ័មិនសូវចង់ច្បាំង ព្រោះបរាជ័មិនសូវបានចំណែក  ឯបរាជ័ល្បោកដែលមិនបាន ទាន់នឹងសម្លាប់នាយល្បោកបង់ ។

២៤– មនុស្សដែលមានប្រក្រតីព្រងើយកន្តើយ  លះបង់ ពោលគ្នាក្នុងសង្គ្រាម  ឯមនុស្សដែលជាប់ជំពាក់ក្នុងកាមគុណ គេតែងយកឈ្នះបានដោយងាយ ។

២៥– មនុស្សមានចិត្តផ្លាស់ប្តូរច្រើន តែងជាទីបែកចិត្តនៃ ជនអ្នកជួយប្រឹក្សា (មន្ត្រី) ដល់មានការកើតឡើង  មនុស្ស

មានចិត្តផ្លាស់ប្ដូរនោះ តែងព្រងើយកន្តើយព្រោះមានចិត្តមិនទៀងទាត់ ។

២៦ មនុស្សខ្ជិលទៅគាល់សមណៈព្រាហ្មណ៍ នឹងសាបសូន្យទៅឯងៗ ព្រោះអំណាចព្រះធម៌ដ៏ទូលាយណាស់, ឯមនុស្សមានព្រេងសំណាងអាក្រក់ក៏វិនាសដូចគ្នា ។

២៧– មែនពិត, ការជឿព្រេងសំណាង ជាហេតុនៃសម្បត្តិ (សេចក្ដីចំរើន) ផង ជាវិបត្តិ (សេចក្ដីវិនាស) ផង កាលបើដូច្នេះមនុស្សជឿព្រេងសំណាង នឹងមិនតាំងចិត្តព្យាយាមធ្វើអ្វីដោយខ្លួនឯង ។

២៨– មនុស្សដែលត្រូវអន្តរាយដោយទុក្ខ នឹងលេចស្រឹមទៅខ្លួនឯង, រីទោយមានសេចក្ដីសោកសោយគន្ធក្ដី អន្តរាយហើយពេល ក៏មិនអាចនឹងគេចចូលបញ្ចៀសទៀតបានទេ ។

២៩– មនុស្សដែលមិននៅប្រទេសខ្លួន សូម្បីតែកូនសត្រូវតូចមួយក៏អាចសម្លាប់បាន ដូចក្រពើសូម្បីតូចតាចបើ

នៅក្នុងទឹក ហើយអាចចាប់នូវដំរីសារធំក៏បាន ។

៣០- មនុស្សមានសត្រូវហើយ តែងរន្ធត់តក់ស្លុតដូចព្រាបនៅកណ្តាលហ្វូងខ្លែង បើទុកជាដើរទៅណាទៅណាក៏ដោយ មិនយូរប៉ុន្មាននឹងដល់ក្តីស្លាប់មិនខាន ។

៣១- មនុស្សដែលមានសេនានុភាពមិនប្រកបដោយវេលា នឹងត្រូវយោធាដែលប្រកបដោយកាលវេលាក៏វាយខ្ចាត់ខ្ចាយបាន ដូចក្អែកនៅក្នុងពេលរាត្រីឥតពន្លឺត្រូវទីទុយសម្លាប់បាន ។

៣២- ក្នុងកាលណាក៏ដោយ បុគ្គលមិនគប្បីធ្វើសន្ធិភាពដោយបុគ្គលមិនកាន់ពាក្យសច្ចៈនឹងគេឡើយ ព្រោះថា កាលបើធ្វើសន្ធិភាពជាមួយនឹងជនបែបនេះហើយ មិនយូរប៉ុន្មានគង់នឹងដល់នូវការប្រែប្រួល ដោយហេតុតែមិនមែនជាសប្បុរសនោះឯង ។

៣៣- សន្ធិភាពស្ងប់សឹកដែលបុគ្គលគប្បីធ្វើមាន១៦

ប្រការគឺ៖ កបាលៈ១ ឧបហារៈ១ សន្តានៈ១ សំគត១ ឧបន្យាសៈ១ ប្រតីការៈ១ សំយោគៈ១ បរសន្តារៈ១ ។

៣៤– អនុស្សវៈ១ អចិន្តៈ១ អាត្មាចិន្តៈ១ ឧបគ្រហៈ១ បរិក្រយៈ១ ឧច្ឆិន្នៈ១ បរក្ខសណៈ១ ។

៣៥– ស្តនោបទេយៈ១ សន្និកាតទាំង១៦ប្រការនេះ បណ្ឌិតអ្នកជំនាញក្នុងសន្និសញ្ញាស្ទប់សឹកបានពោលហើយ ៗ

៣៦– ១ ដែលហៅថាកបាលសន្និសញ្ញា បុគ្គលគប្បីដឹងថា ប៉ុសឹកដោយមានលទ្ធិកៈ ស្មើគ្នាទាំងសងខាង; ២សន្និសញ្ញាណា ដែលកើតដោយការឲ្យសន្និសញ្ញានោះហៅថាឧបហារៈ ។

៣៧– ៣ដែលហៅថាសន្តានសញ្ញា បុគ្គលគប្បីដឹងថាជាសញ្ញាមានការចៀជិតជាកាយាទុកខាងដើម; ៤ការបេនស្ពានមេត្រីមួយអន្ទើរបាយសប្បុរសទុកជាខាងដើម លោកឲ្យឈ្មោះថាសំគតសន្និសញ្ញា ៗ

៣៨– សិក្ខសន្ធិសញ្ញានេះ មានគុណលក្ខណៈដូចជាសុវណ្ណ ព្រោះវាតែងផ្តល់នូវសប្បុរស ជូនកាលលោកដែលទៀវភ្ជាប់ក្នុងសន្ធិសញ្ញាឲ្យឈ្មោះថា កាញ្ចនសន្ធិសញ្ញា ។

៣៩– សិក្ខសន្ធិសញ្ញានេះ មានចរិយាដកបដល់អស់កាយ មានការប្រយោជន៍ស្មើៗគ្នា ក្នុងគ្រាចំរើនក្តី ក្នុងគ្រាវិបត្តិក្តី ក្នុងហេតុការណ៍ណាមួយក្តី មិនដាច់ស្ពានមេត្រីនឹងគ្នាទេ ។

៤០– ៥.សន្ធិសញ្ញាណា ដែលបុគ្គលទទួលខ្លួនឬព្រមឲ្យខ្លួន គិតឲ្យតែខាងបានសម្រេចសន្ធិសញ្ញានោះ លោកអ្នកទៀតទុកក្នុងសន្ធិសញ្ញាឲ្យឈ្មោះថាឧបន្យាសៈ ។

៤១– ៦.សន្ធិសញ្ញាណា ដែលធ្វើដូច្នេះ គឺកាលដើមយើងធ្វើឧបការៈគុណដល់គេ គេត្រូវធ្វើឧបការៈគុណតបវិញ សន្ធិសញ្ញានោះលោកឲ្យជាប្រតិការៈ គឺការតបស្នង ។

៤២– "ក៏នោះយើងត្រូវជួយគេ គេក៏ត្រូវជួយយើង

វិញ» ដូច្នេះក៏ឈ្មោះថាប្រតិការៈដែរ ។

៤៣- ៧.សន្និសញ្ញា ដែលអ្នកតាំងសនិទានទុនបំណងដោយប្រពៃ ដើម្បីប្រយោជន៍តែមួយដូចគ្នា ហើយធ្វើសន្និសញ្ញានោះលោកឲ្យឈ្មោះ សំយោគសន្និសញ្ញា (ការប្រជុំ) ព្រោះជាការប្រជុំជាប្រមាណ ។

៤៤- ៨- ត្រូវទុកឲ្យសេនាប្រមុខនៃយោធាទាំងឡាយ តាំងសនិទានធ្វើការស្ងប់សឹក សម្រេចដើម្បីប្រយោជន៍ដល់ យើងទាំងឡាយ សេចក្តីព្រមព្រៀងយ៉ាងនេះហើយធ្វើនៅក្នុង សន្និសញ្ញាណា លោកហៅសន្និសញ្ញានោះថា បុរសាន្តរៈ ។

៤៥- ៩. «មានតែអ្នកមួយទេ ដែលអាចធ្វើសេចក្តីប្រាថ្នារបស់ខ្ញុំឲ្យសម្រេចបាន» សត្រូវដែលចូលមកសុំធ្វើការស្ងប់សឹកយ៉ាងនេះ ក្នុងសន្និសញ្ញាណា សន្និសញ្ញានោះលោកហៅថាអទិស្តបុរស ។

៤៦- ១០. សត្រូវព្រមធ្វើស្ងប់សឹក ដោយការបែងចែក

ដីមួយចំណែកទៀត សន្ធិសញ្ញាបែបនេះ លោកជាអ្នកធ្វៀត ទាត់ពីសន្ធិសញ្ញាឲ្យឈ្មោះថាអាទិស្ត (ការបែងចែកឲ្យ) ។

៤៧-១១- សន្ធិសញ្ញាណា ដែលសម្រេចដោយសេទក្នុភាពរបស់ខ្លួន លោកហៅថាអាត្មាទិស្ត (ការឲ្យខ្លួនឯង); ១២. សន្ធិសញ្ញាដែលធ្វើដើម្បីរក្សាជីវិតខ្លួន ហើយព្រមប្រគល់សម្បត្តិឲ្យដល់សត្រូវលោកហៅថា ឧបគ្រហ: (ការសូមលា) ។

៤៨-១៣- សន្ធិសញ្ញាណា ដែលព្រមបែងសម្បត្តិក្នុងឃ្លាំងមួយចំណែក ឬពាក់កណ្ដាលពុំនោះឲ្យទាំងអស់ដល់សត្រូវដើម្បីរក្សាទ្រព្យដែលនៅសល់ខ្លះ សន្ធិសញ្ញានោះលោកឲ្យឈ្មោះថា បរិក្រយ: ។

៤៩-១៤- សន្ធិសញ្ញាណា ដែលព្រមលើកភូមិប្រទេសដែលឧត្តមទីបំផុតឲ្យសត្រូវ លោកឲ្យឈ្មោះថាឧច្ឆិន្ន: (ការតាំសំលើន); ១៥- សន្ធិសញ្ញាដែលព្រមលះបង់ផល

ព្រះធរណីដែលកើតក្នុងប្រទេសខ្លួនឲ្យសត្រូវ លោកហៅថា ប្រកូសណៈ (ប្រដាប់ដនដៃ) ។

៥០– ១៦. អ្នកប្រាជ្ញទៀតតាំងក្នុងសន្ធិសញ្ញាពោលថា «ការព្រមបែងចែកផលខ្វះក្នុងចំណែក ដែលខ្លួនបេះបានហើយលើយកមក» សន្ធិសញ្ញានេះឲ្យឈ្មោះថា ស្កន្ទាបនេយៈ ។

៥១– សន្ធិសញ្ញា៤ប្រការទៀត ដែលបុគ្គលគួរដឹងគឺ បរស្សោបការ (ការធ្វើឧបការៈទៅវិញទៅមក)១, មេត្រី (ការចងស្ពានមេត្រី)១, សម្ពន្ធៈ (ការពាក់ព័ន្ធគ្នា)១, ឧបហារៈ (ជំនួយ)១ ។

៥២– មានតែឧបហារៈសញ្ញាមួយប៉ុណ្ណោះទេ ដែលខ្ញុំយល់ថាគួរ កាលបើលើកយកឧបហារៈចេញហើយ មេត្រីភាពក៏មិនមាន ។

៥៣– បុគ្គលមិនត្រូវធ្វើការអ្នកក្តាំង ដូចជាគ្រោម

ក្រេងក្រោ ដូចមយក្ខបរទេះកាលទេ អ្នកមានបុណ្យធំមិន ត្រូវប្រកាសជ័យជំនះ ឬ បរាជ័យនៃសត្រូវទេ ។

៥៤– ព្រះរាជាជាធំ មិនត្រូវធ្វើសង្គ្រាមក្នុងកាលតែ មួយចំពោះសត្រូវច្រើននាក់ទេ ដូចពស់សូម្បីមានពិសក្លៀវ ក្លា ត្រូវហ្វូងកណ្ដូបបំផ្លាញសម្លាប់បានដោយពិត ។

៥៥– ជនពាលល្ងង់ មិនដឹងច្បាស់ខ្លាំងសេចក្ដីពិតនៃប្រ យោជន៍ យកតែតាមអំណាចនៃសេចក្ដីក្រោធ ជនទាំងនោះនឹង ត្រូវក្ដៅក្រហាយស្ដាយក្រោយមិនខាន ។

៥៦– មនុស្សប្រមឹកស្រា មនុស្សឆ្កួត មនុស្សពាច កក្រោល មនុស្សអស់កម្លាំង មនុស្សអត់ឃ្លាន មនុស្សល្មោភ មនុស្សខ្លាច មនុស្សហត់ស្អែក និងមនុស្សបរិភោគកាម មនុស្សទាំងអស់នេះមិនចេះធម៌ទេ ។

៥៧– បុគ្គលគួរធ្វើនូវការចងស្ពានមេត្រីមួយអន្ទើដោយ សត្រូវដែលធ្វើឧបការៈ, តែកុំធ្វើមួយអន្ទើដោយមិត្រដែលធ្វើ

អបការៈ (ទោស) ហើយ, ឧបការៈនិងអបការៈទាំងពីរប្រការនេះជាលក្ខណៈ ដែលបុគ្គលគប្បីកាន់ជាប់ចំពោះសត្រូវនិងមិត្រទាំងឡាយ ។

៥៨– នរណាហ៊ាននឹងរៀបលោកទាំងមូលយល់ថា ជាសត្រូវដ៏ក្រៃលែងដោយឥតកោតញញើត? គាត់តែងតាំងផនលោកធាបកងដំណែងរបស់នោះ ទុកដូចជាគំនូសដែលគេគូសលើដីខ្សាច់ ។

៥៩– ក្នុងកាលណាក៏ដោយ គេមិនដែលតាំងមនុស្សលោកធាបឡើងកាន់ដំណែងរបស់ទេ មនុស្សលោកធាបការបើបានដំណែងខ្ពង់ខ្ពស់ តែងតែប្រាថ្នាកំចាត់បង់នាយខ្លួនដោយពិត ។

៦០– គុណសម្បត្តិ និងសេចក្ដីប្រព្រឹត្តនៃជនដែលគេមើលមិនឃើញបុគ្គលគិញ្ចូតាបទៅតាមទំពើនៃជននោះ ដែលបានជ្រើសពួកពលទាំងពួង, មែនពិតហើយ សេចក្ដីប្រព្រឹត្ត

នៃជនៈគេមើលមិនឃើញនោះ គេអាចស្ទង់មើលឃើញនូវផល អំពើរបស់ជននោះបាន ។

៦១– មនុស្សល្ងង់គេធ្វើឲ្យពេញចិត្តបាន ដោយងាយ មនុស្សអ្នកចេះដឹងពិសេស គេធ្វើឲ្យពេញចិត្តដ៏រឹតតែងាយ ទៅទៀត តែឯបុគ្គលដែលចេះដឹងបន្តិចបន្តួច កុំថាឡើយ ត្រឹមមនុស្ស សូម្បីព្រះព្រហ្ម ក៏ធ្វើឲ្យពេញចិត្តមិនបានដែរ ។

៦២– បុគ្គលឥតគរុសិក្ខ មិនត្រូវធ្វើការប្រញាប់ ប្រញាល់ទេ ព្រោះការខ្វះខាតការពិចារណា ត្រឹមត្រូវជា ប្រភពនៃសេចក្ដីវិនាស ។

៦៣– អំពើដែលគេត្រូវទទួលទង់គេត្រូវឲ្យ បុគ្គលគប្បី ធ្វើឲ្យឆាប់ៗ បើបុគ្គលមិនធ្វើឲ្យឆាប់រហ័សទេ កាលវេលា នឹងលេបផ្លាក់ស៊ីរស់ជាតិនៃអំពើនោះអស់ ។

៦៤– កាម១ ក្រោធ១ មោហៈ១ លោភ១ បុស្សក១ មានៈ១ ស្រះធ៍១ ធម៌ទាំង ៧ ប្រការនេះបើលះបង់

បានទើបបានសេចក្ដីសុខ ។

៦៥– អ្នកបរិភោគកាម ១ ព្រះរាជា ១ គ្រូនេក្ខ័ ១ និងមនុស្សក្រ្កត ១ ទាំង ៤ ពួកនេះតែងចង់បាននូវវត្ថុណាដែល មិនគួរបង់បាន សូម្បីតែរបស់ភ្ជាប់ប៉ុន ភ្ជាប់ស្ពាល់គេដោយ ។

៦៦– បុគ្គលគួរលះបង់កាមឲ្យស្រឡះ ថាបើអត់ទ្រាំទប់ទល់កាមមិនបាន គួរសេពគប់ចំពោះតែភរិយាខ្លួនមួយប៉ុណ្ណោះហើយ ព្រោះថាភរិយាជាភេសជ្ជៈកែរោគ គឺកាមរោគបាន ។

៦៧– គួរលះបង់កិច្ចដែលជាប់ជំពាក់នេះចេញឲ្យស្រឡះពីខ្លួន ថាបើមិនអាចលះបង់បានទេ គួរសមាគមមួយអន្លើដោយសប្បុរសទាំងឡាយ ព្រោះជាសមាគមមួយអន្លើដោយសប្បុរសទាំងឡាយជាភេសជ្ជៈ កែរោគគឺសេចក្ដីទុក្ខបាន ។

៦៨– ភាពជាធំលើផ្ទៃផែនដី (ស្ដេច) នេះរលត់រលាយទៅក្នុងមួយខណៈៗ ប្រៀបដូចពពកដែលខ្យល់ផាត់, ការបរិ-ភោគកាមមានមធុរសតែមួយភ្លែត, ប្រាណគឺជីវិតនៃមនុស្ស

សត្វទាំងឡាយញាប់ញ័រយេង យ៉ាងដូចដំណក់ទឹកនៅលើចុង
ស្មៅ ឯព្រះធម៌វិញជាសម្មាញ់ក៏ក្រៃលែងព្រោះដឹកនាំសត្វទៅ
កាន់បរលោកខាយ ។

៦៩– កាលបុគ្គលពិចារណាឃើញច្បាប់ទូន្មានសាវជ្ជៈនេះថា ជាកំហែកប្រះធាធាប់ក្នុងមួយខណៈ ប្រៀបដូចជាស្រ ពោលកដីទឹក តប្បីគេសេពគប់មួយអន្ទើដោយសប្បុរសទាំងឡាយ ដើម្បីគេជម្រំផង ដើម្បីគេសេចក្តីសុខផង ។

៧០ ថាប៉េយកអស្សមេធៈមួយពាន់ដងនឹងសច្ចៈតែមួយ មកធ្វើងកាន់ត្រាជូ ហើយថ្លឹងមើល សច្ចៈតែ១នេះឯង មានទឹកចម្ងន់ធ្ងន់ជាងអស្សមេធៈទាំងពាន់ដោយពិត ។

៧១– អទិន្នាធម៌ ទុកដូចជាមាតា ឧបក្រោសាចចិញ្ចឹម អ្នកបដិសន្ធិទុកក្នុងទ្រូង តាំងតែពីប្រថមម្ល៉េះ ឯមាតាជាអ្នកបង្កើតនេះមាននៅក្នុងកាលជាខាងក្រោយទេ ។

៧២– ព្រះភិក្ខុមិត្តបាលទាំងឡាយ ប្រកបដោយរេហ៍ពល

នៃបទក្កុភាពយ៉ះនភៈពាន ទាំងឡាយច្រើនដល់ម្លេះ ស្បូវ នេះស្តេចទៅណាអស់ទៅហ្ន៎ ? ផែនប្រឋពីតហេតង់នៅ ហេតុមកដល់ថ្ងៃនេះ ជាសាក្សីនៃការត្រាស់ប្រាស់ព្រះកជាតាំង ឡាយនោះស្រាប់ ។

៧៣ - ប៉ុន្តែថ្ងៃនេះឬថ្ងៃស្អែក សត្វទាំងត្រូវវិនាសដោយ ក្តីទុក្ខនឹងជម្ងឺបៀតបៀន នរណាហ្ន៎ហ៊ានប្រព្រឹត្តធ្វើអំពើខុស តាមគន្លងធម៌ព្រោះតែក្រុកកង់កាយ ។

៧៤ - មែនពិត, ជីវិតសត្វទាំងឡាយយើងហ្មង់ណាស់ ដូចជាការញាប់ញ័រនៃស្រមោលព្រះចន្ទនៅក្នុងទឹក កាលបើ ដឹងថាជីវិតមានលក្ខណៈយ៉ាងនេះហើយ បុគ្គលគប្បីប្រព្រឹត្ត កល្យាណធម៌ជានិច្ច ។

៧៥ - ត្រូវប្រើត្រណាស់ ! កងកាយនេះកើតឡើង ហើយក៏ដល់នូវការបែកធ្លាយទៅវិញ គោតសម្បត្តិកើតឡើង បរិបូណ៌ហើយក៏ដល់នូវក្តីគោតវិបត្តិទៅវិញ, ការជួបជុំគ្នាកើត

មានរឿងហើយ ក៏ដល់នូវការព្រាត់ប្រាស់គ្នាទៅវិញ, សារពើភ្នំទាំងឡាយ មានការកើតរឿងនឹងការបាក់បែកពុកផុយរលួយទៅវិញយ៉ាងនេះជាធម្មតា ។

៧៦- កាយនេះ រលត់រលាយទៅគ្រប់ខណៈ កាលកំពុងរលាយទៅ បុគ្គលកំណត់មើលមិនឃើញទេ. ដូចគ្នានឹងផាំវិការនៃដីដែលគេដុតមិនល្អ (ឆៅ) បិតនៅលើទឹករលាយបន្តិចម្តងៗដល់បែកធ្លាក់ហើយទើបគេមើលឃើញច្បាស់ ។

៧៧- ម្រឹត្យូតែងដើរចូលទៅជិតរាល់ថ្ងៃ ឯសត្វក៏ដើរទៅរកសេចក្តីស្លាប់គ្រប់ជំហានដែរ ដូចជាសត្វគេនាំទៅកាន់ទីសត្តឃាត កាន់ជិតសេចក្តីស្លាប់រាល់ជំហានដើរ ។

៧៨- អនិច្ចធម៌ យោនៃវ័យ រូបជីវិត ការសន្សំកពូនទ្រព្យ សប្បាយយស ការនៅរួមរួមអន្ទើរជាមួយផងជាទីស្រឡាញ់ ទាំងអស់នេះបណ្ឌិតមិនរាប់ថាទៀងរហូតដល់កើតទុក្ខបានប្រកាន់ស្អិតយ៉ាងនេះទេ ។

៧៩ – សំណាកមួយទីណា សំគមួយទៀតមែនសោត ទៅជួបគ្នានៅក្នុងមហាសមុទ្រ លុះបានកពប្រសព្វជួបគ្នា ហើយក៏ឃ្លាតឃ្លាចាកប្រាសគ្នាទៅវិញ យ៉ាងណា ការជួបជុំនៅរួមគ្នានៃជនដែលកើតមកក្នុងលោកនេះ ក៏យ៉ាងនោះដែរ ។

៨០ – មែនពិត, អ្នកដំណើរតាំងឡាយ ចូលទៅឈប់សម្រាកកម្លាំងក្រោមម្លប់ដើមឈើ ហើយបិតនៅជួបជុំគ្នាហោង លុះឈប់សម្រាកកម្លាំងរួចហើយ ធ្វើដំណើរតទៅទៀត មានឧបមាយ៉ាងណា ការជួបជុំនៅរួមគ្នានៃជនដែលកើតមកក្នុងលោកនេះ ក៏យ៉ាងនោះដែរ ។

៨១ – ពងកាយបេងនេះ ធម្មជាតិនិម្មិតដោយហេតុ៤ យ៉ាង ហើយបែកធ្លាយត្រឡប់ទៅកាន់ធាតុទាំង៤ យ៉ាងវិញ ធាតុទាំង៤ នេះតែងចូលទៅកាន់កំណើតដើមវិញជាធម្មតា ។

៨២ – ការនៅជួបជុំគ្នាហេតុទីបំផុតនេះ មិនមានអ្នកណាមួយបាននេសាះ កុំថាឡើយដល់ញាតិសន្ដាន សូម្បីតែ

រូបកាយ ខ្លួនឯងក៏គាត់ណាមួយ ក៏ឥតមាននរណាមួយបាន ដែរចាំបាច់និយាយថ្វីដល់ញាតិសន្តានដែលនៅក្រៅពីកាយ ។

៨៣– ការស្វែងរកការជាប់លាប់នៅក្នុងជីវិតមនុស្សទើប ការស្វែងរកការជាប់លាប់ដើម្បីកក៏ឥតប្រយោជន៍ដូចគ្នា ដូច គេចង់ឲ្យក្រពេញទឹកចិត្តនៅយូរដូចខ្លោះដែរ ។

៨៤– ដរាបណា សត្វលោកណា ត្រូវបម្ពន្ធជាមួយ ញាតិសន្តានជាទីស្រឡាញ់ទុកក្នុងចិត្ត ដរាបនោះសត្វលោក នោះឈ្មោះថាកប់ទុកនូវបន្ទា គឺសេចក្តីសោកក្នុងចិត្តស្រេច ទៅហើយ ។

៨៥– មែនពិតការនៅជួបជុំគ្នា ឈ្មោះថាឲ្យកំណើត ផលការព្រាត់ប្រាសគ្នាវិញ ឯកំណើតក៏ឈ្មោះថាទាមកនូវ ប្រែត្យធម៌នេះមិនមានបុគ្គលណាមួយគេចរួចបាននះឡើយ ។

៨៦– ការលាប់ប្ញូសៅ នៃការជួបជុំជាទីរីករាយនេះ លឿនក្រៃពេកមួយអន្ទើជាយវនជាទីស្រឡាញ់ទាំងឡាយជា

ធមិតាៈណាក្រៃលែងណាស់ ដូចជាការបញ្ចុះអាហារស្អុងដ៏អាក្រក់ក្រៃលែងដូច្នោះដែរ ។

៨៧- ខ្សែចំណងនៃស្នេហ៍ទាំងឡាយ តែងព្យួរនៅៗហើយកាន់យកពួកណាត់ទៅជាមួយផង មិនដែលត្រឡប់ថយក្រោយវិញទេ គ្រប់ៗកាល មានឧបមាយ៉ាងណា យប់និងថ្ងៃក៏ចាប់ផ្តក់យកនូវអាយុនៃសត្វទាំងឡាយ ហើយទៅមិនត្រឡប់ថយក្រោយគ្រប់ៗកាល មានឧបមេយ្យយ៉ាងនោះដែរ ។

៨៨- ក្នុងសំសារវដ្តនេះ ការនៅជួបជុំមួយអន្ទើដោយជនជាទីស្រឡាញ់ណា ដែលមានសេចក្តីសុខនៅជាខាងដើមការនៅជួបជុំមួយអន្ទើ ដោយជនជាទីស្រឡាញ់នោះក៏ចងជាប់ជាមួយនឹងនឹមនៃសេចក្តីទុក្ខ ព្រោះការជួបជុំនោះមានការព្រាត់ប្រាសនៅក្នុងទីបំផុត ។

៨៩- ហេតុនេះឯង បានជាសប្បុរសទាំងឡាយមិនប្រាថ្នានូវការជួបជុំមួយអន្ទើ ដោយជនជាទីស្រឡាញ់ទាំង

ឡាយៈព្រោះមិនមានថ្នាំកែក្ខចិត្ត ដែលមុតដោយដាវគឺសេចក្ដីព្រាត់ប្រាសឲ្យសះស្បើយបានឡើយ ។

៩០– កាលបើគិតហើយគិតទៀត នូវអំណាចម្រឹត្យ ដែលមានអាជ្ញាដ៏អាក្រក់ក្រៃលែងនេះ សេចក្ដីប្រឹងប្រែងទាំងអស់នៃមនុស្ស សូម្បីជាអ្នកប្រាជ្ញក៏ថមថយចាញ់ដៃប្រៀបដូចជាវិទ្យានជាវែការៈនៃស្បែកដែលទទឹកដោយទឹកភ្លៀង ។

៩១– នរជនសូម្បីជាវីរៈបុរស ដែលចូលទៅចាប់បដិសន្ធិទៅកាន់គភ៌ក្នុងបឋមរាត្រីណា ចាប់តាំងពីបឋមរាត្រីនោះមក វីរៈបុរសនោះដើរត្រង់ឡើយចូលទៅកាន់ម្រឹត្យរាល់ៗថ្ងៃ ។

៩២– ជាបើសេចក្ដីព្រាត់ប្រាស ជាហេតុនៃសេចក្ដីសោក មិនមែនមោហៈជាហេតុទេ ហេតុអ្វីថ្ងៃដែលកន្លងទៅៗ សេចក្ដីសោកមិនចេះតែចំរើនឡើងរាល់ថ្ងៃទៅហ៎ះ? ។

៩៣– សេចក្ដីសោកដ៏ខ្លាំងណាស់ ទុកដូចជាសរដែលបាញ់មកមុតចំសាច់ឈឺជាងគេ ហើយជាធម្មជាតិត្រូវ

តែធ្លាក់ចុះមក មិនដាំបាចសព្វសត្វគ្រប់គ្នាដឹងខ្លួនមុនទេ ការប្រហារបំបាត់សេចក្ដីសោកនេះ មានតែការមិនគិតមួយទេ ដែលទុកជាមហោសថទិព្វជួយគេបាន ។

៩៤-- ជនណា មានភោជនគ្រាន់តែញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ មានមេថុនគ្រាន់តែបណ្ដុះពូជ មានវាចាគ្រាន់តែពោលពាក្យសត្យ ជននោះឈ្មោះជាកន្លងផុតនូវឧបសគ្គដ៏លំបាកបានហើយ ។

៩៥-- អាត្មា យើងនេះទុកជាស្ទឹង ដ៏មានការសង្រួមជាកំពង់បុណ្យ មានពាក្យសច្ចៈជាទឹក មានសីលជាត្រើយ មានករុណាជារលក, អ្នកចូលអភិសេកគឺចូលមុជក្នុងស្ទឹងគឺអត្តភាពនេះចុះ អន្តរាត្មាគឺចិត្តខាងក្នុងមិនមែនបរិសុទ្ធបានដោយទឹកទេ ។

៩៦-- សំសារវដ្ដនេះឥតខ្លឹមសារទេ កើតឡើងដោយឧបទ្រពចង្រៃ គឺទុក្ខវេទនាដែលកើតអំពីកំណើត ម្រិត្យុ

ផឹកទឹកត្រជាក់ ជនណាមួយលះបង់សារជាតិនេះបាន ហើយ
បានសេចក្ដីសុខ ។

៩៧- ក្នុងលោកនេះ មានតែសេចក្ដីទុក្ខមួយប៉ុណ្ណោះពិត មិនមានសេចក្ដីសុខទេ ដំណើរនេះបុគ្គលកំណត់ឃើញជាក់ច្បាស់ណាស់ ព្រោះថា ការបានជួយការពារបុគ្គលដែលមានសេចក្ដីទុក្ខឲ្យរួចស្រឡះហើយ ទើបគេសំគាល់ថា មានសេចក្ដីសុខបាន ។

៩៨- នរជនណា មិនប្រព្រឹត្តបៀតបៀនសព្វសត្វទាំងឡាយឲ្យក្ដៅក្រហាយ ព្យាយាមអត់ធន់ចំពោះការងារតាំងខ្លួន ឯងជាទីពឹងពំនាក់អាស្រ័យនៃសព្វសត្វទាំងឡាយ នរជននោះឈ្មោះថាកសាងស្ពានទៅកាន់ស្ថានសួគ៌ដោយពិត ។

៩៩- មានតែព្រះធម៌មួយទេ ហៅថា «មិត្តធម៌» ដែលជាប់ជិតតាមខ្លួនក្នុងពេលស្លាប់ ឯអ្វីៗដទៃទៀត សុទ្ធតែដល់នូវសេចក្ដីវិនាសអន្តរាយជាមួយនឹងសរីរៈកាយទាំងអស់ ។

១០០ – ធម៌ណាដែលមានឈ្មោះថា «អនិច្ចាធម៌គឺសភាពប្រែប្រួលមិនទៀងទាត់» ធម៌នោះមិនមែនជាធម៌សម្រាប់អ្នកស្រុក, សម្រាប់អ្នកនិគម ឬសម្រាប់ត្រកូលតែមួយៗទេ, សេចក្តីគឺ ធម៌នោះជាធម៌សម្រាប់មនុស្ស សត្វព្រមទាំងទេវតាមារព្រហ្មគ្រប់ៗរូប ។

១០១ – ធម៌ណាដែលមានឈ្មោះថា «ទុក្ខតាធម៌សភាពជាទុក្ខ» ទុក្ខតាធម៌នោះ មិនមែនជាធម៌សម្រាប់អ្នកស្រុក អ្នកនិគម ឬជាធម៌សម្រាប់ត្រកូលតែមួយៗទេ, ធម៌នោះគឺជាធម៌ តែងមានដល់មនុស្សនិងសត្វ ព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប ។

១០២ – ធម៌ដែលមិនមែនជារបស់ខ្លួន គឺអនត្តាធម៌ ព្រោះមានសភាពមិនស្ថិតស្ថេរ មិនទៀងទាត់ ឃាត់មិនបានដែលមានឯណា ធម៌នោះ មិនមែនមានសម្រាប់តែអ្នកស្រុក អ្នកនិគម ឬត្រកូលមួយៗទេ ពិតជាធម៌ សម្រាប់មានដល់

មនុស្សសត្វព្រមទាំងទេវតា មារព្រហ្មទាំងអស់គ្រប់រូប ។

១០៣– សង្ខារធម៌ទាំងឡាយមិនទៀងទាត់ មានការកើតឡើងហើយនឹងវិនាសទៅវិញជាធម្មតា គឺសុទ្ធតែកើតឡើងហើយរលត់ទៅវិញ កាលបើរលត់នូវសង្ខារទាំងឡាយនោះហើយ ទើបបានសេចក្តីសុខគ្រប់យ៉ាង ។

១០៤– មនុស្សទាំងសត្វទាំងឡាយ ទៀងតែនឹងស្លាប់គ្រប់ៗគ្នាមិនមាននរណាមួយចៀសវាងផុតទេ ហើយតែងតែនាំយកបុណ្យនឹងបាបដែលខ្លួនបានធ្វើទៅតាមផង អ្នកណាបានធ្វើបុណ្យតែងបានកើតក្នុងឋានសួគ៌ អ្នកណាធ្វើបាបតែងធ្លាក់ទៅសោយទុក្ខក្នុងនរក ដោយពិត -

១០៥– បុគ្គលគប្បីកប់នូវប្រយោជន៍ខ្លួនគឺការខំសន្សំកិច្ចជាបុណ្យដើម្បីជាសេចក្តីសុខ ទីងជាទីពឹងពំនាក់ទៅលោកខាងនាយ ព្រោះជាគុណគឺអ្នកប្រាជ្ញតែងកប់កានលើកដំកើង ។

១០៦– កាយនេះ មិនមានស្ថិតស្ថេរនៅបានយូរទេ

បើពេលណាវិញ្ញាណលះបង់ចោលហើយ គេតែងនាំយកទៅបោះបង់ចោលលើផែនដី អន់ថយជាងអង្កត់ៗសទៅទៀតជាវត្ថុក្រៀមសាគ្មាន ។

១០៧– ពេលណា ភ្លើងធាតុ អាយុ និងវិញ្ញាណរត់ចេញពីកាយនេះទៅកាន់ទីដើមវិញហើយ ពេលនោះហើយដែលគេត្រូវនាំយកកាយនេះទៅបោះចោលនៅក្នុងព្រៃ ។

១០៨– នាយគង្វាលគោ តែងគៀងគោទាំងឡាយ ដោយដំបងឬរំពាត់ទៅកាន់ទីមានទឹកនិងស្មៅយ៉ាងណា ជរាក៏តែងគៀងនូវជីវិតនៃសព្វសត្វទាំងឡាយ ទៅកាន់មរណៈក៏យ៉ាងនោះដែរ ។

១០៩– រូបរបស់យើងនេះដូចជាដុំពពុះទឹក វេទនាដូចជាក្រពេញទឹកដែលប៉ោងឡើងព្រិចៗ សញ្ញាដូចគាន់ងថ្ងៃបណ្ដើរគូទ សង្ខារទាំងឡាយមានសេចក្ដីប្រៀបនឹងដើមចេក វិញ្ញាណប្រៀបដូចជាកលមាយា សេចក្ដីប្រៀបនេះគឺព្រះពុទ្ធ

ដែលជាបុគ្គលប្រសើរក្នុងលោកទ្រង់សំដែងមក ៗ

១១០— សេចក្តីចាស់ស្លាប់ តែងតែគ្រប់សង្កត់សត្វ សត្វទាំងឡាយឥតមានសល់មុះជា នេះជាសេចក្តី ជាទាម៉ឺន ជាអ្នកជំនួញ ជាអ្នកចំការ ទឹងជាអ្នកកម្មករទេ ដូចជាថ្មភ្នំ ខ្ពស់ពេញអាកាសកាលបើធ្លាក់បែករមាលមកគ្រប់ទិសទាំង ៤ តែងគ្រប់សង្កត់សត្វលោកមិនរើសមុខយ៉ាងនោះដែរ ៗ

១១១— ពលរថ, ពលដំរី, ពលថ្មើរជើង ឬក៏ចម្បាំង តបតនៅក្នុងភូមិដកមរណៈនោះមិនមានទេ, ហេតុនោះបុគ្គល ជាបណ្ឌិត កាលបើចង់បាននូវប្រយោជន៍ខ្លួនគប្បីបណ្តុះសទ្ធា ចំពោះព្រះពុទ្ធ ព្រះធម៌និងព្រះសង្ឃដោយសេចក្តីមិនប្រមាទ ៗ

១១២— បុគ្គលណាមួយជាអ្នកប្រព្រឹត្តធម៌ដោយកាយ វាចានិងដោយចិត្ត បណ្ឌិតទាំងឡាយតែងសរសើរនូវបុគ្គល នោះក្នុងលោកនេះឯង ៗ

១១៣— អាយុជីវិត ១ ព្យាធិ ១ កាលមរណៈ ១

ទីកាលមរណៈ ១ ទីដំណើរទៅកាន់បរលោកនាយ ១ សភាពទាំង ៥ ប្រការនេះ គ្មានបុគ្គលណាមួយក្នុងលោកដឹងច្បាស់បានឡើយ ។

១១៤- បុគ្គលមិនគប្បីប្រហែសធ្វេស ដោយគិតថា " សេចក្តីស្លាប់មិនមានដល់អញ " ដូច្នេះឡើយ, គប្បីគិតថា ជីវិតនៃមនុស្សសត្វនេះតិចណាស់, ដូចជាភ្លើងកាលបើឆេះដល់ក្បាលហើយគង់នឹងឆេះដល់ខ្លួនទៀតយ៉ាងឆាប់ ។

១១៥- សត្វពស់កាលបើដល់ចាស់ហើយ តែងសកសំណកចោលហើយលូនទៅយ៉ាងណា, សត្វលោកកាលបើសរីរៈចាស់គ្រាំគ្រាប្រើការមិនកើតហើយ តែងស្លាប់ទៅចោលរាងកាយនេះ ទៅកាន់លោកឯទៀតយ៉ាងនោះដែរ, សូម្បីតែសរីរៈដែលសល់នៅគេយកមកដុតឬកប់ក៏មិនដឹងខ្លួន កុំថាឡើយដល់ទៅយំសោក ។

១១៦- សេចក្តីទុក្ខមិនមែនកើតមកអំពីហេតុដទៃក្រៅ

ពិតណាទេ  ទុក្ខនោះពិតជាកើតមកពីតណ្ហាតែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុនោះ  ទើបព្រះពុទ្ធទ្រង់ត្រាស់ថា "តណ្ហានេះជារបស់ពិត ១  តាមទំនងដែលជាហេតុបណ្ដាលឱ្យកើតទុក្ខ" ។

១១៧- មិនមានគុណជាតិអ្វីដែលអាចរម្ងាប់សេចក្តីទុក្ខបានឡើយ  មានតែគុណជាតិមួយគឺ "ព្រះនិព្វាន" ទេ ទើបអាចរំលត់បាន, ព្រោះហេតុនោះ  ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា  "ព្រះនិព្វានជារបស់ពិត ១  តាមទំនងនៃសភាពដែលរម្ងាប់នូវទុក្ខបាន" ។

១១៨- គុណជាតិដទៃក្រៅពីមគ្គទាំង ៨ (អដ្ឋង្គិកមគ្គ)  មិនមែនជាឧបាយសម្រាប់ទាញសត្វឱ្យផុតពីទុក្ខបានឡើយ (គឺមានតែមគ្គទាំង ៨ ដោយពិត) ព្រោះហេតុនោះ បានជាព្រះសម្ពុទ្ធទ្រង់ត្រាស់ថា  "មគ្គទាំង ៨ នោះជារបស់ពិត ១  ព្រោះជាឧបាយនាំទាញសត្វលោកឱ្យផុតចាកពីទុក្ខ

បាន ។

១៥៩- អដ្ឋង្គិកមគ្គ ៨ នោះគឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្ប ១ សម្មាវាចា ១ សម្មាកម្មន្ត ១ សម្មាអាជីវ ១ សម្មាវាយាម ១ សម្មាសតិ ១ សម្មាសមាធិ១ ត្រូវជា ៨ ប្រការ ។

១៦០- សម្មាទិដ្ឋិ គឺប្រាជ្ញាយល់ត្រូវ បានដល់បញ្ញាចេតសិកដែលយកព្រះនិព្វានមកជាអារម្មណ៍ ហើយដឹងច្បាស់ក្នុងទុក្ខសច្ច ដឹងច្បាស់ក្នុងទុក្ខសមុទយសច្ច ដឹងច្បាស់ក្នុងទុក្ខនិរោធសច្ច ដឹងច្បាស់ក្នុងទុក្ខនិរោធគាមិនីបដិបទាសច្ច ឬមគ្គសច្ច ហើយប្រតិបត្តិដកកិលេសបង់នូវអវិជ្ជាទឹងតណ្ហានោះ ឈ្មោះហៅថា សម្មាទិដ្ឋិ ជាអង្គនៃអរិយមគ្គទី ១ ។

១៦១- សភាពមានចិត្តប្រកបក្នុងការត្រិះរិះដើម្បីបំពេញទាន សីល ភាវនា ត្រិះរិះលះបង់នូវព្យាបាទគំនុំទឹងអាឃាតចងពៀរនឹងគ្នាក្តី ត្រិះរិះក្នុងការមិនបៀតបៀននូវសត្វ

ការគិតនោះគឺ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ហៅថាសម្មា-
សង្កប្បៈ ជាអង្គនៃអរិយមគ្គជាគំរប់ ២ ។

១៦២- វចីសុចរិត ៤ គឺមិនកុហកបញ្ឆោតឲ្យខូចប្រ-
យោជន៍អ្នកដទៃមួយ មិនញុះញង់បំបែកបំបាក់អ្នកដទៃឲ្យកើត
ក្តីក្តៅក្រហាយ១ មិនពោលពាក្យអាក្រក់មានជេរប្រទេចអ្នក
ដទៃ១ មិនពោលពាក្យតិរច្ឆានកថាក្រមាប់កំប្លែងលេងឥតប្រ-
យោជន៍១ ទាំងអស់នេះព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់
ថាសម្មាវាចា អង្គនៃអរិយមគ្គជាគំរប់៣ ។

១៦៣- កាយសុចរិត៣ប្រការ គឺមិនសម្លាប់សត្វមាន
ជីវិតរស់នៅឲ្យស្លាប់១ មិនលួចទ្រព្យអ្នកដទៃដែលគេមិនបាន
ឲ្យ១ មិនប្រព្រឹត្តខុសគន្លងបវេណីដោយប្រពន្ធអ្នកដទៃនឹង
ស្រ្តីមិនមែនជាភរិយាខ្លួន១ ទាំង៣ប្រការនេះ ព្រះវិតជីមារ
ទ្រង់ត្រាស់ហៅថាសម្មាកម្មន្ត-គឺការងារល្អ ជាអង្គនៃអរិយ
មគ្គជាគំរប់៤ ។

១៦៤– សម្មាជីវោ ដែលជាអង្គនៃអរិយមគ្គទី៥នោះ សំដៅយកអ្នកបួសក្នុងព្រះពុទ្ធសាសនា ដែលលះបង់នូវមិច្ឆាអាជីវៈ គឺចិញ្ចឹមជីវិតមិនត្រូវតាមធម៌ ឧអនេសន នឹងវេជ្ជកម្មជាដើម, ហើយដំកល់ក្នុងសម្មាជីវៈ ចិញ្ចឹមជីវិតប្រកបដោយធម៌មានការក្រាបបិណ្ឌបាតដោយកម្លាំងស្នងជាដើម ។....

១៦៥– ចំណែកខាងគ្រហស្ថវិញ ដែលវៀរចិញ្ចឹមជីវិតក្រៅនូវធម៌មានវណិជ្ជា៥ប្រការជាដើម នឹងការលក់ដូរបំបាត់ដោយក្លែងជញ្ជីង ឬរង្វាល់វេចជាដើម ។

១៦៦– បុគ្គល ដែលជឿជាក់ក្នុងព្រះពុទ្ធសាសនា ហើយខំលះបង់អំពើអកុសល ដែលមានឲ្យវិនាសទៅវិញ ១ ប្រឹងស្មារតីមិនឲ្យអំពើអកុសលដែលមិនទាន់កើតមាន មិនឲ្យកើតដល់ខ្លួនបាន១ ព្យាយាមធ្វើកុសលធម៌ដែលមិនទាន់កើតឲ្យកើតឡើង១ ធ្វើនូវកុសលធម៌ដែលកើតហើយនោះមិនឲ្យវិនាសទៅវិញ១ ព្យាយាមទាំង៤ ប្រការនេះព្រះពុទ្ធទ្រង់ត្រាស់

ហៅថា សម្មាវាយាមោ ជាអង្គនៃអរិយមគ្គជាគំរប់៦ ។

១២៧- អង្គនៃអរិយមគ្គជាគំរប់៧នោះ សម្មាសតិបាន ដល់ការដំកល់ចិត្តត្រូវគឺសតិបដ្ឋាន ៤ ប្រការគឺ តាំងសតិ យកសរីរៈកាយជាអារម្មណ៍ហើយចំរើនវិបស្សនា១ យកវេទនាជាអារម្មណ៍ហើយចំរើនវិបស្សនា១ យកចិត្តជាអារម្មណ៍ហើយចំរើនវិបស្សនា១ ដំកល់សតិយកធម៌គឺសញ្ញាចេតសិក និងសង្ខារចេតសិកជាអារម្មណ៍ហើយចំរើនសមថវិបស្សនា១ ។

១២៨- អង្គនៃអរិយមគ្គជាគំរប់ ៨ គឺសម្មាសមាធិបាន ដល់ការលះបង់កិលេសកាមនិងវត្ថុកាម និងតាំងចិត្តឲ្យស្ងាត់ចាកកាមទាំងនោះ ហើយចំរើនទូវសមាធិ មានចូលបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន តែមួយខណៈចិត្តក៏ឈ្មោះជាសម្មាសមាធិដែរ ។

១២៩- សូមសន្តិភាពបូរមានដល់ព្រះពជា ទាំងពួងទាំងឡាយផង ដល់ព្រះពជាដែលឥតយ័ធន៍ ហើយសូមឲ្យមាន

បីតិបាមោជ្ជៈកាយសប្បាយគ្រប់កាលទាំងពួង! សូមកិត្តិយស ខ្ពង់ខ្ពស់ចូរវិឡ្សនាការចំរើនដល់លោក ដែលប្រព្រឹត្តកុសលកម្មឲ្យបានស្ថិតស្ថេរថេរកាលតទៅ។ សូមទិកសាស្ត្រនេះចូរជិតជិតស្និទ្ធនៃបទក្សញដំនូកនៃមន្ត្រីភាពទាំងឡាយ ហើយជុំជប់នូវមាត់អស់កាលជានិរន្តរ៍តទៅ។ សូមសេចក្ដីសុខសាន្តដ៏ធំក្រៃលែងដ៏ច្រើនក្រៃលែង ចូរមានដល់ប្រជាជនទាំងឡាយរាល់ទិនទិវារាត្រីគ្រប់កាលទៅហោង ! ៗ

១៣០- សូមព្រះឥន្ទ្រាធិរាជបង្អូរនូវភ្លៀងដែលសព្វសត្វប្រាថ្នាឲ្យត្រូវតាមកាល ដើម្បីឲ្យធញ្ញជាតិដុះលូតលាស់បរិបូណ៌ដេរដាសពាសពេញភូមិឋានទៀង សូមប្រមុខនៃព្រាហ្មណ៍ព្រឹទ្ធ បណ្ឌិតគ្រប់ប្រព្រឹត្តបំពេញព្រះជ័យទេវតាទាំងឡាយដោយគ្រឿងពលីទាំងឡាយ ទៅតាមយញ្ញពិធីសព្វកាល សូមសន្តិមនៃសាធុជនទាំងឡាយ មូលមិត្រព្រមគ្រឿងគ្នាកៀរគរប្រមែប្រមូល សេចក្ដីសុខឲ្យកើតទូលំទូលាយ

ត្រឡុកត្រឡប់ទៀតហូតដល់កល្បវិនាស សូមទ្រគុំ គឺពុ-ជិនអាក្រក់សាមាន្យរឹងក្រៃលែងរឹងដូចស៊ីម៉ង់ត៍រឹង ហើយដែលគេផ្ចាញ់បានដោយកម្រនោះ ដល់ទូវវិនាសហិនហោចខ្ទេចផង់ សាបសូន្យអន្តរធានបាត់បង់អស់កុំឲ្យសេសសល់ដល់ម្នាក់ឡើយ ។

១៣១– បារមីនៃព្រះសម្មាសម្ពុទ្ធ ជាមកុដនៃត្រៃភព ដែលមានព្រមទាំងពលនៃមារ ទៅផ្ចាញ់ហើយមិនកើបញ្ញាប់ញ័រ យ៉ាងណា សូមឲ្យលោកន័យសាស្ត្រ ទុកដូចជាកុំម៉ាសគីកំហិមាលយាប៉ុព្រះអាទិត្យ ដែលមានពន្លឺរនឹងរឿងសុរនោសរនៅដូចជាភ្លើងប្រល័យលោកនេះ ផ្សាយចេញទៅពេញសា-កលលោក ហើយបិតបេរបោះតាលនៅដកបនោះ ។

ប៉ប

ការផ្សាយសៀវភៅ នេះជា eBook បាន បង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **ម៉ាន ផាន្នី**

តុលា ឆ្នាំ ២០១៥

គាំទ្រដោយ កូនប្រុស ស្រី

លោក ស៊ី ដារា និងលោកស្រី សុន ដារី ព្រមទាំងលោកស្រី បុប្ផា ដឺឡូប៉ែស

ដើម្បី ឧទិសកុសល ដល់វិញ្ញាណក្ខន្ធ

លោកឪពុក សង្វារ ដឺ ឡូប៉ឺស និងលោកម្តាយ ឌិន សៅខុន

សូមអរគុណ

ខ្ញៅ យុនសំរ៉ង

ប្រធាន

**មូលនិធិខ្មែរសម្រាប់ការសិក្សា**

www.elibraryofcambodia.org

មានលក់ ដុំ និង លក់រាយ

សៀវភៅធម៌គ្រប់ប្រភេទនៅ "បណ្ណាគារត្រៃរតន៍"

# 136 Eo វិថីខេមរភូមិន្ទ

ទូរស័ព្ទលេខ: ០១២ ៧០៦ ៥៨១

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។